សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**សារណាបញ្ចប់ការសិក្សា**

# ការផ្តល់សេវាសាធារណៈនៃការិយាល័យ
# ច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅ

ស្រាវជ្រាវចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥

| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ទី ហុងឡេង** | បណ្ឌិត **សឿន សោភ័ណ** |
| **ក.តេង គន្ធា** | |

| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ | | ឆ្នាំចូលសិក្សា | ២០១១ |
| ជំនាន់ទី ៨ | | ឆ្នាំសរសេរសារណា | ២០១៥ |

# អារម្ភកថា

ក្រោយពីបានឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមកនេះ ធ្វើឱ្យយើងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើនទាក់ទងទៅនឹងការគ្រប់គ្រងរដ្ឋបាល។ នៅពេលចាប់ផ្តើមសិក្សាដំបូងយើងខ្ញុំមានក្តីស្រមៃចង់បន្សល់ទុកនូវស្នាដៃមួយនៅសាកលវិទ្យាល័យបន្ទាប់ពីបានបញ្ចប់ការសិក្សា ដើម្បីទុកជាឯកសារសម្រាប់ជួយដល់សិស្សនិស្សិតក្នុងការសិក្សាស្រាវជ្រាវនាពេលក្រោយៗទៀត។ ស្ថិតនៅក្នុងការសិក្សានាពេលដំបូង យើងខ្ញុំបានជួបប្រទះនូវការលំបាកមួយចំនួន ដោយសារតែជំនាញនេះត្រូវបានផ្លាស់ប្តូរនូវមុខវិជ្ជាថ្មីៗមួយចំនួន ហើយម្យ៉ាងវិញទៀតគឺឯកសារដែលទាក់ទងនឹងមុខវិជ្ជាមួយចំនួនមិនសូវសំបូរបែបនោះទេ ពោលគឺការសិក្សា និងឯកសារភាគច្រើនត្រូវបានសាស្ត្រាចារ្យពឹងផ្អែកទៅលើឯកសារបរទេសច្រើនជាងឯកសារក្នុងស្រុក ដែលជាហេតុធ្វើឱ្យចំណុចមួយចំនួនមានការលំបាកក្នុងការស្វែងយល់។ ប៉ុន្តែទោះជាយ៉ាងណាក្តី ដោយសារតែការយកចិត្តទុកដាក់ និងការខិតខំប្រឹងប្រែងរបស់យើងខ្ញុំ បូករួមទាំងការបង្ហាត់បង្ហាញពីសំណាក់សាស្ត្រាចារ្យផងនោះ ទើបធ្វើឱ្យយើងខ្ញុំទទួលបានលទ្ធផលល្អជាទីគាប់ចិត្ត ស្តែងឡើងតាមរយៈលទ្ធផលនេះបានបង្ហាញថាយើងខ្ញុំបានទទួលនូវឱកាសមួយនៅក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

នៅពេលទទួលបានឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សា យើងខ្ញុំក៏បានសម្រេចចិត្តជ្រើសរើសប្រធានបទ "ការផ្តល់សេវាសាធារណៈនៃការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅ" ដើម្បីធ្វើការស្រាវជ្រាវ។ មូលហេតុសំខាន់ដែលទាក់ទាញចិត្តរបស់យើងខ្ញុំឱ្យជ្រើសរើសប្រធានបទនេះមកធ្វើការស្រាវជ្រាវ គឺដោយសារតែសាលាខណ្ឌច្បារអំពៅជាខណ្ឌមួយទើបបង្កើតថ្មីហើយការិយាល័យច្រកចេញចូលតែមួយនៃខណ្ឌច្បារអំពៅក៏ទើបចាប់ផ្តើមដំណើរការផងដែរ។

ជាចុងបញ្ចប់ យើងខ្ញុំមានក្តីសង្ឃឹមយ៉ាងមុតមាំថាស្នាដៃមួយនេះអាចទុកធ្វើជាទុនដល់ការសិក្សាស្រាវជ្រាវ ដែលទាក់ទងនឹងការផ្តល់សេវាសាធារណៈនៃការិយាល័យច្រកចេញចូលតែមួយរបស់មិត្តនិស្សិតជំនាន់ក្រោយៗទៀត។ រាល់កំហុសឆ្គងដែលកើតមានឡើងដោយអចេតនានូវពាក្យពេចន៍ ក៏ដូចជាអត្ថន័យសូមមេត្តាខន្តីអភ័យទោស។ សូមស្វាគមន៍ជានិច្ចនូវរាល់ការរិះគន់ទាំងឡាយណាដែលធ្វើឡើងក្នុងគោលបំណងស្ថាបនា ដើម្បីឱ្យស្នាដៃមួយនេះកាន់តែមានភាពត្រឹមត្រូវនិងល្អប្រសើរជាងនេះ។

សូមអរគុណ!

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទ **ទី ហុងឡេង** និងនាងខ្ញុំ **តេង គន្ធា** ជានិស្សិតឆ្នាំទី៤ ជំនាញរដ្ឋបាលសាធារ-ណៈដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវភាពកតញ្ញូតាធម៌ជូនចំពោះអ្នកមានគុណគឺ លោកឪពុក **តាច លី** អ្នកម្តាយ **សួរ ហួរ** និងលោកឪពុក **តេង ឈៀក** និងអ្នកម្តាយ **ម៉ាង យឿន**។ លោកទាំងពីរបានលះបង់ទាំងកម្លាំងកាយកម្លាំងចិត្តមិនខ្លាចនឿយហត់ទោះបីជួបប្រទះនូវការលំបាកច្រើនបែបណាក៏លោកនៅតែព្យាយាមជំរុញនិងលើកទឹកចិត្ត ឧបត្ថម្ភដល់កូនទាំងផ្នែកស្មារតី និងសម្ភារដើម្បីឱ្យកូនមានចំណេះដឹងជ្រៅជ្រះដែលជាស្ពានចម្លងទៅអនាគតដ៏ភ្លឺស្វាងដោយមិនគិតពីការលំបាករបស់ខ្លួននោះឡើយ។

ជាងនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះលោកគ្រូអ្នកគ្រូសាស្ត្រាចារ្យទាំងអស់ដែលបានបង្ហាត់បង្រៀន យើងខ្ញុំតាំងពីចាប់ផ្តើមរហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ លើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជាទីបំផុតដល់ លោកសាស្ត្រាចារ្យ **សឿន សោភ័ណ** ដែលបានព្យាយាមពន្យល់ណែនាំបង្ហាត់បង្ហាញអស់ពីកម្លាំងកាយចិត្ត និងជួយកែតម្រូវរាល់កំហុសឆ្គង និងចំណុចខ្វះខាតជាច្រើនដើម្បីឱ្យស្នាដៃនេះអាចបង្កើតឡើងបានជារូបរាង។

ជាពិសេសទៅទៀតយើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណដល់លោក **ស្រេង គឹមស្រ៊ុន** និងលោក **តាត់ ប៊ុនហេង**ដែលជាមន្ត្រីបម្រើការងារនៅក្រសួងមហាផ្ទៃដែលបានជួយផ្តល់ឯកសារមួយចំនួនពាក់ព័ន្ធទៅនឹងប្រធានបទ។ បន្ថែមពីនេះទៀត សូមថ្លែងអំណរគុណដល់លោក **អ៊ាង ស៊ីផាន** អភិបាល នៃគណៈអភិបាលខណ្ឌច្បារអំពៅដែលបានអនុញ្ញាតឱ្យយើងខ្ញុំចុះធ្វើការសិក្សាស្រាវជ្រាវលើការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ។ លោក **ហ៊ួត ហ៊ុយ** នាយករដ្ឋបាល និងលោក **អ៊ុំ សុផៃ** អនុប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុសាលាខណ្ឌច្បារអំពៅដែលបានជួយសម្រួល និងផ្តល់ជាឯកសារដែលពាក់ព័ន្ធនឹងប្រធានបទនេះ។ ហើយសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះលោក **យី ធីរ៉ាត** ប្រធានការិយាល័យច្រកចេញចូលតែមួយ និងលោកស្រី **ខៀវ សុភាវី** អនុប្រធាន ព្រមទាំងបុគ្គលិកធ្វើការនៅការិយាល័យច្រកចេញចូលតែមួយនិងខណ្ឌច្បារអំពៅដែលបានទទួលស្វាគមន៍ និងជួយសម្រួលដល់ការចុះស្រាវជ្រាវទៅលើប្រធានបទមួយនេះ។ លោក **ទី ហុងលីម** ដែលបានផ្តល់ជាឯកសារ។ ជាចុងបញ្ចប់យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរជូនដល់លោកអ្នកមានគុណ ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ សូមឱ្យប្រកបតែជោគជ័យគ្រប់ភារកិច្ច និងជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**អារម្ភកថា** ........ i
**សេចក្ដីថ្លែងអំណរគុណ** ........ ii
**បញ្ជីតារាង** ........ vi
**សេចក្ដីផ្ដើម**
**១.លំនាំបញ្ហានៃការស្រាវជ្រាវ** ........ ១
**២.ចំណោទបញ្ហា** ........ ២
**៣.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ** ........ ២
**៤.គោលបំណងនៃការស្រាវជ្រាវ** ........ ៣
**៥.វិធីសាស្ត្រស្រាវជ្រាវ** ........ ៣
**៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ ៣
**ជំពូកទី ១ សញ្ញាណទូទៅនៃសេវាសាធារណៈនៃការិយាល័យច្រកចេញចូលតែមួយ**
១.១.និយមន័យ ........ ៥
១.១.១.ប្រវត្តិនៃការកកើតសេវាសាធារណៈ ........ ៥
១.១.២.គោលបំណងនៃសេវាសាធារណៈ ........ ៦
១.១.៣.ប្រភេទនៃសេវាសាធារណៈរបស់រដ្ឋ ........ ៨
១.១.៤.យន្តការនៃការអនុវត្តសេវាសាធារណៈ ........ ១១
១.២.ការិយាល័យច្រកចេញចូលតែមួយ ........ ១៥
១.២.១.និយមន័យ ........ ១៥
១.២.២.ប្រវត្តិនៃការកកើតការិយាល័យច្រកចេញចូលតែមួយនៅកម្ពុជា ........ ១៦
១.២.៣.គោលបំណងនៃការបង្កើតការិយាល័យច្រកចេញចូលតែមួយ ........ ១៧
១.២.៤.ក្រុង ស្រុក ខណ្ឌគោលដៅ ........ ១៧
១.៣.ទីតាំង និងតួនាទីភារកិច្ចរបស់ការិយាល័យច្រកចេញចូលតែមួយ ........ ១៨
១.៣.១.ទីតាំងសមស្របក្នុងការបង្កើតការិយាល័យច្រកចេញចូលតែមួយ ........ ១៨
១.៣.២.តួនាទី និងភារកិច្ចរបស់ការិយាល័យច្រកចេញតែមួយ ........ ១៨

## ជំពូកទី ២ ទិដ្ឋភាពទូទៅនៃការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ


២.១.ស្ថានភាពទីតាំងនៃការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅ ................. ១៩
២.១.១.ភូមិសាស្រ្ត ........................................................................................... ១៩
២.១.២.ប្រជាពលរដ្ឋ ........................................................................................... ១៩
២.២.ការបង្កើតការិយាល័យច្រកចេញចូលតែមួយនៅខណ្ឌច្បារអំពៅ ................................ ១៩
២.៣.ប្រភេទវិស័យរបស់សេវាសាធារណៈនៃការិយាល័យច្រកចេញចូលតែមួយ.................. ២០
២.៤.រចនាសម្ព័ន្ធនៅក្នុងការិយាល័យច្រកចេញចូលតែមួយ ................................................ ២០
២.៤.១.ផ្នែកជួរមុខ ........................................................................................... ២២
២.៤.២.ផ្នែកជួរក្រោយ........................................................................................ ២៤
២.៤.៣.ក្រុមសម្របសម្រួលរដ្ឋបាល ........................................................................ ២៧
២.៥.ការគ្រប់គ្រងការងារនៅក្នុងការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ ............. ២៨
២.៥.១.តួនាទីរបស់អភិបាលខណ្ឌ.......................................................................... ២៨
២.៥.២.តួនាទីរបស់អភិបាលរងទទួលបន្ទុក .............................................................. ២៨
២.៥.៣.តួនាទីរបស់ប្រធានការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ .............. ២៩
២.៥.៤.តួនាទីរបស់អនុប្រធានការិយាល័យច្រកចេញចូលតែមួយ ............................... ២៩
២.៥.៥.កាតូកិច្ចរបស់មន្ត្រីរាជការ បុគ្គលិកនៃការិយាល័យច្រកចេញចូលតែមួយ ........... ៣០
២.៦.នីតិវិធីរដ្ឋបាល ទម្រង់បែបបទ ការបង់ថ្លៃសេវា និងដែនកំណត់នៃការផ្តល់សេវាសាធារណៈ
របស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ ............................................... ៣០
២.៦.១.នីតិវិធីរដ្ឋបាល......................................................................................... ៣០
២.៦.២.ទម្រង់បែបបទ........................................................................................... ៣១
២.៦.៣.ការបង់ថ្លៃសេវា........................................................................................ ៣១
២.៦.៤.ដែនកំណត់នៃការផ្តល់សេវាសាធារណៈ ........................................................ ៣២
២.៧.វិន័យ និងការហាមឃាត់ចំពោះមន្ត្រីក្នុងការិយាល័យច្រកចេញចូលតែមួយ.................. ៣៣
២.៧.១.វិន័យ....................................................................................................... ៣៣
២.៧.១.១.ពេលវេលាប្រតិបត្តិការការងារ ............................................................... ៣៣
២.៧.១.២.ការឈប់សម្រាក........................................................................................ ៣៣
២.៧.១.៣.សីលធម៌ និងអាកប្បកិរិយា.................................................................. ៣៤

២.៧.២.ការហាមឃាត់ ........ ៣៩
២.៨.ធនធានហិរញ្ញវត្ថុនៃការិយាល័យច្រកចេញចូលតែមួយ ........ ៤០
២.៨.១.ចរិកលក្ខណៈនៃការិយាល័យច្រកចេញចូលតែមួយ ........ ៤០
២.៨.២.ប្រភពចំណូល ........ ៤០
២.៨.៣.ការចំណាយ ........ ៤៣
២.៩.ការិយាល័យប្រជាពលរដ្ឋ ........ ៤៤
២.៩.១.គោលបំណង ........ ៤៥
២.៩.២.តួនាទី ........ ៤៥
២.៩.៣.មុខងារ ........ ៤៥
**ជំពូកទី ៣ ការវិភាគលើរបបគំហើញនៃការផ្តល់សេវាសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ**
៣.១.លទ្ធផលនៃការបង្កើតការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ ........ ៤៧
៣.១.១.ផលវិជ្ជមាននៃការបង្កើតការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ ........ ៤៧
៣.១.២.ផលអវិជ្ជមាននៃការបង្កើតការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ ........ ៤៩
៣.២.បញ្ហាប្រឈម ........ ៥០
៣.២.១.ប្រជាពលរដ្ឋ ........ ៥០
៣.២.២.មន្ត្រីរាជការ ........ ៥១
៣.៣.ដំណោះស្រាយ ........ ៥២
៣.៣.១.ប្រជាពលរដ្ឋ ........ ៥៣
៣.៣.២.មន្ត្រីរាជការ ........ ៥៣
**សេចក្តីសន្និដ្ឋាន** ........ ៥៦
**អនុសាសន៍** ........ ៥៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

តារាងទី១ ចំណូលរបស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ
តារាងទី២ ចំណូលប្រចាំឆមាសទី១ក្នុងឆ្នាំ២០១៥របស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ
តារាងទី៣ ការបែងចែកប្រាក់ចំណូលដែលទទួលបានពីការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រោយពីបានបញ្ចប់សង្គ្រាមស៊ីវិលអស់រយៈពេលបីទសវត្សមកប្រទេសកម្ពុជា ក៏ចាប់ផ្តើមមានការប្រែក្លាយខ្លួនយ៉ាងឆាប់រហ័សពីប្រទេស ដែលធ្លាប់មានសង្គ្រាមរ៉ាំរៃមកជាប្រទេសដែលមានសុខសន្តិភាព ស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់ ប្រជាធិបតេយ្យ ការគោរពសិទ្ធិសេរីភាព ព្រមទាំងការកើនឡើងនូវកំណើនសេដ្ឋកិច្ច និងបានចូលរួមកាត់បន្ថយភាពក្រីក្រ។ ជាងនេះទៅទៀត រដ្ឋាភិបាលក៏បានធ្វើការកែទម្រង់ប្រព័ន្ធការងារក្នុងក្រសួងស្ថាប័នរដ្ឋចាប់តាំងពីឆ្នាំ ១៩៩៩ មកក្នុងគោលបំណងដើម្បីធ្វើឱ្យដំណើរការការងាររបស់រដ្ឋមានភាពរលូនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។[១]

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ទៅលើវិស័យសាធារណៈ ក៏ដូចជាការផ្តល់សេវាសាធារណៈក្នុងគោលបំណងបង្វិតសេវាសាធារណៈឱ្យមកជិតប្រជាពលរដ្ឋ។ ជាពិសេសបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានព្យាយាមធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងការបម្រើប្រជាពលរដ្ឋ ដើម្បីប្រែក្លាយខ្លួនពីអ្នកគ្រប់គ្រងទៅជាអ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍន៍ដែលអាចជឿទុកចិត្តដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។

លើសពីនេះទៅទៀត រាល់ក្រសួងស្ថាប័ននៅក្នុងវិស័យសាធារណៈត្រូវតែពង្រឹងខ្លួនដើម្បីជំរុញឱ្យការផ្តល់សេវាសាធារណៈឱ្យមាននិរន្តរភាព និងពង្រឹងភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈដើម្បីធ្វើឱ្យការផ្តល់សេវាសាធារណៈមានភាពស្អិតស្អេរនិងជឿទុកចិត្តបាន។ ជាក់ស្តែងសព្វថ្ងៃនេះ រាជរដ្ឋាភិបាលបានព្យាយាមបង្វិតសេវាសាធារណៈឱ្យកាន់តែជិតអ្នកប្រើប្រាស់សេវា តួយ៉ាងការបង្កើតការិយាល័យច្រកចេញចូលតែមួយ ដែលវាជាអង្គភាពមួយដែលរាជរដ្ឋាភិបាលសម្រេចបង្កើតឡើងធ្វើយ៉ាងណាឱ្យការបម្រើសេវាសាធារណៈរបស់រដ្ឋឱ្យទៅជិតអ្នកប្រើប្រាស់សេវា ក្នុងគោលបំណងដើម្បីឱ្យអ្នកទទួលសេវាទៅប្រើប្រាស់ អាចកាត់បន្ថយការចំណាយ កាត់បន្ថយពេលវេលាទទួលបានសេវាប្រកបដោយប្រសិទ្ធភាព គុណភាព ព្រមទាំងមានបែបបទរដ្ឋបាលងាយស្រួលនិងឆាប់រហ័សជាងមុន។

ទន្ទឹមនឹងនេះដែរ ការផ្តល់សេវាសាធារណៈរបស់រដ្ឋត្រូវបានបង្វិតមកជិតប្រជាពលរដ្ឋតាមរយៈការបង្កើតការិយល័យច្រកចេញចូលតែមួយនៅតាមបណ្តាខេត្តនានា និងបណ្តាខណ្ឌមួយចំនួននៃរាជធានីភ្នំពេញ។ ជាពិសេសការបង្កើតការិយាល័យច្រកចេញចូលតែមួយនៅខណ្ឌច្បារអំពៅ

[១] អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល,*របាយការណ៍ស្តីពីលទ្ធផលការងាររយៈពេល ៥ឆ្នាំ (១៩៩៩-២០០៣)របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល* (ភ្នំពេញ,២០០៤)។

ដែលវាជាអង្គភាពមួយ ដែលត្រូវបានបង្កើតក្នុងគោលបំណងបង្និតការផ្តល់សេវាសាធារណៈទាំងដប់មួយវិស័យជូនប្រជាពលរដ្ឋនៅក្នុងខណ្ឌច្បារអំពៅនេះតែម្តង។

ដំណើរការ នៃការផ្តល់សេវាសាធារណៈនៅការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅត្រូវបានចាប់ផ្តើមនៅឆ្នាំ២០១៤។ ទោះជាការបង្កើតការិយាល័យច្រកចេញតែមួយអាចជួយបង្និតសេវាសាធារណៈឱ្យទៅជិតប្រជាពលរដ្ឋក៏ពិតមែន ប៉ុន្តែក៏បានចោទចេញជាបញ្ហាមួយចំនួនផងដែរដូចជា នៅពេលចាប់ផ្តើមដំណើរការពេលដំបូង គឺបុគ្គលិកបម្រើការនៅក្នុងការិយាល័យច្រកចេញចូលតែមួយមិនទាន់បានយល់ដឹងច្បាស់អំពីនីតិវិធីនៃការប្រតិបត្តិការការងារ និងកង្វះខាតបុគ្គលិកមួយចំនួន ដោយសារតែសាលាខណ្ឌច្បារអំពៅបង្កើតឡើងដោយការបំបែកចេញពីសាលាខណ្ឌមានជ័យ។[២]

## ២.ចំណោទបញ្ហា

ស្ថិតនៅក្នុងប្រធានបទស្តីពី "ការផ្តល់សេវាសាធារណៈនៃការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅ" បានចោទជាបញ្ហាមួយចំនួនដូចជា:

-តើការបង្និតសេវាពីអាជ្ញាធរថ្នាក់ជាតិមកការិយាល័យច្រកចេញចូលតែមួយ បានផ្តល់ផលវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះដល់អ្នកប្រើប្រាស់សេវា?

-តើការិយាល័យច្រកចេញចូលតែមួយត្រូវអនុវត្តបែបណា ទើបការផ្តល់សេវាសាធារណៈទទួលបានប្រសិទ្ធភាពខ្ពស់?

-តើអ្នកផ្តល់សេវាសាធារណៈ គួរមានអាកប្បកិរិយាបែបណាចំពោះអ្នកមកទទួលយកសេវាសាធារណៈ?

## ៣.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវស្តីពី ការផ្តល់សេវាសាធារណៈនៃការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅ គឺជាប្រធានបទមួយដែលធ្វើការស្រាវជ្រាវផ្តោតសំខាន់ទៅលើដំណើរការនៃការផ្តល់សេវា និងការទទួលសេវានៅក្នុងការិយាល័យច្រកចេញចូលតែមួយនៅក្នុងខណ្ឌច្បារអំពៅទៅប្រើប្រាស់ និងការវិភាគទៅលើរបបគំហើញថ្មីដែលពាក់ព័ន្ធទៅនឹងផលវិជ្ជមាន បញ្ហាប្រឈម និងដំណោះស្រាយទៅលើការផ្តល់សេវា នៅក្នុងការិយាល័យច្រកចេញចូលតែមួយនៃខណ្ឌច្បារអំពៅ។ ដែនកំណត់នៃការស្រាវជ្រាវចាប់ពីឆ្នាំ២០១៤ទៅដល់ដើមឆ្នាំ២០១៥។

[២] សេចក្តីសម្រេចស្តីពីការផ្ទេរការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋពីរចនាសម្ព័ន្ធសាលាខណ្ឌមានជ័យ ទៅរចនាសម្ព័ន្ធសាលាខណ្ឌច្បារអំពៅ, លេខ២៣០៧ សសរ, ១៧ មិថុនា ២០១៤, ប្រការ១។

## ៤.គោលបំណងនៃការស្រាវជ្រាវ

ក្រោយពីបានទទួលជោគជ័យ ក្នុងការដាក់ដំណើរការសាកល្បងការិយាល័យច្រកចេញចូលតែមួយនៅខេត្តសៀមរាបរួចមក រាជរដ្ឋាភិបាលក៏បានបន្តសកម្មភាពបង្កើតការិយាល័យច្រកចេញចូលតែមួយបន្ថែមនៅតាមខេត្ត និងរាជធានីភ្នំពេញបន្ថែមទៀត។ ដូច្នេះហើយ ការិយាល័យច្រកចេញចូលតែមួយនៅសាលាខណ្ឌច្បារអំពៅក៏ត្រូវបានបង្កើតឡើងផងដែរនៅដើមឆ្នាំ២០១៤នេះ។ គោលបំណងចម្បងនៃការស្រាវជ្រាវនេះ គឺដើម្បីស្វែងរកអំពី គុណភាព ប្រសិទ្ធភាពនិងនីតិវិធីនៃការផ្តល់សេវា ឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានដែលប្រជាពលរដ្ឋនឹងទទួលបាននៅពេលដែលគាត់មកទទួលសេវាទៅប្រើប្រាស់ ព្រមទាំងការសិក្សាអំពី អាកប្បកិរិយារបស់មន្ត្រីរាជការ បញ្ហាប្រឈមទាំងឡាយដែលកើតមានឡើងក្នុងសកម្មភាពនៃការផ្តល់សេវាសាធារណៈនេះ និងផ្តល់ជូននូវដំណោះស្រាយសមស្របណាមួយ ដែលអាចជាយោបល់ ឬអនុសាសន៍ផ្សេងៗទៅលើចំណុចទាំងនោះ ក្នុងគោលបំណងដើម្បីឱ្យមានការអភិវឌ្ឍប្រសើរឡើងជាងមុន ទៅលើការផ្តល់សេវាសាធារណៈនៃច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅ។

## ៥.វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតទៅលើសេវានៃការិយាល័យច្រកចេញចូលតែមួយដោយបានប្រើវិធីសាស្ត្របែបគុណភាពហើយដោយប្រើប្រភពទិន្នន័យចម្បង និងបន្ទាប់បន្សំ។

**ទិន្នន័យចម្បង** (Primary Data)

ចំពោះទិន្នន័យចម្បងនេះគឺត្រូវបានរៀបចំឡើង ដោយមានការចុះផ្ទាល់ទៅដល់ទីកន្លែង និងធ្វើការសម្ភាសផ្ទាល់ជាមួយថ្នាក់ដឹកនាំការិយាល័យច្រកចេញចូលតែមួយ ព្រមទាំងមន្ត្រីបម្រើការនៅទីនោះ មិនតែប៉ុណ្ណោះក៏បានស្រង់មតិផ្ទាល់ជាមួយប្រជាពលរដ្ឋដែលមកប្រើប្រាស់សេវាផងដែរ។

**ទិន្នន័យបន្ទាប់បន្សំ** ( Secondary Data)

រីឯទិន្នន័យបន្ទាប់បន្សំវិញ គឺត្រូវបានធ្វើការរៀបចំឡើងតាមរយៈការប្រមូលផ្តុំឯកសារ របាយការណ៍ បទបញ្ជាផ្ទៃក្នុង សៀវភៅ បទដ្ឋានគតិយុត្តមួយចំនួនដែលពាក់ព័ន្ធ និងវេបសាយមួយចំនួន។

## ៦.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានភាពជោគជ័យល្អប្រសើរ ហើយមានគុណភាព និងប្រកបដោយប្រសិទ្ធភាពខ្ពស់នោះ គឺចាំបាច់ក្នុងការកំណត់រចនាសម្ព័ន្ធដ៏ពិតប្រាកដមួយដើម្បីអាចបំពេញតាមលក្ខណៈវិធីសាស្ត្រស្រាវជ្រាវត្រឹមត្រូវរបស់សាកលវិទ្យាល័យ។ កិច្ចការស្រាវជ្រាវនេះរួមមានបីផ្នែកសំខាន់ៗគឺ៖

សេចក្តីផ្តើម

ជំពូកទី១៖ សញ្ញាណទូទៅនៃសេវាសាធារណៈនៃច្រកចេញចូលតែមួយ

ជំពូកទី២៖ ទិដ្ឋភាពទូទៅនៃការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅ

ជំពូកទី៣៖ ការវិភាគលើរបបគំហើញនៃការផ្តល់សេវាសាធារណៈនៅច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅ

សេចក្តីសន្និដ្ឋាន

អនុសាសន៍

ឯកសារយោង

ឧបសម្ព័ន្ធ

# ជំពូកទី១
# សញ្ញាណទូទៅនៃសេវាសាធារណៈនៃច្រកចេញចូលតែមួយ

## ១.១.និយមន័យ

សេវាសាធារណៈ គឺត្រូវបានគេឱ្យនិយមន័យច្រើនបែបយ៉ាងទៅតាមការយល់ឃើញរបស់អ្នកនិពន្ធដូចជាសេវាសាធារណៈតាមន័យអង្គការ គឺសំដៅលើបុគ្គលិក និងមធ្យោបាយទាំងអស់ដែលនីតិបុគ្គលសាធារណៈប្រើសម្រាប់បម្រើការងាររដ្ឋការ។ សេវាសាធារណៈតាមន័យខ្លឹមសារ គឺជាសកម្មភាពដែលបម្រើប្រយោជន៍ទូទៅ ហើយដែលទទួលរ៉ាប់រងដោយរដ្ឋការ។ សេវាសាធារណៈតាមន័យគតិយុត្ត គឺសំដៅលើសកម្មភាពដែលស្ថិតក្រោមរបបគតិយុត្តមួយផ្សេងពីនីតិរូម។[៣]

សេវាសាធារណៈ មានន័យថាជាសេវាកម្មដែលបានផ្ដល់ឡើងដោយរាជរដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋដែលរស់នៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួនដោយផ្ទាល់ (តាមរយៈវិស័យសាធារណៈ) ឬដោយការផ្ដល់ជាហិរញ្ញវត្ថុដល់ផ្នែកឯកជនក្នុងការផ្គត់ផ្គង់សេវានោះ។ សេវាសាធារណៈ គឺជាសកម្មភាពបម្រើប្រយោជន៍ទូទៅដែលរាជការជាអ្នកទទួលបន្ទុក។[៤] តែបើតាមគោលនបាយស្ដីពីការផ្ដល់សេវាសាធារណៈនោះ បានកំណត់និយមន័យសេវាសាធារណៈ គឺសំដៅរាល់សកម្មភាពទាំងឡាយដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ចក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ។ ស្ថាប័នមានសមត្ថកិច្ច គឺសំដៅដល់ស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋ ដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន។ ស្ថាប័នទទួលសមត្ថកិច្ច គឺសំដៅដល់ផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិនិងភារកិច្ចពីរដ្ឋ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។[៥]

### ១.១.១.ប្រវត្តិនៃការកកើតសេវាសាធារណៈ

នៅក្នុងសតវត្សទី១៩ សេវាសាធារណៈបានចាប់ផ្ដើមកកើតឡើងនៅក្នុងប្រទេសអភិវឌ្ឍន៍ ដោយពេលនោះយើងសង្កេតឃើញថា ការផ្ដល់សេវាសាធារណៈទៅអ្នកប្រើប្រាស់សេវាសាធារណៈនោះមានដូចជាហ្គាស និងទឹកជាដើមដែលធ្វើឡើងដោយរាជការក្រុង។ ក្រោយមកសេវាមួយចំនួនទៀតត្រូវបានចាប់ផ្ដើមផ្ដល់ឱ្យជាបន្តបន្ទាប់ ដោយរាជរដ្ឋាភិបាលមានដូចជា អគ្គិសនី និងសេវាសុខភាព។ ដោយឡែកនៅក្នុងប្រទេសអភិវឌ្ឍន៍មួយចំនួនសេវាសាធារណៈ ត្រូវបានផ្ដល់

[៣] អ៊ុង ចំរើន, *សិក្ខាប័ននីតិរដ្ឋបាល* (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ), ៩១។
[៤] http://www.km.wikipedia.org/wiki/សេវាសាធារណៈ (ចូលទស្សនា ថ្ងៃទី៧ មេសា ២០១៥)។
[៥] ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល, *គោលនយោបាយស្ដីពី ការផ្ដល់សេវាសាធារណៈ* (ភ្នំពេញ៖ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល, ២០០៦), ៦។

ដោយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើកលែងតែនៅក្នុងប្រទេសអង់គ្លេស និងសហរដ្ឋអាមេរិចសេវាសាធារណៈរបស់រដ្ឋត្រូវបានធ្វើឯកជននីយកម្ម ដោយវិស័យឯកជនជាអ្នកដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាសាធារណៈដោយមានភាពត្រឹមត្រូវ ម៉ត់ចត់ និងប្រកបដោយប្រសិទ្ធភាព។ ចំណែកឯប្រទេសកំពុងអភិវឌ្ឍន៍ សេវាសាធារណៈគឺមិនសូវមានការរីកចំរើនប៉ុន្មានទេ។ ជាឧទាហរណ៍សេវាទឹកស្អាត ភាគច្រើនមានតែអ្នកមានកម្រិតជីវភាពមធ្យមតែប៉ុណ្ណោះដែលមានលទ្ធភាពប្រើប្រាស់សេវានេះ ដូច្នេះដើម្បីដោះស្រាយបញ្ហានេះទើបរាជរដ្ឋាភិបាល បានបង្កើតគោលនយោបាយចូលរួមកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋ ដោយរដ្ឋធ្វើការឧបត្ថម្ភធនមួយចំនួនលើសេវាកម្មទឹកស្អាត ក្នុងគោលបំណងដើម្បីឱ្យប្រពលរដ្ឋក្រីក្រអាចប្រើប្រាស់សេវាកម្មទឹកស្អាតនេះបាន។[៦]

### ១.១.២.គោលបំណងនៃសេវាសាធារណៈ

ការកែទម្រង់រដ្ឋបាលសាធារណៈនៅក្នុងប្រទេស រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការអភិវឌ្ឍលើវិស័យសាធារណៈតាមរយៈការពង្រឹងការផ្តល់សេវាសាធារណៈ ដើម្បីបម្រើប្រជាពលរដ្ឋរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង។ ក្នុងនោះគោលបណងនៃសេវាសាធារណៈបានរំលេចនូវចំណុចសំខាន់ៗមួយចំនួនដូចជា៖

#### ក.ដើម្បីធានាឱ្យមានភាពងាយស្រួលក្នុងការទទួលយកសេវាទៅប្រើប្រាស់

ដើម្បីកាត់បន្ថយភាពលំបាកដល់អ្នកប្រើប្រាស់សេវា និងកាត់បន្ថយការចំណាយបន្ថែមទៅលើអ្នករត់ការក្រៅផ្លូវការ នៅពេលដែលអតិថិជនមកទទួលសេវា នោះតម្រូវឱ្យរាល់ការផ្តល់សេវាសាធារណៈទាំងឡាយ គឺត្រូវតែមានព័ត៌មានគ្រប់គ្រាន់ ច្បាស់លាស់ ងាយស្រួល កាត់បន្ថយការិយាធិបតេយ្យ និងនីតិវិធីស្មុគស្មាញ។

#### ខ.ផ្តោតទៅលើតម្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់សេវា

កន្លងមកមន្ត្រីរាជការតែងតែចាត់ទុកខ្លួនឯងជាអ្នកគ្រប់គ្រង ដោយធ្វើការកំណត់ពីប្រភេទសេវាដែលគាត់ត្រូវផ្តល់ជូនអ្នកប្រើប្រាស់សេវា ដោយមិនបានគិតអំពីតម្រូវការរបស់អ្នកប្រើប្រាស់សេវាឡើយ។ តែក្រោយមកឥរិយាបថរបស់មន្ត្រីរាជការត្រូវបានធ្វើការផ្លាស់ប្តូរពី "អ្នកគ្រប់គ្រង" ទៅជា "អ្នកផ្តល់សេវា" ដែលនោះមានន័យថាគាត់ត្រូវកំណត់ប្រភេទសេវាទៅតាមតម្រូវការរបស់ទីផ្សារ និងតម្រូវការរបស់អ្នកប្រើប្រាស់វិញ។

[៦] http://www.km.wikipedia.org/wiki/សេវាសាធារណៈ (ចូលទស្សនា ថ្ងៃទី៧ មេសា ២០១៥)។

**គ.ផ្តល់សេវាឱ្យចំទីកន្លែងនៃតម្រូវការរបស់អ្នកប្រើប្រាស់សេវា**

ការផ្តល់សេវាសាធារណៈ គឺត្រូវតែនៅជិតអ្នកប្រើប្រាស់សេវា លើកលែងតែក្នុងករណីពិសេសមួយចំនួនដែលសេវាសាធារណៈនោះមិនអាចត្រូវគេផ្តត់ផ្តង់បាន។ ឧទាហរណ៍សេវាវះកាត់បេះដូងដែលបច្ចុប្បន្ននេះមានតែមួយកន្លែងគត់នៅរាជធានីភ្នំពេញ។ ក្នុងន័យនេះសេវារដ្ឋបាលសាធារណៈត្រូវតែបង្វិតឱ្យជិតប្រជាពលរដ្ឋ ក្នុងគោលបំណងបង្កឱ្យមានលក្ខណៈងាយស្រួលសម្រាប់ប្រជាពលរដ្ឋក្នុងការមកទទួលសេវាទៅប្រើប្រាស់។ ឧទាហរណ៍បើអ្នកប្រើប្រាស់ត្រូវការប្រភេទសេវាណាមួយនៅតំបន់ណាមួយ យើងត្រូវកំណត់ឱ្យមានសេវាប្រភេទនោះនៅតំបន់នោះតែម្តង មិនត្រូវឱ្យអ្នកប្រើប្រាស់សេវារត់ទៅរកសេវានោះវិញទេ។

**ឃ.ត្រូវមានតម្លាភាព និងការទទួលខុសត្រូវក្នុងការផ្តល់សេវា**

ក្នុងការផ្តល់សេវាជូនដល់អ្នកប្រើប្រាស់ អ្នកផ្តល់សេវាត្រូវតែផ្តល់ព័ត៌មានឱ្យបានទូលំទូលាយជាចំហដោយគ្មានការរើសអើង និងយកចិត្តទុកដាក់ក្នុងការផ្តល់សេវាឱ្យបានទាន់ពេលវេលាកំណត់ និងមានគុណភាពជូនដល់អ្នកប្រើប្រាស់ដោយមានស្មារតីទទួលខុសត្រូវខ្ពស់។ ដើម្បីឱ្យស្របតាមគោលការណ៍អភិបាលកិច្ចល្អ ការលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពជូនអ្នកផ្តល់សេវា ត្រូវទុកឱកាសឱ្យអ្នកប្រើប្រាស់សេវាតាមដាន និងស្វែងយល់អំពីនីតិវិធីនៃការផ្តល់សេវា និងទុកឱកាសឱ្យអ្នកប្រើប្រាស់សេវាធ្វើការទិទៀន តវ៉ា ឬទាមទារឱ្យមានការកែលម្អកង្វះខាតផ្សេងៗតាមតម្រូវការ។

**ង.គុណភាព និងប្រសិទ្ធភាពនៃសេវា**

ជាទូទៅអ្នកផ្តល់សេវាត្រូវបំពេញឱ្យបានទៅតាមស្តង់ដារកំណត់ ដែលនោះមានន័យថាអ្វីៗទាំងឡាយដែលបានកំណត់ជូនអ្នកប្រើប្រាស់រួចហើយនោះ អ្នកផ្តល់សេវាត្រូវតែធ្វើឱ្យបានទៅតាមការកំណត់នោះ ទាំងតម្លៃ ទាំងពេលវេលា និងគុណភាព។ ជាធម្មតាគុណភាពនៃសេវាត្រូវបានបង្ហាញដោយផ្អែកលើការពេញចិត្តរបស់អ្នកប្រើប្រាស់សេវា នៅពេលដែលសេវាត្រូវបានផ្តល់ជូននោះ អាចឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍ទូទៅរបស់អ្នកប្រើប្រាស់សេវា។ រាល់សេវាទាំងឡាយណា ដែលរដ្ឋបាលសាធារណៈមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ផ្តល់ជូនប្រជាពលរដ្ឋ រដ្ឋអាចស្វែងរកដៃគូអភិវឌ្ឍន៍ណា ដែលមានលទ្ធភាពគ្រប់គ្រាន់ដើម្បីជួយសម្រួលដល់អ្នកប្រើប្រាស់សេវាស្របតាមតម្រូវការ។[៧]

[៧] ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល, *គោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ* (ភ្នំពេញ៖ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល, ២០០៦), ២១-២៤។

### ១.១.៣.ប្រភេទនៃសេវាសាធារណៈរបស់រដ្ឋ

ប្រភេទសេវាសាធារណៈរបស់រដ្ឋត្រូវបានចងក្រង និងប្រមូលផ្តុំជា ៧ ប្រភេទធំៗទៅតាមវិស័យ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន។ ប្រភេទសេវាសាធារណៈរបស់រដ្ឋទាំង៧ មានដូចជាៈ ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម ចង្កោមសេវាពាក់ព័ន្ធយុត្តិធម៌និងអាជ្ញាកណ្តាល ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធនតូច និងមធ្យម បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ ចង្កោមសេវាសង្គមកិច្ច វប្បធម៌និងកិច្ចការនារី ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងចង្កោមសេវាពាក់ព័ន្ធនិងការប្រមូលចំណូល ការធ្វើវិចារណកម្មចំណាយ និងការបើកផ្តល់។

#### ក. ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ

ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ គឺជាសេវាទទួលខុសត្រូវផ្តាច់មុខរបស់រដ្ឋ ដែលផ្តល់ដោយអង្គភាពរដ្ឋ ឬនីតិបុគ្គលនៃនីតិសាធារណៈ ដែលរដ្ឋបានប្រគល់សិទ្ធិអំណាចឱ្យដើម្បីអនុវត្ត។ ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋមានដូចជា លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ បញ្ជីអត្រានុកូលដ្ឋាន សំបុត្រកំណើត ប័ណ្ណសំគាល់យានយន្ត អាកាសយាន និងនាវា វិញ្ញាប័ណ្ណប័ត្រទទួលស្គាល់កម្មសិទ្ធិ អត្តសញ្ញាណប័ណ្ណសំគាល់ប្រជាពលរដ្ឋខ្មែរ សៀវភៅគ្រួសារ ការធ្វើនីត្យានុកូលកម្មជាដើម។ ពាក់ព័ន្ធទៅនឹងចង្កោមនៃសេវាសាធារណៈនេះការរៀបចំ និងការប្រតិបត្តិការនៃការផ្តល់សេវាត្រូវទទួលខុសត្រូវដោយរដ្ឋ ឬភ្នាក់ងាររបស់រដ្ឋ។

#### ខ. ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម

ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការស្នាក់នៅ ការធ្វើដំណើរ ការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋ និងសុវត្ថិភាពសង្គមគឺជាសមត្ថកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច នគរបាលជាតិ កងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទគ្រប់លំដាប់ថ្នាក់ទូទាំងប្រទេស។ ចង្កោមសេវាទាំងនេះជាសេវាដែលចាំបាច់ និងមិនអាចខ្វះបាន ដើម្បីធានាបរិយាកាសល្អដល់ការអភិវឌ្ឍសង្គមជាតិ ការកាត់បន្ថយភាពក្រីក្រ ភាពសុខសាន្តរបស់ប្រជាពលរដ្ឋ និងជាទំនុកចិត្តដល់វិនិយោគិន ធុរជន ក្នុងការប្រកបរបរអាជីវកម្ម និងជំនួញជួញដូរ។ ពាក់ព័ន្ធទៅនឹងចង្កោមនៃសេវាសាធារណៈនេះការរៀបចំ និងការប្រតិបត្តិការនៃការផ្តល់សេវាត្រូវធ្វើឡើងដោយរដ្ឋ ឬភ្នាក់ងាររបស់រដ្ឋ។

**គ. ចង្កោមសេវាពាក់ព័ន្ធនិងយុត្តិធម៌ និងអាជ្ញាកណ្តាល**

ចង្កោមសេវាពាក់ព័ន្ធនិងយុត្តិធម៌ និងអាជ្ញាកណ្តាល ដូចជា វិវាទរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ឬរវាងប្រជាពលរដ្ឋនិងអ្នករាជការ ឬរវាងប្រជាពលរដ្ឋនិងផ្នែកឯកជន ឬរវាងអ្នករាជការនិងផ្នែកឯកជនជាដើម សេវាដោះស្រាយវិវាទនេះធ្វើឡើងតាមរូបភាពពីរយ៉ាង:

រូបភាពទី១៖ តាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលជាអ្នកសម្របសម្រួល និងដោះស្រាយចំពោះករណីវិវាទមិនធ្ងន់ធ្ងរ ដើម្បីសម្រួលដល់គូភាគីទាំងសងខាងដោយមិនចាំបាច់ពឹងផ្អែកទៅលើតុលាការ និងអាចកាត់បន្ថយការកកស្ទះសំនុំរឿងនៅតុលាការ។

រូបភាពទី២៖ ក្នុងករណីគូភាគីវិវាទ មិនទទួលយកនូវដំណោះស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ នោះការដោះស្រាយវិវាទ ត្រូវធ្វើឡើងតាមរយៈតុលាការ។

ភាពជឿទុកចិត្តរបស់អ្នកប្រើប្រាស់សេវានឹងអ្នកពាក់ព័ន្ធទាំងអស់ អាស្រ័យទៅលើការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ នៅក្នុងបរិបទនីតិរដ្ឋ។ ដូចនេះរាល់សកម្មភាពកែលម្អប្រព័ន្ធការងារទាំងអស់ត្រូវរៀបចំឡើងជាជំហានៗ និងដោយប្រុងប្រយ័ត្នក្នុងទិសដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាកម្មយុត្តិធម៌។

**ឃ. ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូច និងមធ្យមបរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ**

**-ការលើកកម្ពស់ពាណិជ្ជកម្ម**

រាជរដ្ឋាភិបាលដែលជាអ្នករៀបចំយុទ្ធសាស្ត្រនិងជាអ្នកគ្រប់គ្រងការអភិវឌ្ឍ ដើម្បីធ្វើឱ្យបរិស្ថានធុរកិច្ចកាន់តែប្រសើរសម្រាប់វិស័យឯកជន បានចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។ អាទិភាពជាពិសេសនឹងត្រូវផ្តោតទៅលើការរៀបចំឱ្យកាន់តែប្រសើរឡើងនូវបរិស្ថានរួមសម្រាប់ការអភិវឌ្ឍវិស័យឯកជន តាមរយៈវិធានការជាក់ស្តែងនានាដូចជា: ពង្រឹងអភិបាលកិច្ចល្អទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន។ កាត់បន្ថយរាល់បែបបទស្មុគស្មាញ និងវែងអន្លាយទៅតាមក្រសួងស្ថាប័នដែលពាក់ព័ន្ធដល់ការនាំចេញនាំចូល។ បំបាត់ចោលនូវភារកិច្ចជាន់គ្នារបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញដំណើរការត្រួតពិនិត្យតែមួយកន្លែងឱ្យមានប្រសិទ្ធភាព។ពង្រឹងការអនុវត្តយន្តការការិយាល័យ "ច្រកចេញចូលតែមួយ" នៅតាមបណ្តាច្រកអន្តរជាតិ។

**-សហគ្រាសធុនតូចនិងមធ្យម**

រាជរដ្ឋាភិបាលបន្តជំរុញការអភិវឌ្ឍសហគ្រាសធនតូច និងមធ្យមតាមរយៈគោលនយោបាយលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម ជាពិសេសតាមរយៈការផ្តល់ឥណទានរយៈពេលមធ្យម និងរយៈពេលវែង ទប់ស្កាត់ការរត់គេចពន្ធគ្រប់ប្រភេទ កាត់បន្ថយបែបបទការចុះបញ្ជី និង

ការរៀបចំដំណើរការក្រុមហ៊ុន។ សម្រួលដល់ការនាំចេញនាំចូលតាមរយៈការកាត់បន្ថយបែបបទស្មុគស្មាញក្នុងការស្នើសុំអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតផ្សេងៗ។ល។ កាត់បន្ថយពេលវេលា និងកាត់បន្ថយថ្លៃសេវាកម្មក្នុងការអនុញ្ញាតឱ្យដំណើរការផលិតកម្មនៃសហគ្រាសធុនតូច និងមធ្យមតាមរយៈការអនុវត្តយន្តការការិយាល័យច្រកចេញចូលតែមួយ។ ផ្តល់ការគាំពារដល់សហគ្រាសមួយចំនួនក្នុងរយៈពេលមួយសមស្រប។ ជំរុញឱ្យមានសម្ព័ន្ធភាពរវាងសហគ្រាសធុនតូចនិងមធ្យមជាមួយនិងឧស្សាហកម្មធុនធំជាដើម។

**- បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងថែទាំហេដ្ឋារចនា-សម្ព័ន្ធ**

ពាក់ព័ន្ធនឹងការងារនេះរាជរដ្ឋាភិបាលនឹងចាត់វិធានការចាំបាច់ ដើម្បីពង្រឹងនិងកែលម្អបរិស្ថានវិនិយោគ និងធុរកិច្ច រួមមាន គោលនយោបាយលើកទឹកចិត្ត លិខិតបទដ្ឋានសម្រាប់ណែនាំ និងជំរុញការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាងនិងថែទាំហេដ្ឋារចនាសម្ព័ន្ធ។ រចនាសម្ព័ន្ធនៃផ្នែកពាក់ព័ន្ធទៅនឹងចង្កោមសេវានេះ មិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការជាចាំបាច់ក្នុងការសម្របសម្រួលដល់ការធ្វើអាជីវកម្ម ការវិនិយោគ និងការអភិវឌ្ឍផ្នែកឯកជន ដូចនេះរចនាសម្ព័ន្ធនៃផ្នែកពាក់ព័ន្ធនេះត្រូវធ្វើការកែសម្រួលឱ្យបានសមស្រប និងឱ្យបានឆាប់រហ័សទៅតាមស្ថានភាពជាក់ស្តែង និងធនធានដែលមាន។

**ង. ចង្កោមសេវាសង្គមកិច្ច វប្បធម៌ និងកិច្ចការនារី**

ចង្កោមសេវានេះ រួមមាន សេវាអប់រំ (លើកកម្ពស់សេវាអប់រំសម្រាប់ទាំងអស់គ្នា សម្ភារៈសិក្សាគ្រប់គ្រាន់ និងសិទ្ធិទទួលបានសេវាអប់រំជាមូលដ្ឋាន) សេវាអនាម័យនិងសុខភាព (បង្កលក្ខណៈងាយស្រួល គុណភាព ប្រសិទ្ធភាព ដើម្បីផ្គត់ផ្គង់សេវាសុខាភិបាលមូលដ្ឋានប្រកបដោយសមធម៌ និងនិរន្តរភាពជូនប្រជាពលរដ្ឋគ្រប់រូបជាពិសេសជនក្រីក្រ និងក្រុមជនងាយរងគ្រោះ) សេវាសម្រាប់ការកំសាន្ត សេវាសង្គមកិច្ច សេវាគាំពារកុមារកំព្រា កុមារងាយរងគ្រោះ ជនពិការ សេវាលើកស្ទួយនិងការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសេវាដទៃទៀត ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

**ច. ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត**

ការផ្តល់សេវានៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គឺជាអាទិភាពចម្បងមួយរបស់រាជរដ្ឋា-ភិបាលដើម្បីជំរុញ និងបង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ត្រូវផ្តោតជាសំខាន់លើការបន្តការកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនរួមមានៈ ផ្លូវថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងអាកាសយានដ្ឋាន ដែលអាចតភ្ជាប់ពីទីក្រុងទៅ

ជនបទ និងគ្រប់ទីកន្លែងទូទាំងប្រទេស ការកសាងមន្ទីរពេទ្យ សាលារៀន អណ្តូងទឹក ប្រព័ន្ធទឹកស្អាត ប្រព័ន្ធធារាសាស្ត្រ អគ្គីសនី ថាមពល បច្ចេកវិទ្យាព័ត៌មាន ប្រៃសណីយ៍ និងទូរគមនាគមន៍។ល។ពាក់ព័ន្ធនឹងចង្កោមសេវានេះ រាជរដ្ឋាភិបាលមានគោលនយោបាយលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសផ្នែកឯកជន។

**ឆ. ចង្កោមសេវាពាក់ព័ន្ធទៅនឹងការប្រមូលចំណូល ការធ្វើវិចារណកម្មចំណាយ និងការបើកផ្តល់**

ចង្កោមសេវានេះ ពាក់ព័ន្ធនិងការកែលម្អការគ្រប់គ្រងចំណូល ចំណាយ និងការបើកផ្តល់ឱ្យមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់ជាងមុន សំដៅកាត់បន្ថយការលំបាករបស់អ្នកប្រើប្រាស់សេវា។ដើម្បីសម្រួលដល់ការអនុវត្ត ក្រសួង ស្ថាប័ន ដែលមានភារកិច្ចពាក់ព័ន្ធទៅនឹងចង្កោមសេវាណាមួយក្នុងចំណោមចង្កោមសេវាទាំង៧ខាងលើ ត្រូវរៀបចំចងក្រងបញ្ជីសេវានេះឱ្យបានសមស្រប។[៨]

**១.១.៤.យន្តការនៃការអនុវត្តសេវាសាធារណៈ**

យន្តការនៃការអនុវត្តសេវាសាធារណៈត្រូវបានដំណើរការតាមជម្រើសទាំង៩ដូចជា ការកែលម្អកិច្ចដំណើរការការងារនៃការផ្តល់សេវាសាធារណៈ ច្រកចេញចូលតែមួយ វិសហមជ្ឈការសេវាសាធារណៈ វិមជ្ឈការសេវាសាធារណៈ គ្រឹះស្ថានសេវាសាធារណៈ កិច្ចសន្យា ភ្នាក់ងារប្រតិបត្តិការពិសេស និងឯកជនភាវូបនីយកម្ម។ ការកំណត់យន្តការខាងលើនេះមានគោលបំណងជួយសម្រួលការងារដល់ក្រសួងស្ថាប័នទាំងអស់ក្នុងដំណើរការកែលម្អ និងការបង្កើតស្តង់ដារក្នុងការប្រើប្រាស់ទាំងនេះ។ ក៏ប៉ុន្តែការអនុវត្តអាស្រ័យទៅលើកាលៈទេសៈ និងទិដ្ឋភាពជាក់ស្តែងនៃរដ្ឋបាលសាធារណៈរបស់កម្ពុជា។ ដើម្បីទទួលបានភាពជោគជ័យនៃការផ្តល់សេវាសាធារណៈគឺវាអាស្រ័យទៅលើកិច្ចដំណើរការរបស់យន្តការទាំងអស់ ពេលវេលានៃការប្រព្រឹត្តទៅ និងតម្លៃនៃសេវា។

**ក.ការកែលម្អកិច្ចដំណើរការការងារ នៃការផ្តល់សេវាសាធារណៈ**

ការកែលម្អកិច្ចដំណើរការការងារ នៃការផ្តល់សេវាសាធារណៈ គឺជាយន្តការជាមូលដ្ឋានដើម្បីកែលម្អការផ្តល់សេវាសាធារណៈដែលកំពុងដំណើរការនៅតាមក្រសួងស្ថាប័ន និងភ្នាក់ងាររបស់រដ្ឋទាំងអស់តាមរយៈការលុបចោលនូវភាពជាន់គ្នា ឬភាពមិនច្បាស់លាស់នៃភារកិច្ច និងនីតិវិធីដែលចាំបាច់។ ការងារនេះត្រូវផ្តោតទៅលើនីតិវិធី អភិក្រម ពេលវេលា តម្លៃនៃការចំណាយ ប្រសិទ្ធភាព ជំនឿទុកចិត្ត និងគុណភាពនៃសេវាសាធារណៈដែលអ្នកប្រើប្រាស់បានទទួល។

[៨] ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល, *គោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ* (ភ្នំពេញ៖ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល, ២០០៦), ៨-២០។

**ខ.ច្រកចេញចូលតែមួយ**

ច្រកចេញចូលតែមួយ ជាយន្តការនៃការផ្តល់សេវាសាធារណៈដែលបង្កភាពងាយស្រួលដល់អ្នកប្រើប្រាស់ តាមនីតិវិធីសាមញ្ញ មានតម្លាភាព ប្រសិទ្ធភាព និងយកចិត្តទុកដាក់ចំពោះការផ្តល់យោបល់ និងការចាប់អារម្មណ៍របស់អ្នកប្រើប្រាស់សេវា។ យន្តការនេះប្រមូលផ្តុំជាចង្កោមនូវសេវាសាធារណៈមួយចំនួន ឱ្យមកនៅកន្លែងតែមួយ ទាំងកន្លែងស្នើសុំ និងកន្លែងទទួល ដោយកំណត់ពេលវេលាប្រគល់សេវា និងតម្លៃច្បាស់លាស់។ បទពិសោធន៍ល្អៗដែលបានអនុវត្តកន្លងមកត្រូវយកមកធ្វើជាគំរូនៃការអនុវត្តនៅទូទាំងប្រទេស។ ការផ្តល់សេវាសាធារណៈតាមយន្តការការិយាល័យច្រកចេញចូលតែមួយ ត្រូវរៀបចំឡើងដោយកំណត់តួនាទី ភារកិច្ច និងដែនសមត្ថកិច្ចឱ្យបានច្បាស់លាស់។ ការរៀបចំនិងការប្រព្រឹត្តទៅ ក្របខណ្ឌ គោលការណ៍ នីតិវិធី និងរចនាសម្ព័ន្ធនៃការផ្តល់សេវាតាមយន្តការការិយាល័យច្រកចេញចូលតែមួយត្រូវធ្វើឡើងតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

**គ.វិសហមជ្ឈការសេវាសាធារណៈ**

ការរៀបចំអំណាចគ្រប់គ្រងរដ្ឋបាល គឺជាការងារអាទិភាពនិងជាយុទ្ធសាស្ត្រ ដូចមានចែងក្នុងក្របខណ្ឌយុទ្ធសាស្ត្រស្តីអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥។ វិសហមជ្ឈការនៅក្នុងគោលនយោបាយនេះកំណត់តែអំពីសេវាសាធារណៈ និងការផ្តល់សេវាសាធារណៈក្នុងកម្រិតនៃអំណាចគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ តាមប្រព័ន្ធរដ្ឋបាលឯកភាពប៉ុណ្ណោះ។ រដ្ឋបាលឯកភាពនៅថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងជួយជំរុញកិច្ចសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន សំដៅជំរុញកិច្ចអភិវឌ្ឍន៍ និងការផ្តល់សេវាសាធារណៈដើម្បីឆ្លើយតបតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

**ឃ.វិមជ្ឈការសេវាសាធារណៈ**

ដោយផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ មិនា ឆ្នាំ ២០០១ រដ្ឋបាលឃុំសង្កាត់មានតួនាទី២ប្រភេទគឺ ១.តួនាទីបម្រើកិច្ចការមូលដ្ឋាន សម្រាប់បម្រើផលប្រយោជន៍ ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំសង្កាត់របស់ខ្លួន។ ២.តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។ ចំពោះតួនាទីទី២នេះរដ្ឋបាល ឃុំ សង្កាត់ មានភារកិច្ចដូចមានចែងក្នុងមាត្រា៤៣ និងមាត្រា៤៤នៃច្បាប់ស្តីអំពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់។ ការផ្តល់សេវាសាធារណៈរបស់រដ្ឋបាល

ឃុំ សង្កាត់ ត្រូវអនុវត្តជាជំហានៗ ផ្អែកលើស្ថានភាពជាក់ស្តែងនៃការវិវឌ្ឍរីកចម្រើនរបស់ទីផ្សារ និងទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់។

**ង.គ្រឹះស្ថានសាធារណៈរដ្ឋបាល**

គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាយន្តការនៃការផ្តល់សេវាសាធារណៈមួយផ្សេងទៀត ដែលមានស្វ័យភាពខាងហិរញ្ញវត្ថុ ឬរដ្ឋបាល និងជានីតិបុគ្គលនៃនីតិសាធារណៈ ដែលទទួលបន្ទុកជាចម្បងនូវបេសកកម្មផ្នែកសេវាសាធារណៈជាលក្ខណៈរដ្ឋបាល សង្គម សុខាភិបាល វប្បធម៌ វិទ្យាសាស្ត្រ ឬបច្ចេកទេស។

**ច.សហគ្រាសសាធារណៈ**

សហគ្រាសសាធារណៈ គឺជាយន្តការផ្តល់សេវាសាធារណៈរបស់រដ្ឋ ដែលស្ថិតក្រោមការគ្រប់គ្រងនៃនីតិឯកជន និងនីតិសាធារណៈ និងជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ ហើយដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ។ សហគ្រាសសាធារណៈមានបេសកកម្ម បង្កលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម មានជាអាទិ៍ការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព។ សហគ្រាសសាធារណៈមានទម្រង់ជាគ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនចម្រុះរដ្ឋ ដែលក្រុមហ៊ុនចម្រុះរដ្ឋកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលលើសពី ៥១ភាគរយនៃដើមទុនក្រុមហ៊ុន ឬសិទ្ធិបោះឆ្នោត។ សហគ្រាសសាធារណៈត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួង ឬអាជ្ញាធរសាធារណៈណាមួយ អាស្រ័យលើប្រភេទនៃសកម្មភាពរបស់សហគ្រាសនោះ។

- **គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច**

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច គឺជានីតិបុគ្គលនៃនីតិសាធារណៈដែលមានលក្ខណៈស្វ័យភាពហិរញ្ញវត្ថុ។ គ្រឹះស្ថានមួយនេះបានផលិតទំនិញ និងសេវាសម្រាប់បម្រើទីផ្សារ។

- **ក្រុមហ៊ុនរដ្ឋ**

ក្រុមហ៊ុនរដ្ឋ គឺជាក្រុមហ៊ុនដែលមានដើមទុនទាំងអស់ជារបស់រដ្ឋ។ ក្រុមហ៊ុនរដ្ឋ គឺជាយន្តការនៃការផ្តល់សេវាសាធារណៈជូនអ្នកប្រើប្រាស់សេវា ដោយធ្វើការប្រកួតប្រជែងនៅក្នុងបរិស្ថានសេដ្ឋកិច្ចទីផ្សារហើយដែលរដ្ឋអាចដំណើរការទៅបានដោយខ្លួនឯង។

- **ក្រុមហ៊ុនចម្រុះ**

ក្រុមហ៊ុនចម្រុះ គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតាមគោលការណ៍និងតាមបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយដែលដើមទុនត្រូវបានកាន់កាប់រួមគ្នាដោយនីតិបុគ្គល

ឬបវន្តបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ។ កាលណាភាគកម្មលាភសាធារណៈលើសពី ៥១%នៃដើមទុន ឬសិទ្ធិបោះឆ្នោត ក្រុមហ៊ុនចម្រុះរដ្ឋត្រូវបានចាត់ទុកជាសហគ្រាសសាធារណៈ។

- **កិច្ចសន្យា**

កិច្ចសន្យា គឺជាយន្តការមួយនៃការផ្តល់សេវាសាធារណៈ ក្នុងពេលដែលរដ្ឋពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការដាក់ឱ្យដំណើរការនូវការផ្តល់សេវា ស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់សេវា សំដៅពង្រឹងប្រសិទ្ធភាពការងារ លើកកម្ពស់គុណភាពសេវា ដើម្បីទទួលបាននូវទំនុកចិត្តពីអ្នកប្រើប្រាស់សេវា។ ការអនុវត្តយន្តការកិច្ចសន្យា ត្រូវមានលក្ខខណ្ឌការងារច្បាស់លាស់ដោយផ្អែកលើលទ្ធផលរំពឹងទុកលក្ខខណ្ឌនៃការអនុវត្តធនធានចាំបាច់សម្រាប់ដំណើរការ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ ភាគីជាប់កិច្ចសន្យាត្រូវប្រើប្រាស់មន្ត្រីរាជការនៅនឹងកន្លែងដែលអាចទទួលប្រាក់ឧបត្ថម្ភផ្អែកលើសមត្ថភាពមុខងារទទួលខុសត្រូវ និងលទ្ធផលដែលសម្រេចបាន។ ក្នុងករណីចាំបាច់ ភាគីជាប់កិច្ចសន្យា អាចជ្រើសរើសបុគ្គលិកបន្ថែមក្រៅពីមន្ត្រីរាជការរបស់រដ្ឋដើម្បីបំពេញការងារតាមតម្រូវការ។ ការសម្រេចដាក់ឱ្យដំណើរការផ្តល់សេវាសាធារណៈតាមយន្តការ កិច្ចសន្យាត្រូវធ្វើឡើងតាមគំនិតផ្តួចផ្តើមរបស់ក្រសួង ស្ថាប័នសាមីដោយមានការយល់ព្រមពីរាជរដ្ឋាភិបាល។

- **ភ្នាក់ងារប្រតិបត្តិការពិសេស**

ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈតាមយន្តការភ្នាក់ងារប្រតិបត្តិការពិសេស គឺជាទស្សនទានមួយថ្មី ដែលរបៀបនៃការដំណើរការត្រូវធ្វើឡើងតាមគោលដៅកំណត់។ ភ្នាក់ងារប្រតិបត្តិការពិសេស គឺជាអង្គភាពមួយរបស់ក្រសួង ស្ថាប័ន ដែលចាត់តាំងឡើងដើម្បីអនុវត្តឱ្យបានសម្រេចនូវគោលដៅពិសេសណាមួយរបស់រាជរដ្ឋាភិបាល ដោយផ្អែកលើលក្ខខណ្ឌបេសកកម្ម ហើយដែលមានភាពអនុគ្រោះ និងភាពបត់បែនទៅលើការរៀបចំ និងការប្រព្រឹត្តទៅ ការគ្រប់គ្រងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ខុសពីអង្គភាពដទៃទៀតនៅក្នុងក្រសួង ស្ថាប័ននោះ។ ការរៀបចំឱ្យមានភ្នាក់ងារប្រតិបត្តិការពិសេសនេះ មានគោលដៅលើកកម្ពស់ប្រសិទ្ធភាពការងារពង្រឹងគណនេយ្យភាព និងគំនិតផ្តួចផ្តើម សំដៅពង្រឹងវប្បធម៌នៃការយកចិត្តទុកដាក់ដល់អ្នកប្រើប្រាស់សេវា។ លក្ខខណ្ឌបេសកកម្មដើម្បីអនុវត្តន៍យន្តការភ្នាក់ងារប្រតិបត្តិការពិសេសត្រូវផ្អែកលើចំណុចជាមូលដ្ឋាន៤យ៉ាងគឺ: ១.ផ្តោតការយកចិត្តទុកដាក់លើតម្រូវការជាអាទិ៍ភាពរបស់អ្នកប្រើប្រាស់សេវាដោយកំណត់ឱ្យបានច្បាស់លាស់អំពី ប្រភេទ គុណភាព និងតម្លៃនៃសេវាដែលត្រូវផ្តល់ជូន។ ២.កំណត់ឱ្យបានច្បាស់លាស់អំពីលទ្ធផលរំពឹងទុក និងធនធានចាំបាច់នានា។ ៣.កំណត់ឱ្យបានច្បាស់លាស់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ភ្នាក់ងារនេះ។ ៤.កំណត់ឱ្យបានច្បាស់លាស់អំពីយន្តការនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

• ឯកជនភាវូបនីយកម្ម

ករណីចាំបាច់ខ្លះឯកជនភាវូបនីយកម្ម អាចត្រូវបានជ្រើសរើសជាយន្តការមួយដើម្បីសម្រួលដល់ការផ្តល់សេវាសាធារណៈជូនអ្នកប្រើប្រាស់សេវា។ ការដឹកនាំកម្មវិធីឯកជនភាវូបនីយកម្ម ត្រូវអនុលោមទៅតាមបទប្បញ្ញត្តិកំណត់ និងផ្សព្វផ្សាយឱ្យសាធារណជនបានយល់ដឹងអំពីដំណើរការនៃការប្រព្រឹត្តទៅ។ ការធ្វើឯកជនភាវូបនីយកម្មត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលតាមការស្នើសុំពីក្រសួង ស្ថាប័នសាមី។[៩]

## ១.២.ការិយាល័យច្រកចេញចូលតែមួយ

### ១.២.១.និយមន័យ

ការិយាល័យច្រកចេញចូលតែមួយ គឺជាកន្លែងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ អាជីវករ សហគ្រាសធុនតូច សិស្ស និស្សិត។

ការិយាល័យច្រកចេញចូលតែមួយ ជាកន្លែងប្រមូលផ្តុំសេវាកម្ម និងនីតិវិធីរដ្ឋបាលមួយចំនួននៅកន្លែងតែមួយ ជាកន្លែងដែលអតិថិជនមកទទួលទម្រង់បែបបទ និងទទួលព័ត៌មានគ្រប់គ្រាន់ច្បាស់លាស់ ស្តីពីការផ្តល់សេវាសាធារណៈផ្សេងៗហើយវាក៏ជាកន្លែងផ្តល់លទ្ធផលសម្រេចជាផ្លូវការដល់អតិថិជន។[១០]

ការិយាល័យច្រកចេញចូលតែមួយ គឺជាការិយាល័យផ្តល់សេវាកម្មដល់ប្រជាពលរដ្ឋមានគោលដៅបម្រើប្រជាពលរដ្ឋ អាជីវករ ពាណិជ្ជករ ក្រុមហ៊ុន សហគ្រាស និងអង្គការទាំងឡាយដែលកំពុងធ្វើសកម្មភាពក្នុងមូលដ្ឋានក្រុង ស្រុក ខណ្ឌ ក្នុងទិសដៅប្រើប្រាស់ឱ្យមានប្រសិទ្ធភាព នូវធនធានដែលមានស្រាប់នៅក្នុងក្រុង ស្រុក ខណ្ឌ ទៅតាមនីតិវិធីរដ្ឋបាលដែលអាចសម្រេចការងារប្រកបដោយប្រសិទ្ធភាព និងមានរយៈពេលខ្លីជាងមុន។ ការិយាល័យច្រកចេញចូលតែមួយត្រូវអនុវត្តតាមនីតិវិធីរដ្ឋបាលដែលបានកំណត់។ ដូចនេះការិយាល័យច្រកចេញចូលតែមួយ គឺជាស្ថាប័នមួយ ដែលត្រូវតែផ្តល់ព័ត៌មានយ៉ាងច្បាស់លាស់ទៅឱ្យអ្នកប្រើប្រាស់សេវាអំពីកិច្ចការរដ្ឋបាលនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងផ្តល់ព័ត៌មានអំពីនីតិវិធីរដ្ឋបាលដែលជាសមត្ថកិច្ចរបស់ថ្នាក់ជាតិ និងថ្លៃសេវាកម្មសម្រាប់នីតិវិធីដែលពាក់ព័ន្ធទៅនឹងវិស័យសេដ្ឋកិច្ច ដីធ្លី

---

[៩] ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល, *គោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ* (ភ្នំពេញៈ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល, ២០០៦), ៣៣-៥០។

[១០] http://www.owso.gov.kh (ចូលទស្សនាថ្ងៃទី១០ មេសា ២០១៥)។

ផែនការប្រើប្រាស់ដីធ្លី រួមទាំងព័ត៌មានអំពីការគាំពារ សុខភាព ការអប់រំវប្បធម៌ និងបញ្ហាសង្គមផងដែរ។[១១]

ការិយាល័យច្រកចេញចូលតែមួយជាយន្តការនៃការផ្តល់សេវាសាធារណៈ ដែលបង្កភាពងាយស្រួលដល់អ្នកប្រើប្រាស់តាមនីតិវិធីសាមញ្ញ មានតម្លាភាព ប្រសិទ្ធភាព និងយកចិត្តទុកដាក់ចំពោះការផ្តល់យោបល់និងការចាប់អារម្មណ៍របស់អ្នកប្រើប្រាស់សេវា។ យន្តការនេះប្រមូលផ្តុំជាចង្កោមនូវសេវាសាធារណៈមួយចំនួន ឱ្យមកនៅកន្លែងតែមួយ ទាំងកន្លែងស្នើរសុំនិងកន្លែងទទួល ដោយកំណត់ពេលវេលាប្រគល់សេវា និងតម្លៃច្បាស់លាស់។

សេវាសាធារណៈច្រកចេញចូលតែមួយ គឺសំដៅលើសេវាកម្មទាំងឡាយដែលផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយដើម្បីបម្រើប្រជាជន ក្នុងគោលបំណងបម្រើដល់ប្រយោជន៍សាធារណៈឱ្យមានប្រសិទ្ធភាព ភាពសក្តិសិទ្ធ តម្លាភាព គណនេយ្យភាព រយៈពេលខ្លី ច្បាស់លាស់ អាចជឿទុកចិត្តបាន តម្លៃថោក និងប្រកបដោយគុណភាពល្អ។[១២]

### ១.២.២.ប្រវត្តិនៃការកកើតការិយាល័យច្រកចេញចូលតែមួយនៅកម្ពុជា

ការិយាល័យច្រកចេញចូលតែមួយត្រូវបានបង្កើតឡើង ជាដំបូងដោយគម្រោងសហភាពអឺរ៉ុបរួមជាមួយ AsiaUrb នៅក្រុងពីរ (សៀមរាប និងបាត់ដំបង) ពីឆ្នាំ ២០០៤ ដល់ឆ្នាំ២០០៧។ ក្រោយមកគម្រោងអភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋានក៏ត្រូវបានពង្រីកសកម្មភាព ដោយបង្កើតការិយាល័យច្រកចេញចូលតែមួយចំនួន១៥ នៅក្រុងចំនួន១៤ និងស្រុក១ ក្នុងរយៈពេលពីរឆ្នាំ (២០១០ ដល់ ២០១១) រហូតមកដល់បច្ចុប្បន្ននេះ ការិយាល័យច្រកចេញចូលតែមួយចំនួន១៧ កំពុងដំណើរការទូទាំងប្រទេស។ បទពិសោធន៍ដែលទទួលបានពីការិយាល័យច្រកចេញចូលតែមួយដែលជាកិច្ចខិតខំដំបូងរបស់កម្ពុជា ក្នុងការផ្តល់មុខងារពីថ្នាក់ជាតិទៅឱ្យថ្នាក់ក្រុង ស្រុក ខណ្ឌនិងបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការផ្តល់សេវា និងកំណែទម្រង់វិមជ្ឈការនៅកម្ពុជា។ ការវាយតម្លៃលើកដំបូង និងការស្ទង់មតិនៅក្នុងឆ្នាំ ២០១១ បានបង្ហាញពីការពេញចិត្តរបស់អតិថិជនជារួមស្មើនិង៩៣%។ ដោយឈរលើលទ្ធផលនេះ រាជរដ្ឋាភិបាលបច្ចុប្បន្នកំពុងរៀបចំបង្កើតឱ្យមានការិយាល័យច្រកចេញចូលតែមួយបន្ថែមចំនួន១១ទៀតនៅក្រុង ស្រុក និងខណ្ឌទាំងអស់នៃរាជធានីភ្នំពេញដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍។ ក្រោយមកនៅក្នុងឆ្នាំ ២០១៣ ការគាំទ្ររបស់ដៃគូ

---

[១១] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌគោលដៅ, លេខ៩២៨ ប្រក, ១២ មិនា ២០០៩, ប្រការ៣។

[១២] http://www.owso.gov.kh/?lang=kh&page_id=703 (ចូលទស្សនាថ្ងៃទី១០ មេសា ២០១៥)។

អភិវឌ្ឍន៍ទៅលើគម្រោងច្រកចេញចូលតែមួយនឹងត្រូវបានបញ្ចប់ ប៉ុន្តែរាជរដ្ឋាភិបាលនៅតែបន្តការប្ដេជ្ញាក្នុងការពង្រីកសកម្មភាពនៃការិយាល័យច្រកចេញចូលតែមួយបន្តទៀត។[១៣]

### ១.២.៣.គោលបំណងនៃការបង្កើតការិយាល័យច្រកចេញចូលតែមួយ

ការបង្កើតការិយាល័យច្រកចេញចូលមួយនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណង គឺៈ ១.លើកកម្ពស់គោលការណ៍អភិបាលកិច្ចល្អ កំណែទម្រង់ប្រព័ន្ធរដ្ឋបាលដោយពង្រីកវិសាលភាពសេវាដែលផ្ដល់ដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យបានទូលំទូលាយតាមរយៈការប្រមូលផ្ដុំសេវាទាំងអស់ក្នុងក្របខណ្ឌសមត្ថកិច្ច ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានផ្ដល់ជូនអតិថិជននៅកន្លែងតែមួយ។ ២.បង្ខិតសេវារដ្ឋបាលឱ្យនៅកៀកជិតនឹងប្រជាពលរដ្ឋ បង្កភាពងាយស្រួលសម្រួលក្នុងការផ្ដល់សេវា ជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាព គុណភាព តម្លាភាព ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ។ ៣.កែលម្អការផ្ដល់សេវាសាធារណៈ បង្កើនអភិបាលកិច្ចល្អ កាត់បន្ថយអំពើពុករលួយ និងបង្កើនការជឿទុកចិត្តពីប្រជាពលរដ្ឋលើប្រព័ន្ធរដ្ឋបាល។ ៤.លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការផ្ដល់មតិយោបល់ និងការរិះគន់ស្ថាបនាដើម្បីកែលម្អការអនុវត្តប្រព័ន្ធរដ្ឋបាល។ ៥.បង្កើនតម្លាភាពនៅក្នុងប្រព័ន្ធរដ្ឋបាលតាមរយៈការលើកកម្ពស់ឱ្យមាននូវប្រព័ន្ធផ្សព្វផ្សាយផ្សេងសម្រាប់ប្រជាពលរដ្ឋ និងដើម្បីវាស់វែងនូវការចូលរួមរបស់គាត់ក្នុងការអនុវត្តប្រព័ន្ធរដ្ឋបាល។[១៤]

### ១.២.៤.ក្រុង ស្រុក ខណ្ឌគោលដៅ

ការិយាល័យច្រកចេញចូលតែមួយបង្កើតឡើងក្នុងគោលបំណង ដើម្បីបង្ខិតសេវាសាធារណៈជូនពលរដ្ឋ ដូច្នេះការិយាល័យច្រកចេញចូលតែមួយត្រូវបានគេរៀបចំបង្កើតឡើងនៅតាមក្រុង ស្រុក ខណ្ឌគោលដៅមួយចំនួនដូចជាៈ

**ក.ឆ្នាំទី១ (២០០៩ដល់២០១០)** : ក្រុងគោលដៅចាស់ចំនួន២គឺ ក្រុងសៀមរាប និងក្រុងបាត់-ដំបង ព្រមទាំងក្រុងពង្រីកថ្មីចំនួន៧ទៀតគឺ ក្រុងប៉ោយប៉ែត ក្រុងស្ទឹងសែន ក្រុងតាខ្មៅ ក្រុងព្រះសីហនុ ក្រុងសួង ក្រុងក្រចេះ ក្រុងពាមរក៍។

**ខ.ឆ្នាំទី២ (២០១០ដល់២០១១)** : ពង្រីកបន្ថែមទៅកាន់ក្រុងចំនួន៨រួមមានៈ ក្រុងពោធិ៍សាត់ ក្រុងកំពង់ឆ្នាំង ក្រុងខេមរភូមិន្ទ ក្រុងកំពង់ស្ពឺ ក្រុងកំពត ក្រុងដូនកែវ ក្រុងបាវិត និងក្រុងបានលុង។

[១៣] Erin Thebault-Weiser និង ប៉ក់ គឹមជឿន, *របាយការណ៍ស្តីពីមេរៀន និងបទពិសោធន៍ក្នុងការអនុវត្តគម្រោងការិយាល័យច្រកចេញចូលតែមួយ* (ភ្នំពេញៈ ២០១៣), ១៤-១៧។

[១៤] ក្រសួងមហាផ្ទៃ, "នីតិវិធីនៃការអនុវត្តតួនាទី និងភារកិច្ចនៃការិយាល័យច្រកចេញចូលតែមួយ" (បទបង្ហាញនៅក្នុងវគ្គបណ្ដុះបណ្ដាលមន្ត្រីការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ, ក្រុងបាត់ដំបង, ១៥-១៦ វិច្ឆិកា ២០១២។

**គ.ឆ្នាំទី៣(២០១១ដល់២០១២) :** ពង្រីកបន្ថែមទៅក្រុង៦ និងស្រុកជនបទ១រួមមានៈ ក្រុងសំរោង ក្រុងព្រះវិហារ ក្រុងស្ទឹងត្រែង ក្រុងសែនមនោរម្យ ក្រុងកែប ក្រុងប៉ៃលិន និងស្រុកបវេល។

**ឃ.ឆ្នាំទី៤(២០១២ដល់២០១៣) :** ពង្រីកបន្ថែមទៅក្រុង៤ និងខណ្ឌ៩រួមមានៈ ក្រុងសិរីសោភ័ណ ក្រុងកំពង់ចាម ក្រុងព្រៃវែង ក្រុងស្វាយរៀង ខណ្ឌមានជ័យ ខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌសែនសុខ ខណ្ឌទួលគោក ខណ្ឌ៧មករា ខណ្ឌឫស្សីកែវ ខណ្ឌដូនពេញ និងខណ្ឌចំការមន។ ដូចនេះការិយាល័យច្រកចេញចូលតែមួយដែលស្ថិតនៅក្នុងក្រុង ស្រុក ខណ្ឌគោលដៅសរុបទាំងអស់មាន៣៧ក្រុង ស្រុក ខណ្ឌគោលដៅ។[១៥]

## ១.៣.ទីតាំង និងតួនាទី ភារកិច្ចរបស់ការិយាល័យច្រកចេញចូលតែមួយ

### ១.៣.១.ទីតាំងសមស្របក្នុងការបង្កើតការិយាល័យចេញចូលតែមួយ

ទីតាំងការិយាល័តច្រកចេញចូលតែមួយត្រូវតែរៀបចំឱ្យស្ថិតនៅកន្លែងណា ដែលសាធារណៈជនអាចប្រាស្រ័យទាក់ទងបានងាយស្រួល ហើយទីតាំងនេះត្រូវតែរៀបចំឱ្យមានបរិយាកាសល្អ និងសម្ភារ ឧបករណ៍ សមស្របសម្រាប់សាធារណៈជន។ ជាងនេះទៅទៀតការិយាល័យច្រកចេញចូលតែមួយ ដែលមានលក្ខណៈពេញលេញ (ផ្នែកជួរមុខ និងផ្នែកជួរក្រោយ) គឺត្រូវស្ថិតនៅក្នុងសាលាក្រុង ស្រុក ខណ្ឌ។[១៦]

### ១.៣.២.តួនាទី និងភារកិច្ចរបស់ការិយាល័យច្រកចេញចូលតែមួយ

គ្រប់ការិយាល័យច្រកចេញចូលតែមួយមានតួនាទី និងភារកិច្ចដូចខាងក្រោមៈ -ផ្តល់សេវាកម្មដល់អតិថិជនពលរដ្ឋ សហគ្រាស និងអង្គការទាំងឡាយដែលកំពុងធ្វើសកម្មភាពនៅមូលដ្ឋានក្រុង ស្រុក ខណ្ឌ។ -ផ្តល់ព័ត៌មានពិស្តារ និងព័ត៌មានទូទៅជូនប្រជាពលរដ្ឋ និងអតិថិជននានាក្នុងស្រុក អំពីកិច្ចការរដ្ឋបាលនៅថ្នាក់ខេត្ត ស្រុក ឃុំ (ដោយផ្ទាល់មាត់ ឬតាមទូរស័ព្ទ ឬតាមសៀវភៅព័ត៌មាននានាដែលបានបោះពុម្ពផ្សាយ)។ -ផ្តល់ព័ត៌មានអំពីនីតិវិធីរដ្ឋបាលដែលជាសមត្ថកិច្ចរបស់ថ្នាក់ជាតិ និងថ្លៃសេវាកម្មសម្រាប់នីតិវិធីទាំងនេះ ដែលពាក់ព័ន្ធនិងវិស័យសេដ្ឋកិច្ច ដីធ្លី ផែនការប្រើប្រាស់ដីធ្លី រួមទាំងព័ត៌មានអំពីការគាំពារសុខភាព ការអប់រំ វប្បធម៌ និងបញ្ហាសង្គមផងដែរ។[១៧]

---

[១៥] ក្រសួងមហាផ្ទៃ, "គម្រោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ" (បទបង្ហាញនៅក្នុងវគ្គបណ្តុះបណ្តាលមន្ត្រីការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ, ក្រុងបាត់ដំបង, ១៤-១៦ វិច្ឆិកា ២០១២)។

[១៦] ក្រសួងមហាផ្ទៃ, "គម្រោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ" (បទបង្ហាញនៅក្នុងវគ្គបណ្តុះបណ្តាលមន្ត្រីការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ, ក្រុងបាត់ដំបង, ១៤-១៦ វិច្ឆិកា ២០១២) ។

[១៧] ក្រុមគាំទ្រក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃ, ចងក្រង, ការិយាល័យច្រកចេញចូលតែមួយ (ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១០), ១៣។

# ជំពូកទី២
# ទិដ្ឋភាពទូទៅនៃការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ

## ២.១.ស្ថានភាពទីតាំងនៃការិយាល័យច្រកចេញចូលតែមួយនៃខណ្ឌច្បារអំពៅ

### ២.១.១.ភូមិសាស្ត្រ

ខណ្ឌច្បារអំពៅជាខណ្ឌមួយដែលទើបតែបង្កើតឡើងនៅចុងឆ្នាំ ២០១៣ ដោយយោងតាមអនុក្រឹត្យលេខ ៥៧៩ អនក្រ.កប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា។ ខណ្ឌនេះមានទីតាំងស្ថិតនៅខាងត្បូងឈៀងខាងកើតនៃសាលារាជធានីភ្នំពេញ។ ខណ្ឌច្បារអំពៅមានសង្កាត់ចំនួន ០៨ គឺសង្កាត់ច្បារអំពៅទី១ សង្កាត់ច្បារអំពៅទី២ សង្កាត់និរោធ សង្កាត់ព្រែកប្រា សង្កាត់វាលស្បូវ សង្កាត់ព្រែកឯង សង្កាត់ក្បាលកោះ និងសង្កាត់ព្រែកថ្មី។ ខណ្ឌច្បារអំពៅមានព្រំប្រទល់រដ្ឋបាលខាងជើងទល់នឹងស្រុកល្វាឯម ខាងត្បូងទល់នឹងស្រុកកៀនស្វាយ ខាងកើតទល់នឹងស្រុកកៀនស្វាយ និងស្រុកល្វាឯមខេត្តកណ្ដាល ខាងលិចទល់នឹងខណ្ឌមានជ័យរាជធានីភ្នំពេញ។ ខណ្ឌនេះមានផ្ទៃក្រឡាសរុប ៨០,៩៥ គីឡូម៉ែត្រក្រឡា ចែកជា០៨សង្កាត់ មាន៤៩ភូមិ។[១៨]

### ២.១.២.ប្រជាពលរដ្ឋ

ខណ្ឌច្បារអំពៅជាខណ្ឌមួយដែលទើបតែបង្កើតឡើងថ្មី ដោយខណ្ឌនេះបានកាត់យកសង្កាត់ចំនួន ០៨ ពីខណ្ឌមានជ័យនៃរាជធានីភ្នំពេញ។ ខណ្ឌច្បារអំពៅមានប្រជាជនរស់នៅសរុបចំនួន ១៣២,២២៩នាក់ ក្នុងនោះស្រីមានចំនួន ៦៧,៧៤៩នាក់ ហើយចែកចេញជា ២៦,៧៧៣គ្រួសារ។[១៩]

## ២.២.ការបង្កើតការិយាល័យច្រកចេញចូលតែមួយនៅខណ្ឌច្បារអំពៅ

បន្ទាប់ពីខណ្ឌច្បារអំពៅត្រូវបានបង្កើតឡើងដោយយោងតាមអនុក្រឹត្យលេខ ៥៧៩ អនក្រ.កប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជារួចមក។ ការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅក៏ត្រូវបានបង្កើតឡើងផងដែរដោយយោងតាមសេចក្ដីសម្រេចលេខ ២៣០៧ សសរ ស្ដីពីការផ្ទេរការិយាល័យច្រកចេញចូល និងការិយាល័យប្រជាពលរដ្ឋពីរចនាសម្ព័ន្ធសាលាខណ្ឌមានជ័យ ទៅរចនាសម្ព័ន្ធសាលាខណ្ឌច្បារអំពៅ។[២០]

[១៨] សាលាខណ្ឌច្បារអំពៅ, *របាយការណ៍បូកសរុបលទ្ធផលការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិសង្កាត់ មានសុវត្ថិភាព" នៅក្នុងខណ្ឌច្បារអំពៅ*, លេខ០៥២ របក.ចអព.អណ២ (ភ្នំពេញ៖ សាលាខណ្ឌច្បារអំពៅ, ២៨ ឧសភា ២០១៥), ១។

[១៩] ប៉ា សុជាតិវង្ស, *តារាងស្ថិតិប្រជាពលរដ្ឋរាជធានីភ្នំពេញ,* គ្មានលេខ (ភ្នំពេញ៖ សាលារាជធានីភ្នំពេញ, ១៣ កុម្ភៈ ២០១៥)។

[២០] សេចក្ដីសម្រេចស្ដីពីការផ្ទេរការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋពីរចនាសម្ព័ន្ធសាលាខណ្ឌមានជ័យ ទៅរចនាសម្ព័ន្ធសាលាខណ្ឌច្បារអំពៅ, ២៣០៧សសរ, ១៧ មិថុនា ២០១៤។

## ២.៣.ប្រភេទវិស័យរបស់សេវាសាធារណៈនៃការិយាល័យច្រកចេញចូលតែមួយ

រាជរដ្ឋាភិបាលបានធ្វើការរៀបចំប្រព័ន្ធរដ្ឋបាលសាជាថ្មី ដោយធ្វើការកែទម្រង់យ៉ាងស៊ីជម្រៅលើប្រព័ន្ធរដ្ឋបាលសាធារណៈដោយអនុវត្តប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការដើម្បីបង្វិតសេវាសាធារណៈឱ្យទៅជិតប្រជាពលរដ្ឋ។ ដូច្នេះហើយក្រសួងស្ថាប័នដែលពាក់ព័ន្ធក៏បានធ្វើប្រតិភូកម្មការងារមួយចំនួនទៅឱ្យថ្នាក់ក្រោមជាតិ ជាពិសេសការិយាល័យច្រកចេញចូលតែមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋងាយស្រួលទទួលយកសេវាទៅប្រើប្រាស់។ ការិយាល័យច្រកចេញចូលតែមួយបានផ្តល់សេវាលើវិស័យមួយចំនួនៈ ១.ការងារនីត្យានុកូលកម្ម (ការបញ្ជាក់លើឯកសារថតចម្លង) ២.ការងារអត្រានុកូលដ្ឋាន ៣.វិស័យវប្បធម៌ និងវិចិត្រសិល្បៈ ៤.វិស័យអប់រំ យុវជន និងកីឡា ៥.វិស័យទេសចរណ៍ ៦.វិស័យសំណង់ ៧.វិស័យឧស្សាហកម្ម រ៉ែនិងថាមពល ៨.វិស័យពាណិជ្ជកម្ម ៩.វិស័យសុខាភិបាល ១០.វិស័យសាធារណៈការនិងដឹកជញ្ជូន ១១.វិស័យកសិកម្ម។[២១]

## ២.៤.រចនាសម្ព័ន្ធនៅក្នុងការិយាល័យច្រកចេញចូលតែមួយ




ដោយយោងតាមដីកាលេខ ១៩៤ ដក.គធម ស្តីពីការតែងតាំងមន្ត្រីការិយាល័យច្រកចេញចូលតែមួយរបស់សាលាខណ្ឌមានជ័យ ចុះថ្ងៃទី១៣ កុម្ភៈ ឆ្នាំ២០១៤ បានបង្ហាញថាមន្ត្រីរាជការដែលបម្រើការងារនៅការិយាល័យច្រកចេញចូលតែមួយមានចំនួន១៦រូប ដែលមានសមាសភាពដូចខាងក្រោមៈ

[២១] សេចក្តីជូនដំណឹងស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលខណ្ឌច្បារអំពៅ, ០២១សជណ.ចអព.អណ២, ៣ តុលា ២០១៤។

១.លោក យី ធីរ៉ាត ជាប្រធាន

២.លោកស្រី ខៀវ សុភាវី អនុប្រធាន

**ក.មន្ត្រីជួរមុខ**

៣.លោក ស៊ុន សុខាល័យ មន្ត្រីទទួលបន្ទុកបេឡា

៤.លោកស្រី វង វណ្ណា មន្ត្រីទទួលបន្ទុកប្រគល់ឯកសារ និងផ្តល់ព័តមាន

៥.លោក ឈាង រ៉ាវិន មន្ត្រីទទួលបន្ទុកការងារនីត្យានុកូលកម្ម

៦.លោក អ៊ូស ទ្រាស មន្ត្រីទទួលបន្ទុកការងារនីត្យានុកូលកម្ម

៧.លោក ហ៊ីង ហំ មន្ត្រីជំនួយការប្រធានការិយាល័យប្រជាពលរដ្ឋ

**ខ.មន្ត្រីជួរក្រោយ**

៨.លោក ស៊ឹម នី មន្ត្រីទទួលបន្ទុកពាណិជ្ជកម្ម

៩.លោក ជិន លី មន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ

១០.លោក បែន ថានិត មន្ត្រីទទួលបន្ទុកទេសចរណ៍

១១.លោក ខេង គឹមសាន មន្ត្រីទទួលបន្ទុកឧស្សាហាកម្ម រ៉ែ និងថាមពល

១២.លោក ជា វង្សចិន្តា មន្ត្រីទទួលបន្ទុកកិច្ចការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

១៣.លោក ឡាយ ជ មន្ត្រីទទួលបន្ទុកសាធារណៈការនិងដឹកជញ្ជូន

១៤.លោក គឹម សុខុម មន្ត្រីទទួលបន្ទុកអប់រំយុវជន និងកីឡា

១៥.លោក លាប ខេមុនី មន្ត្រីទទួលបន្ទុកសុខាភិបាល

១៦.លោក សេង តារាវិទ្ធ មន្ត្រីទទួលបន្ទុកកសិកម្ម

ប៉ុន្តែដោយយោងតាមសេចក្តីសម្រេចលេខ ២៣០៧ សសរ ស្តីពីការផ្ទេរការិយាល័យច្រកចេញចូលតែមួយ និង ការិយាល័យប្រជាពលរដ្ឋពីរចនាសម្ព័ន្ធសាលាខណ្ឌមានជ័យទៅរចនាសម្ព័ន្ធសាលាខណ្ឌច្បារអំពៅ ចុះថ្ងៃទី១៧ មិថុនា ឆ្នាំ២០១៤ រចនាសម្ព័ន្ធនៃការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋរបស់សាលាខណ្ឌមានជ័យត្រូវផ្ទេរទៅឱ្យស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់សាលាខណ្ឌច្បារអំពៅវិញ ដូច្នេះហើយទើបធ្វើឱ្យរចនាសម្ព័ន្ធរបស់មន្ត្រីរាជការមានការប្រែប្រួល។ ដោយសារតែបុគ្គលិកមួយចំនួននៅក្នុងការិយាល័យច្រកចេញចូលតែមួយរបស់សាលាខណ្ឌច្បារអំពៅបានផ្ទេរទៅតាមសាលាខណ្ឌចាស់វិញ។[២២]

[២២] ដីកាស្តីពីការតែងតាំងមន្ត្រីការិយាល័យច្រកចេញចូលតែមួយរបស់សាលាខណ្ឌមានជ័យ, ១៤៤ដក.គធម, ១៣ កុម្ភៈ ២០១៤។

### ២.៤.១.ផ្នែកជួរមុខ

ផ្នែកជួរមុខ គឺជាផ្នែកដែលត្រូវធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នកប្រើប្រាស់សេវា។ ដើម្បីឱ្យផ្នែកជួរមុខមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាជូនអ្នកប្រើប្រាស់សេវា មន្ត្រីរាជការ ឬភ្នាក់ងារដែលបម្រើការងារនៅក្នុងផ្នែកនេះត្រូវតែយល់ដឹងជារួម និងតាមវិស័យជំនាញនូវសេវាសាធារណៈនោះ និងត្រូវមានអាកប្បកិរិយាល្អ យកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការនិងជួយបំភ្លឺចម្ងល់ផ្សេងៗទៅអ្នកប្រើប្រាស់សេវា។ ផ្នែកជួរមុខមានភារកិច្ចផ្តល់ព័ត៌មាន ពន្យល់អំពីនីតិវិធីនៃការទទួលសេវា បញ្ជូន និងការបែងចែកសំនុំឯកសារទៅតាមវិស័យជំនាញ ទទួលប្រាក់កម្រៃសេវា ព្រមទាំងផ្តល់លទ្ធផល និងសេចក្តីសម្រេចពាក់ព័ន្ធនឹងការស្នើសុំសេវា ទៅអ្នកប្រើប្រាស់សេវាវិញ។ ក្នុងករណីចាំបាច់ត្រូវផ្តល់ការណែនាំបន្ថែមនិងជួយសម្រួលដល់ការបំពេញបែបបទ និងការទទួលពាក្យស្នើសុំពីអ្នកប្រើប្រាស់សេវាទាំងឡាយណា ដែលពុំមានការយល់ដឹងច្បាស់លាស់ដូចជាករណីអ្នកមិនចេះអក្សរជាដើម។ ចំពោះផ្នែកជួរមុខនៃការិយាល័យច្រកចេញចូលតែមួយ គឺជាផ្នែកសំខាន់ដែលប្រជាពលរដ្ឋមកប្រាស្រ័យទាក់ទងដោយផ្ទាល់ក្នុងការទទួលយកសេវាពីការិយាល័យ។ ផ្នែកជួរមុខត្រូវបានគេបែងចែកជាបីក្រុមតូចៗបន្តទៀត គឺក្រុមទី១ទទួលបន្ទុកទទួលពាក្យ ប្រគល់ឯកសារ និងផ្តល់ព័ត៌មាន ក្រុមទី២ទទួលបន្ទុកការងារនីត្យានុកូលកម្ម និងក្រុមទី៣ទទួលបន្ទុកការងារបេឡា។

**ក្រុមទី១៖ ក្រុមទទួលពាក្យ ប្រគល់ឯកសារ និងផ្តល់ព័ត៌មាន**

ក្រុមនេះមានភារកិច្ចបម្រើជួរមុខ ដោយទទួលបន្ទុកទទួលឯកសារប្រគល់ឯកសារ និងផ្តល់ព័ត៌មាន បន្ទាប់មកទៀតគាត់មានភារកិច្ចផ្សេងទៀតដូចជា ធ្វើការត្រួតពិនិត្យរាល់ពាក្យស្នើសុំ និងឯកសារភ្ជាប់ផ្សេងៗ ដែលបានទទួលក្នុងករណីសំណុំបែបបទគ្រប់គ្រាន់ ត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអតិថិជន ហើយត្រូវបែងចែកពាក្យស្នើសុំទៅជួរក្រោយតាមវិស័យជំនាញនីមួយៗ។ បន្ថែមពីនេះក្រុមទី១នេះមានភារកិច្ចក្នុងការឆ្លើយតបរាល់ព័ត៌មាន និង ចម្ងល់របស់ប្រជាពលរដ្ឋព្រមទាំងផ្សព្វផ្សាយលិខិតជូនដំណឹង និងលិខិតបទដ្ឋានផ្សេងៗដល់អតិថិជន។ ជាចុងក្រោយគឺត្រូវធ្វើរបាយការណ៍ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ និងភារកិច្ចផ្សេងទៀតដែលប្រធានការិយាល័យច្រកចេញចូលតែមួយនៃខណ្ឌច្បារអំពៅប្រគល់ឱ្យ។

**ក្រុមទី២៖ ក្រុមទទួលបន្ទុកការងារនីត្យានុកូលកម្ម**

ក្រុមទី២មានភារកិច្ចបម្រើការជួរមុខ ទទួលបន្ទុកការងារនីត្យានុកូលកម្មលើឯកសារ និងពិនិត្យលើសំណុំឯកសារនានា ដែលត្រូវបានស្នើសុំធ្វើសេចក្តីបញ្ជាក់ពីរដ្ឋបាលលើឯកសារថតចម្លងនានាតាមគោលការណ៍កំណត់។ ក្រុមនេះលើកយោបល់ជូនប្រធានការិយាល័យច្រកចេញចូលតែមួយ

អំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងការងារនីត្យានុកូលកម្ម។ ចំពោះបញ្ហាទំនាក់ទំនងវិញក្រុមទី២នេះធ្វើទំនាក់ទំនងជាមួយមន្ទីរអង្គភាពពាក់ព័ន្ធនានា ដើម្បីស្វែងរកមូលដ្ឋានផ្លូវច្បាប់ពាក់ព័ន្ធនឹងកិច្ចការនីត្យានុកូលកម្ម និងធ្វើទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋដោយជូនព័ត៌មាននឹងឆ្លើយតបទៅនឹងសំណើរបស់ប្រជាពលរដ្ឋចំពោះកិច្ចការដែលខ្លួនទទួលខុសត្រូវ។ ក្រុមនេះត្រូវធ្វើរបាយការណ៍ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំហើយត្រូវបំពេញភារកិច្ចទៅតាមអ្វីដែលប្រធានការិយាល័យច្រកចេញចូលតែមួយប្រគល់ឱ្យ។ បន្ថែមពីនោះក្រុមនេះជាអ្នករក្សាទុកនូវឯកសារនានាដែលបានធ្វើសេចក្តីបញ្ជាក់ជូនពលរដ្ឋរួចហើយ។

ក្រុមទី២ ដែលជាក្រុមនីត្យានុកូលកម្មនៅការិយាល័យច្រកចេញចូលតែមួយបានផ្តល់សេវាកម្មលើប្រភេទសេវាកម្មឯកសារមួយចំនួនដូចជា: វិញ្ញាបនបត្របញ្ជាក់ការសិក្សា វិញ្ញាបនបត្របណ្តោះ-អាសន្នមធ្យមសិក្សាកម្រិត១ វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាកម្រិត២ វិញ្ញាបនបត្រ-បណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ វិញ្ញាបនបត្របញ្ជាក់ការសិក្សាថ្នាក់ទី១២ វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម វិញ្ញាបនបត្រប្រកបអាជីវកម្ម វិញ្ញាបនបត្រ លិខិតបញ្ជាក់លទ្ធផលនៃការប្រលងសញ្ញាបត្រមធ្យមសិក្សាកម្រិត១ សញ្ញាបត្រមធ្យមសិក្សាកម្រិត២ (បំពេញវិជ្ជា) សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញាបត្រមធ្យមសិក្សាគរុកោសល្យ សញ្ញាបត្រមធ្យមសិក្សា សញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម ព្រឹត្តិបត្រលទ្ធផលប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បរិញ្ញាបត្រ បរិញ្ញាបត្ររង លិខិតបញ្ជាក់ការសិក្សា អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ ប័ណ្ណសំគាល់យានយន្ត ព្រឹត្តិបត្រពិន្ទុ ពាក្យសុំបញ្ជាក់សញ្ញាបត្រមធ្យមសិក្សាកម្រិត២ ចំណេះដឹងទូទៅ វិញ្ញាបនបត្របណ្តោះអាសន្នថ្នាក់បរិញ្ញាបត្រ វិញ្ញាបនបត្របណ្តោះអាសន្នថ្នាក់បរិញ្ញាបត្ររង។

**ក្រុមទី៣៖ ក្រុមទទួលបន្ទុកការងារបេឡា**

ក្រុមទី៣មានភារកិច្ចទទួលកំរៃសេវាកម្មរដ្ឋបាលតាមគោលការណ៍កំណត់ និងចេញបង្កាន់ដៃបង់ប្រាក់ជូនអតិថិជនព្រមទាំងធ្វើរបាយការណ៍ប្រចាំថ្ងៃអំពីស្ថានភាពថវិកា របាយការណ៍ប្រចាំសប្តាហ៍ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំព្រមទាំងភារកិច្ចផ្សេងៗទៀតដែលប្រធានការិយាល័យច្រកចេញចូលតែមួយប្រគល់ឱ្យ។

បន្ទាប់ពីបំពេញលក្ខខណ្ឌទាំងឡាយ ដែលបានកំណត់ក្នុងជួរមុខនៅពេល ដែលខ្លួនពិនិត្យឃើញថាត្រឹមត្រូវហើយនោះ ត្រូវបញ្ជូនសំណុំឯកសារ ពាក្យសុំបន្តទៅជួរក្រោយ។[២៣]

---

[២៣] ក្រសួងមហាផ្ទៃ, *ការិយាល័យច្រកចេញចូលតែមួយ* (ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១៣), ១០-១២។

### ២.៤.២.ផ្នែកជួរក្រោយ

ផ្នែកជួរក្រោយ ជាផ្នែកដែលទទួលរ៉ាប់រងសេវា ហើយជាផ្នែកមួយមាននីតិវិធីរដ្ឋបាលស្មុគស្មាញ និងស៊ាំញ៉ាំ ឬជាផ្នែកមួយដែលមាននីតិវិធីរដ្ឋបាលដែលត្រូវការពេវេលាដើម្បីត្រួតពិនិត្យបច្ចេកទេស និងត្រូវសម្រេចបញ្ចប់ដោយផ្នែកជួរក្រោយ ឬតម្រូវឱ្យសេវានោះត្រូវសម្រេច ឬបញ្ចប់ដោយសហការរវាងការិយាល័យច្រកចេញចូលតែមួយ ជាមួយអង្គភាពការិយាល័យជំនាញនានានៃរដ្ឋបាលខណ្ឌក្នុងរយៈពេលមួយកំណត់។

ចំពោះផ្នែកជួរក្រោយត្រូវបានគេបែងចែកជា១០ផ្នែកគឺ ផ្នែកពាណិជ្ជកម្ម ផ្នែកវប្បធម៌ និងវិចិត្រសិល្បៈ ផ្នែកទេសចរណ៍ ផ្នែករៀបចំដែនដីនិងនគរូបនីយកម្ម និងសំណង់ ផ្នែកឧស្សាហកម្ម រ៉ែ និងថាមពល ផ្នែកសាធារណៈការនិងដឹកជញ្ជូន ផ្នែកអប់រំ យុវជន និងកីឡា ផ្នែកអគ្រានុកូលដ្ឋាន ផ្នែកសុខាភិបាល និងផ្នែកកសិកម្ម។

#### ១.ផ្នែកសាធារណៈការនិងដឹកជញ្ជូន

ផ្នែកនេះទទួលបន្ទុកក្នុងការផ្តល់សេវាកម្មទៅលើម៉ូតូ (ការចុះបញ្ជីថ្មី ប្តូរបណ្ណសំគាល់ ទុតិយាតាប័ណ្ណសំគាល់ តតិយតាប័ណ្ណសំគាល់ ទុតិយាតាស្លាកលេខ តតិយតាស្លាកលេខ និងផ្ទេរកម្មសិទ្ធិដែលសេវាទាំងនេះមានរយៈពេលនៃការផ្តល់៣០ថ្ងៃ សុពលភាពអចិន្ត្រៃយ៍ ប៉ុន្តែតម្លៃនៃសេវាប្រែប្រួលទៅតាមប្រភេទនៃសេវាកម្មនីមួយៗ) សេវាកម្មទៅលើការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន (ត្រីចក្រយានយន្ត រ៉ឺម៉កសណ្តោងដោយទោចក្រយានយន្ត ដែលសេវាកម្មទាំងពីរមានតម្លៃរយៈពេលនៃការផ្តល់ និងសុពលភាពដូចគ្នា) និងសេវាកម្មបន្តលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន (ត្រីចក្រយានយន្ត រ៉ឺម៉កសណ្តោងដោយទោចក្រយានយន្ត ដែលសេវាកម្មទាំងពីរមានតម្លៃរយៈពេលនៃការផ្តល់ និងសុពលភាពដូចគ្នា)។

#### ២.ផ្នែករៀបចំដែនដី នគរូបនីយកម្មនិងសំណង់

ផ្នែកនេះទទួលបន្ទុកក្នុងការផ្តល់សេវាកម្មដូចជាលិខិតអនុញ្ញាតឱ្យសាងសង់ លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល (តម្លៃស្មើនឹង១០% នៃតម្លៃលិខិតអនុញ្ញាត) លិខិតអនុញ្ញាតបើកការដ្ឋាន (តម្លៃស្មើនឹង១០%នៃតម្លៃលិខិតអនុញ្ញាត) លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ(តម្លៃស្មើនឹង១០% នៃតម្លៃលិខិតអនុញ្ញាត) សេវាកម្ម ជួសជុល និងសង់របង ព្រមទាំងផ្តល់សេវាកម្មលើការបញ្ជាក់ការផ្ទេរសិទ្ធិកាន់កាប់ ឬលក់ផ្តាច់ ឬអំណោយ ឬមរតកអចលនវត្ថុសម្រាប់បំពេញបែបបទ ចំពោះដី លំនៅស្ថាន ភូមិគ្រឹះ ដែលពុំទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុ។ សេវាកម្មដែលផ្តល់ឱ្យដោយផ្នែកមួយនេះកំណត់តម្លៃ និងរយៈពេលនៃការផ្តល់អាស្រ័យទៅលើទីតាំង ទំហំ ដែលសំណង់ស្ថិតនៅ។

**៣.ផ្នែកអប់រំ យុវជន និងកីឡា**

ផ្នែកនេះទទួលបន្ទុកក្នុងការផ្តល់សេវាកម្មដូចជា សាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជន (កម្មវិធីជាតិ) សាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជន (កម្មវិធីអន្តរជាតិ) ថ្នាក់បណ្តុះបណ្តាលជំនាញ និងភាសាបរទេសវគ្គខ្លីៗ តិចជាង១ឆ្នាំ បង្កើតក្លឹបហាត់ប្រាណ អាជីវកម្មលក់សម្ភារៈកីឡា ហើយក្នុងនោះក៏ត្រូវផ្តល់សេវាកម្មការធ្វើសុពលភាពឡើងវិញផងដែរ។ ប្រភេទនៃសេវាកម្មដែលផ្តល់ដោយផ្នែកនេះមាន រយៈពេលនៃការផ្តល់ដូចគ្នាប៉ុន្តែមានសុពលភាពនិងតម្លៃខុសគ្នាទៅតាមប្រភេទនៃសេវា។

**៤.ផ្នែកសុខាភិបាល**

ផ្នែកនេះទទួលបន្ទុកក្នុងការផ្តល់សេវាកម្មដូចជា បន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះ បន្ទប់ព្យាបាលដោយចលនា បន្ទប់ថែទាំជំងឺ ឱសថស្ថានរង ទៅលើការស្នើសុំបើក ការបន្តសុពលភាព និងការប្តូរទីតាំង។ សេវាកម្មដែលផ្តល់ឱ្យដោយផ្នែកសុខាភិបាលមានតម្លៃសេវា រយៈពេលផ្តល់ និងសុពលភាពខុសគ្នាទៅតាមប្រភេទនៃសេវាដែលផ្តល់ឱ្យ។

**៥.ផ្នែកឧស្សាហកម្ម រ៉ែ និងថាមពល**

ផ្នែកនេះទទួលបន្ទុកក្នុងការផ្តល់សេវាកម្មដូចជា សហគ្រាសសិប្បកម្ម ( កែច្នៃក្រណាត់ ស្បែក កៅស៊ូ ប្លាស្ទិច កែច្នៃស័ង្កសី អាលុយមីញ៉ូម ដែកកញ្ចក់ កែច្នៃរតនវត្ថុ ផលិតជើងតាំង ពាង ល្វ ឥដ្ឋ ការ៉ូ ធ្វើទៀន ធូប) សេវាកម្មថាមពល ( ដំឡើងម៉ាស៊ីនអគ្គិសនីសម្រាប់ធ្វើសេវាកម្មបញ្ចូល អាគុយដែលមានកម្លាំងមិនលើសពី២៥គីឡូវ៉ាត់) ព្រមទាំងការផ្តល់សេវាកម្មផ្សេងទៀតដូចជា ជួសជុលគ្រឿងអគ្គិសនីអេឡិចត្រូនិច លាងរថយន្ត និងលាងម៉ូតូ។ សេវាកម្មដែលផ្តល់ឱ្យដោយផ្នែកឧស្សាហកម្ម រ៉ែ និងថាមពលមានតម្លៃសេវា រយៈពេលផ្តល់ និងសុពលភាពខុសគ្នាទៅតាមប្រភេទនៃសេវាដែលផ្តល់ឱ្យ។ ប៉ុន្តែដោយសារតែបច្ចុប្បន្នក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវបានគេបំបែកជាពីរគឺ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងរ៉ែ និងថាមពលទើបផ្នែកឧស្សាហកម្ម រ៉ែ និងថាមពល ដែលជាសេវានៅក្នុងការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅត្រូវបានគេបំបែកជាពីរ គឺផ្នែកឧស្សាហកម្មនិងសិប្បកម្ម និងផ្នែករ៉ែ និងថាមពល។បើទោះជាផ្នែកនេះត្រូវបានគេបំបែកក៏ដោយ តែរាល់សេវាដែលផ្តល់ឱ្យដោយផ្នែកទាំងពីរនេះនៅតែផ្នែកឧស្សាហកម្មជាផ្តល់ដដែល។

**៦.ផ្នែកកសិកម្ម**

ផ្នែកនេះទទួលបន្ទុកក្នុងការផ្តល់សេវាកម្មដូចជា លិខិតអនុញ្ញាតធ្វើអាជីវកម្ម លក់ដុំ រាយសម្ភារកសិកម្ម(រយៈពេលនៃការផ្តល់០៧ថ្ងៃ សុពលភាព១ឆ្នាំ) និងសេវាកម្មលើការផ្តល់វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលដែលមានដើមកំណើតពីសត្វ(រយៈពេលនៃការផ្តល់០២ថ្ងៃ សុពលភាព

២ថ្ងៃ)។ រាល់ប្រភេទនៃសេវាដែលបានផ្តល់ឱ្យដោយផ្នែកនេះគឺមានតម្លៃខុសគ្នា ដោយអាស្រ័យទៅតាមចម្ងាយជិត ឆ្ងាយ ឬមធ្យម។

**៧.ផ្នែកវប្បធម៌ និងវិចិត្រសិល្បៈ**

ផ្នែកនេះទទួលបន្ទុកក្នុងការផ្តល់សេវាកម្មដូចជា ការបញ្ចាំងភាពយន្តឬវីដេអូ (ការបញ្ចាំងភាពយន្ត ឬវីដេអូផ្សាយពាណិជ្ជកម្ម ការបញ្ចាំងភាពយន្ត ឬវីដេអូកំដរពិធីបុណ្យផ្សេងៗ ការបញ្ចាំងភាពយន្ត ឬវីដេអូកំដរភ្ញៀវ) អាជីវកម្មលក់ដូរជួលស្នាដៃភាពយន្តវីដេអូ (ហាងលក់ ជួលស៊ីឌី វីស៊ីឌី ឌីវីឌី) ស្លាកសញ្ញាអាជីវកម្ម (ផ្ទាំងយីហោគ្រប់ប្រភេទទំហំក្រោម២m² ផ្ទាំងយីហោគ្រប់ប្រភេទទំហំចាប់ពី២m² ដល់៤m² ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្ម ផ្ទាំងរូបភាពនិមិត្តសញ្ញាផ្សេងៗទំហំក្រោម២m² ផ្ទាំងរូបភាពនិមិត្តសញ្ញាផ្សេងៗទំហំចាប់ពី២m²ទៅ៤m² បដាផ្សាយពាណិជ្ជកម្ម) អាជីវកម្មគ្រឿងបំពងសំលេង (ជួលជុលធុងបាស និងឧគ្ឃោសនសព្ទ) អាជីវកម្មលក់សៀវភៅ (បណ្ណាគារ) អាជីវកម្មសិល្បៈសូនរូប (ទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ងត៍ និងជាងគំនូរ) អាជីវកម្មថតរូប (អគារថតរូបមានស្ទូឌីយូ និងផ្ទះថតរូប) អាជីវកម្មកាត់សក់ អ៊ុតសក់ លម្អក្រចក និងសំអាងការ (កាត់សក់បុរស ពី២ទៅ៤កៅអី, ចាប់ពី៥កៅអីឡើងទៅ, អ៊ុតសក់ កាត់សក់ លម្អក្រចកចាប់ពី២ទៅ៤កៅអី, ចាប់ពី៥កៅអីឡើងទៅ សំអាងការតម្លៃក្រោម៥០០$,តម្លៃចាប់ពី៥០០ដល់ក្រោម១០០០$) និងកម្មវិធីសំដែងផ្សេងៗ (ការប្រគុំតន្ត្រីនៅទីសាធារណៈ ការសំដែងទស្សនីយ៍ភាពល្ខោនលក់សំបុត្រ និងអាជីវកម្មរាំកំសាន្ត)។ រាល់ការផ្តល់សេវាកម្មនៅក្នុងផ្នែកនេះគឺមានរយៈពេលនៃការផ្តល់ដូចគ្នា តែតម្លៃសេវាផ្សេងគ្នានិងសុពលភាពផ្សេងគ្នាអាស្រ័យទៅតាមប្រភេទនៃសេវាដែលផ្តល់ឱ្យ។

**៨.ផ្នែកពាណិជ្ជកម្ម**

ការិយាល័យច្រកចេញចូលតែមួយនៃខណ្ឌច្បារអំពៅទទួលបន្ទុក ក្នុងការចេញលិខិតអនុញ្ញាតធ្វើអាជីកម្ម សេវាកម្មពាណិជ្ជកម្ម ដោយមានរយៈពេលផ្តល់ចេញលិខិតចំនួន ០៧ថ្ងៃ តម្លៃសេវាចំនួន ២៥,០០០រៀល និងមានសុពលភាពរយៈពេល១ឆ្នាំ។

**៩.ផ្នែកការងារអត្រានុកូលដ្ឋាន**

ផ្នែកនេះទទួលបន្ទុកក្នុងការផ្តល់សេវាកម្មទៅលើ ការធ្វើសេចក្តីចំលង សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ និងសេចក្តីចម្លងសំបុត្រមរណៈភាព ឬសំបុត្របញ្ជាក់មរណៈភាព។ ដោយសេវាកម្មដែលផ្តល់ឱ្យដោយផ្នែកការងារអត្រានុកូលដ្ឋានមានតម្លៃសេវា រយៈពេលផ្តល់ និងសុពលដូចគ្នាលើគ្រប់ប្រភេទនៃសេវាដែលផ្តល់ឱ្យ។

**១០.ផ្នែកទេសចរណ៍**

ផ្នែកនេះទទួលបន្ទុកក្នុងការផ្តល់សេវាកម្មដូចជា ផ្ទះសំណាក់ចាប់ពី ០៨បន្ទប់ចុះក្រោម(គិតក្នុង ០១បន្ទប់) ផ្ទះជួលបន្ទប់ស្នាក់នៅ(គិតក្នុង ០១បន្ទប់) ភោជនីយដ្ឋានទេសចរណ៍ចាប់ពី៥០នាក់ចុះក្រោម អាហារដ្ឋាន តូបលក់អាហារ ហាងលក់គុយទាវកាហ្វេ ម៉ាស្សាចាប់ពី០៥គ្រែ ឬចាប់ពី០៥កៅអីចុះក្រោម ខារ៉ាអូខេចាប់ពី០៥បន្ទប់ចុះក្រោម ស្ទូកយ័រចាប់ពី ០៥តុចុះក្រោម រថយន្តដឹកទេសចរណ៍ចំណុះចាប់ពី០៥កៅអីចុះក្រោម ម៉ូតូឌុបទេសចរណ៍ ម៉ូតូជួលទេសចរណ៍ រ៉ឺម៉កម៉ូតូដឹកទេសចរណ៍។ សេវាទាំងអស់នេះមានរយៈនៃការផ្តល់ចំនួន២៨ថ្ងៃដូចគ្នា សុពលភាពរយៈពេល១ឆ្នាំដូចគ្នា ប៉ុន្តែតម្លៃនៃសេវាកម្មនៅក្នុងមួយច្បាប់ៗមានការប្រែប្រួល។[២៤]

**២.៤.៣.ក្រុមសម្របសម្រួលរដ្ឋបាល**

**ក.សមាសភាព**

ក្រុមសម្របសម្រួលរដ្ឋបាលមានសមាសភាពដូចជា អភិបាលរងខណ្ឌទទួលបន្ទុកការិយាល័យច្រកចេញចូលតែមួយជាប្រធាន ប្រធានការិយាល័យច្រកចេញចូលតែមួយជាអនុប្រធាន និងប្រធានការិយាល័យជំនាញពាក់ព័ន្ធជាសមាជិក។ ក្រៅពីសមាសភាពខាងលើនេះ អភិបាលខណ្ឌអាចកំណត់បន្ថែមនូវចំនួនសមាជិកនៃក្រុមសម្របសម្រួលរដ្ឋបាលក្នុងករណីចាំបាច់។ ក្រុមសម្របសម្រួលរដ្ឋបាលនេះត្រូវបង្កើតដោយសេចក្តីសម្រេចរបស់អភិបាលខណ្ឌ។

**ខ.តួនាទី ភារកិច្ច**

ក្រុមសម្របសម្រួលរដ្ឋបាលមានតួនាទីភារកិច្ចដូចខាងក្រោមៈ -ទទួលរ៉ាប់រងបែងចែកសំណើ និងសំណុំលិខិតរបស់ប្រជាពលរដ្ឋ ដែលមានលក្ខណៈស្មុគស្មាញ និងមានការពាក់ព័ន្ធនឹងវិស័យជាច្រើនដោយពិបាកក្នុងការបែងចែកសមត្ថកិច្ច។ -ធានាបែងចែកសំណើ និងសំណុំលិខិតស្មុគស្មាញទាំងនោះឱ្យចំសមត្ថកិច្ច។ ករណីដែលគេពិនិត្យឃើញថាសំណើ និងសំណុំលិខិតដែលមានលក្ខណៈស្មុគស្មាញ និងមានការពាក់ព័ន្ធទៅនឹងវិស័យជាច្រើនដែលប្រធានការិយាល័យច្រកចេញចូលតែមួយពិបាកក្នុងការបែងចែកភារកិច្ចនោះ ឱ្យផ្នែកជួរក្រោយចំសមត្ថកិច្ច ប្រធានការិយាល័យច្រកចេញចូលតែមួយត្រូវដាក់សំណើ ឬសំណុំលិខិតនោះជូនអង្គប្រជុំក្រុមសម្របសម្រួលរដ្ឋបាលដើម្បីពិនិត្យ និងដោះស្រាយ។[២៥]

[២៤] ក្រសួងមហាផ្ទៃ, *ការិយាល័យច្រកចេញចូលតែមួយ* (ភ្នំពេញៈ ក្រសួងមហាផ្ទៃ, ២០១៣), ១៦-២៥។
[២៥] ក្រសួងមហាផ្ទៃ, *ការិយាល័យច្រកចេញចូលតែមួយ* (ភ្នំពេញៈ ក្រសួងមហាផ្ទៃ, ២០១៣), ២៦។

## ២.៥.ការគ្រប់គ្រងការងារនៅក្នុងការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ

ការិយាល័យច្រកចេញចូលតែមួយ ត្រូវដឹកនាំ និងសម្របសម្រួលដោយអភិបាលរងខណ្ឌ ០១រូបប្រធានការិយាល័យ ០១រូបអមដោយអនុប្រធាន ០១រូប ព្រមទាំងមន្ត្រីរាជការបុគ្គលិកទាំងអស់ទាំងផ្នែកជួរមុខ និងជួរក្រោយត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងការចាត់ចែងរបស់ប្រធានការិយាល័យច្រកចេញចូលតែមួយ។

### ២.៥.១.តួនាទីរបស់អភិបាលខណ្ឌ

អភិបាលខណ្ឌមានតួនាទីមួយចំនួន ដែលពាក់ព័ន្ធនឹងការិយាល័យច្រកចេញចូលតែមួយដូចជា -ជំរុញ ចាត់ចែង និងសម្របសម្រួលការអនុវត្តការិយាល័យច្រកចេញចូលតែមួយ។ -ធ្វើការសម្រេចចិត្ត និងចុះហត្ថលេខាលើលិខិតអនុញ្ញាតអាជ្ញាបណ្ណ។ -ជំរុញការផ្តល់សេវាជូនប្រជាពលរដ្ឋតាមការធ្វើប្រតិភូកម្មអំណាចពីក្រសួងស្ថាប័នពាក់ព័ន្ធ។ -ដោះស្រាយ សម្របសម្រួល និងឆ្លើយតបរាល់សំណូមពររបស់ប្រជាពលរដ្ឋ។ -សម្របសម្រួលជាមួយថ្នាក់ជាតិ និងសាលារាជធានីដើម្បីគាំទ្រដល់កិច្ចដំណើរការនៃការិយាល័យច្រកចេញចូលតែមួយ។ -ចាត់ចែង គ្រប់គ្រងបុគ្គលិកទាំងផ្នែកជួរមុខ និងជួរក្រោយ។ -ជំរុញសម្របសម្រួល និងទំនាក់ទំនងជាមួយអង្គភាពពាក់ព័ន្ធនានាដើម្បីគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយ។ -ជំរុញ និងដឹកនាំការចុះស្រង់ស្ថិតិអាជីវកម្មតាមមូលដ្ឋាននីមួយៗ។ -ទទួលខុសត្រូវចំពោះមុខក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធលើកិច្ចការដែលបានធ្វើប្រតិភូកម្ម។ -ដឹកនាំក្រុមសម្របសម្រួលរដ្ឋបាល ដើម្បីធ្វើការបែងចែកសំណើ និងសំណុំលិខិតរបស់ប្រជាពលរដ្ឋដែលមានលក្ខណៈសាំញ៉ាំ ស្មុគស្មាញ និងមានការពាក់ព័ន្ធនឹងវិស័យជាច្រើនដោយពិបាកក្នុងការបែងចែកសមត្ថកិច្ច។ -រៀបចំរបៀបរបបធ្វើការងាររបស់បុគ្គលិកការិយាល័យច្រកចេញចូលតែមួយ។ -ដឹកនាំរៀបចំផែនការការងារ និងផែនការថវិកាពិនិត្យ និងវាយតម្លៃអំពីចំណុចខ្លាំង ចំណុចខ្សោយដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័ត។ -ពិនិត្យ និងសម្រេចលើរបាយការណ៍ ខែ ត្រីមាស ឆមាស និងឆ្នាំជូនក្រុមគាំទ្រខណ្ឌក្រសួងមហាផ្ទៃ និងស្ថាប័នពាក់ព័ន្ធ។

### ២.៥.២.តួនាទីរបស់អភិបាលរងទទួលបន្ទុក

អភិបាលរងទទួលបន្ទុកមានតួនាទីមួយចំនួននៅក្នុងការិយាល័យច្រកចេញចូលតែមួយ ដែលតួនាទីទាំងនោះមានដូចជាៈ -ជំរុញ និងសម្របសម្រួលការអនុវត្តគម្រោងសាកល្បងការិយាល័យច្រកចេញចូលតែមួយដែល មានសមត្ថកិច្ចផ្តល់ជូនប្រជាពលរដ្ឋ និងសហគ្រាសនូវសេវាកម្មរដ្ឋបាលសាធារណៈឱ្យបានទៀងទាត់ពេលវេលា បង់កំរៃ សេវាសមស្រប មានតម្លាភាព និងតាមនីតិវិធីសាមញ្ញ ឆាប់រហ័ស បង្កលក្ខណៈងាយស្រួលប្រកបដោយគុណភាព ប្រសិទ្ធភាពតាមនីតិវិធីនិងគោលការណ៍កំណត់។ -ធានាផ្តល់សេវាកម្មជូនប្រជាពលរដ្ឋ តាមការប្រតិភូកម្មអំណាចពី

ក្រសួង ស្ថាប័នពាក់ព័ន្ធ លើវិស័យសាធារណៈការ និងដឹកជញ្ជូន វិស័យវប្បធម៌ និងវិចិត្រសិល្បៈ វិស័យទេសចរណ៍ វិស័យឧស្សាហកម្ម រ៉ែ និងថាមពល វិស័យពាណិជ្ជកម្ម វិស័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ វិស័យអប់រំ វិស័យសុខាភិបាល វិស័យកសិកម្ម និងការងារនីត្យានុកូលកម្ម ព្រមទាំងវិស័យ ប្រតិភូកម្មផ្សេងៗទៀត ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ។ -ជំរុញការស្រង់ និងធ្វើបច្ចុប្បន្នភាពទិន្នន័យដើម្បីចងក្រងបញ្ជីសេវាកម្មតាមវិស័យនីមួយៗ។ -បង្កើនការផ្សព្វផ្សាយអំពីព័ត៌មាននានា ដែលទាក់ទងនឹងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ដើម្បីឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងខណ្ឌ។ -ដឹកនាំក្រុមសម្របសម្រួលរដ្ឋបាលខណ្ឌដើម្បីធ្វើការបែងចែកសំណើ និងសំណុំលិខិតរបស់ប្រជាពលរដ្ឋ ដែលមានលក្ខណៈសាំញ៉ាំ ស្មុគស្មាញ និងពាក់ព័ន្ធនឹងវិស័យជាច្រើនដោយពិបាកក្នុងការបែងចែក សមត្ថកិច្ច។

### ២.៥.៣.តួនាទីរបស់ប្រធានការិយាល័យច្រកចេញចូលតែមួយ

ប្រធានការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅមានតួនាទីមួយចំនួនដូចជា៖ -ដឹកនាំចាត់ចែង និងសម្របសម្រួលគ្រប់កិច្ចការប្រចាំថ្ងៃក្នុងការិយាល័យច្រកចេញចូលតែមួយ។ -ធានាថាមន្ត្រីរាជការ និងបុគ្គលិកទាំងអស់របស់ការិយាល័យច្រកចេញចូលតែមួយ គោរពពេលវេលាបំពេញការងារតាមច្បាប់ លិខិតបទដ្ឋាន និងរបៀបរបបធ្វើការងារដែលបានកំណត់។ -អប់រំ ហ្វឹកហាត់ និងបែងចែក ភារកិច្ចជូនមន្ត្រី បុគ្គលិក ស្របតាមរបៀបរបបធ្វើការងាររបស់ការិយាល័យ។ -ដោះស្រាយ សម្របសម្រួល រាល់សំណូមពររបស់ប្រជាពលរដ្ឋ។ -ដឹកនាំ និងចាត់ចែងស្រង់ទិន្នន័យ ដើម្បីចងក្រងបញ្ជីសេវាកម្មតាមវិស័យនីមួយៗ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។ -ផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង និងកំរៃសេវា តាមរយៈមធ្យោបាយ និងឧបករណ៍ព័ត៌មានផ្សេងៗ។ -លើកយោបល់ជូនក្រុមសម្របសម្រួលរដ្ឋបាលអំពីសំណើ និងសំណុំលិខិតដែលមានលក្ខណៈសាំញ៉ាំ ស្មុគស្មាញ។ -លើកមតិយោបល់ជូនគណៈអភិបាលក្នុងការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗដូចជា ស្ថាប័នគយ ក្រសួង ស្ថាប័នដែលបានធ្វើ ប្រតិភូកម្មមកឱ្យការិយាល័យច្រកចេញចូលតែមួយ។ -រៀបចំផែនការការងារពិនិត្យលើចំណុចខ្លាំង ចំណុចខ្សោយ ធ្វើសំណូមពរជូនថ្នាក់ដឹកនាំពិនិត្យសម្រេច។ -ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។ -ពិនិត្យរបាយការណ៍ ហើយផ្ញើជូនវិស័យពាក់ព័ន្ធ។ -បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីអភិបាលខណ្ឌ និងអភិបាលរងទទួលបន្ទុក។

### ២.៥.៤.តួនាទីរបស់អនុប្រធានការិយាល័យច្រកចេញចូលតែមួយ

អនុប្រធានការិយាល័យច្រកចេញចូលតែមួយមានតួនាទីដូចជា៖ -លើកយោបល់ និងរាយការណ៍ជូនប្រធានការិយាល័យ លើកករណីដែលមានបញ្ហាពុំច្បាស់លាស់។ -ជួយប្រធាន

ការិយាល័យច្រកចេញចូលតែមួយក្នុងការផ្តល់ព័ត៌មាន និងទទួលព័ត៌មានគ្រប់យ៉ាងពីបញ្ហាចម្ងល់របស់អតិថិជន។ -ជំនួសប្រធានការិយាល័យក្នុងករណីប្រធានអវត្តមាន។ -ជួយប្រធានក្នុងការគ្រប់គ្រង និងចាត់ចែងសម្ភារក្នុងការិយាល័យ។ -ធ្វើរបាយការណ៍សកម្មភាពជូនមុខប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។ -ទទួលពិនិត្យលើលិខិតនីត្យានុកូលកម្ម និងលិខិតស្នាមផ្សេងៗ ស្ថិតក្នុងប្រតិកម្ម និងបញ្ជូនទៅប្រធានការិយាល័យ។ -បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានការិយាល័យច្រកចេញចូលតែមួយ។[២៦]

### ២.៥.៥.ភាតព្វកិច្ចរបស់មន្ត្រីរាជការបុគ្គលិកនៃការិយាល័យច្រកចេញចូលតែមួយ

ក្នុងការបំពេញការងារមន្ត្រីរាជការ បុគ្គលិករបស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅមានកាតព្វកិច្ចដូចជាៈ -ខិតខំប្រឹងប្រែងបញ្ចេញសមត្ថភាពបំពេញការងារក្រោមការចាត់ចែងរបស់ប្រធាន។ -អនុវត្តមុខងារដែលបានប្រគល់ឱ្យស្របតាមបញ្ញត្តិច្បាប់ លិខិតបទដ្ឋាន និងបទបញ្ជាដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន បក្សពួក និងគ្រួសារ។ -ខិតខំបង្កើនចំណេះដឹងខាងបច្ចេកទេស និងចំណេះដឹងផ្ទាល់ខ្លួនឱ្យបានជាប្រចាំ។ -សហការជិតស្និទ្ធ និងត្រូវជួយគ្នាទៅវិញទៅមកក្នុងការអនុវត្តភារកិច្ច។ -អនុវត្តតាមការណែនាំ និងបទបញ្ជារបស់ថ្នាក់ដឹកនាំ។[២៧]

## ២.៦.នីតិវិធីរដ្ឋបាល ទម្រង់បែបបទ ការបង់ថ្លៃសេវា និងដែនកំណត់នៃការផ្តល់សេវាសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយ

### ២.៦.១.នីតិវិធីរដ្ឋបាល

ជាទូទៅ អ្នកដែលមកស្នើសុំសេវានៅការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅមានអ្នកខ្លះចេះអក្សរ និងអ្នកខ្លះមិនចេះអក្សរ។ ដូច្នេះអ្នកខ្លះគាត់អាចបំពេញបែបបទដោយខ្លួនឯងបាន រីឯអ្នកខ្លះទៀតមិនអាចបំពេញបែបបទដោយខ្លួនឯងបានទេ ហេតុនេះហើយទើបមន្ត្រីផ្នែកជួរមុខមានភារកិច្ចជួយបំពេញជំនួស និងចេញបង្កាន់ដៃជូនគាត់ដោយមានចុះហត្ថលេខារបស់មន្ត្រីប្រគល់ទទួលឯកសារនិងព័ត៌មានដើម្បីចៀសវាងនូវកំហុសឆ្គងច្រើនដង។ លក្ខណៈពិសេសនៃបង្កាន់ដៃនេះគឺកំណត់កាលបរិច្ឆេទទទួលលិខិតអនុញ្ញាត ហើយបង្កាន់ដៃនេះធ្វើឡើងជាពីរច្បាប់ ដោយមួយច្បាប់សម្រាប់ផ្តល់ជូនអតិថិជន និងមួយច្បាប់ទៀតសម្រាប់រក្សាទុកជាឯកសារ។ បន្ទាប់ពីមន្ត្រីការិយាល័យច្រកចេញចូលតែមួយទទួលបានពាក្យស្នើសុំរបស់អតិថិជនរួចហើយ ក្រុមទទួលឯកសារនៃផ្នែកជួរមុខត្រូវបំពេញបែបបទរដ្ឋបាល (កត់ត្រាលិខិតចូល រៀបចំសំណុំឯកសារតាមលំដាប់ឱ្យបានរៀបរយ) បន្ទាប់មកបញ្ជូនឯកសារទៅប្រធានការិយាល័យ និងបន្តទៅមន្ត្រីភ្នាក់ងារមាន

[២៦] ក្រសួងមហាផ្ទៃ, *ការិយាល័យច្រកចេញចូលតែមួយ* (ភ្នំពេញៈ ក្រសួងមហាផ្ទៃ, ២០១៣), ២៩-៣៣។
[២៧] ក្រសួងមហាផ្ទៃ, *ការិយាល័យច្រកចេញចូលតែមួយ* (ភ្នំពេញៈ ក្រសួងមហាផ្ទៃ, ២០១៣), ៣៥។

សមត្ថកិច្ចនៃផ្នែកជួរក្រោយមិនឱ្យលើសពី៤ម៉ោង។ ចំពោះផ្នែកជួរក្រោយត្រូវពិនិត្យ និងលើកយោបល់ជូនអភិបាលខណ្ឌតាមរយៈប្រធានការិយាល័យច្រកចេញចូលតែមួយ ឬអង្គភាពពាក់ព័ន្ធព្រមទាំងអភិបាលរងទទួលបន្ទុក ដើម្បីពិនិត្យសម្រេចក្នុងរយៈពេលមួយទៅតាមគោលការណ៍កំណត់។ ក្នុងករណីដែលមានគោលការណ៍សម្រេចពីថ្នាក់ដឹកនាំ មន្ត្រីមានសមត្ថកិច្ចត្រូវផលិតជាលិខិតអនុញ្ញាត ដើម្បីសម្រេចបញ្ចប់ និងបញ្ជូនទៅបេឡានៅផ្នែកជួរមុខត្រៀមចេញបង្កាន់ដៃបង់ថ្លៃសេវា និងប្រគល់ជូនអ្នកស្នើសុំប្រកបដោយលក្ខណៈរូសរាយរាក់ទាក់និងស្និទ្ធស្នាល។ ក្នុងករណីដោយឡែកផ្សេងទៀត ដែលសំណើសុំមិនទទួលបានការឯកភាពពីថ្នាក់ដឹកនាំដោយមានមូលហេតុផ្សេងៗ ភ្នាក់ងារមានសមត្ថកិច្ច និងប្រធានការិយាល័យត្រៀមលិខិតឆ្លើយតបជូនអតិថិជនដោយបញ្ជាក់មូលហេតុច្បាស់លាស់។[២៨]

### ២.៦.២.ទម្រង់បែបបទ

ជាគោលការណ៍ការិយាល័យច្រកចេញចូលតែមួយ ជាកន្លែងដែលប្រជាពលរដ្ឋមកទទួលសេវាតាមនីតិវិធី និងទម្រង់បែបបទសាមញ្ញ។ពាក្យស្នើសុំមានលក្ខណៈស្រដៀងគ្នាស្ទើរគ្រប់វិស័យ ប៉ុន្តែខុសប្លែកគ្នាត្រង់កិច្ចសន្យាអម ដែលតាមសេចក្តីណែនាំរបស់ក្រសួងសាមីនីមួយៗ។ ទម្រង់បែបបទសម្រាប់ផ្តល់ជូនប្រជាពលរដ្ឋបំពេញ និងទម្រង់បែបបទលិខិតឆ្លើយតបត្រូវរៀបចំឱ្យមានលក្ខណៈសាមញ្ញ ខ្លី ច្បាស់លាស់ និង ងាយយល់។ ទម្រង់បែបបទទាំងនោះ ត្រូវសម្រេចដោយអភិបាលក្រុង ស្រុក ខណ្ឌ ដោយមាន ការពិគ្រោះយោបល់ជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធ។[២៩]

### ២.៦.៣.ការបង់ថ្លៃសេវា

ចំពោះការបង់ថ្លៃសេវា គឺជាដំណាក់ការចុងក្រោយនៃសំណុំបែបបទដែលស្នើសុំ (លទ្ធផលសម្រេច)។ ការបង់ថ្លៃសេវានេះគឺធ្វើនៅផ្នែកជួរមុខ និងជាភារកិច្ចរបស់មន្ត្រីបេឡា។ អតិថិជនត្រូវបង់ថ្លៃសេវាកម្មដោយខ្លួនឯងផ្ទាល់នៅបញ្ជរទទួលប្រាក់។ បញ្ជរទទួលប្រាក់ត្រូវមានព័ត៌មានអំពីសេវាកម្មនេះ ដោយត្រូវបានធ្វើការដាក់តាំងក្នុងការិយាល័យ និងប្រកាសជាសាធារណៈតាមរយៈការបិទផ្សាយនៅកន្លែង ដែលប្រជាពលរដ្ឋអាចចេញចូលបានងាយស្រួលគ្រប់ពេលវេលា ឬចុះផ្សាយនៅក្នុងព្រឹត្តិបត្រព័ត៌មាននានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌផងដែរ។ នៅពេលទទួលប្រាក់បេឡាករត្រូវចេញបង្កាន់ដៃបង់សេវាកម្មជូនអតិថិជន។ បង្កាន់ដៃបង់ថ្លៃសេវាកម្មនេះ ត្រូវមានហត្ថលេខារបស់បេឡា និងមានចុះកាលបរិច្ឆេទថ្ងៃ ខែ ឆ្នាំបង់លុយ។ បង្កាន់ដៃនេះ ត្រូវធ្វើឡើងជា ០៣

[២៨] ក្រសួងមហាផ្ទៃ, *ការិយាល័យច្រកចេញចូលតែមួយ* (ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១៣), ៤១-៤៥។
[២៩] ក្រសួងមហាផ្ទៃ, *ការិយាល័យច្រកចេញចូលតែមួយ* (ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១៣), ៤៥។

ច្បាប់ ដោយ០១ច្បាប់សម្រាប់ជូនអតិថិជន ០១ច្បាប់សម្រាប់រក្សាទុកនៅបេឡាករ និង០១ច្បាប់ទៀតសម្រាប់ភ្ជាប់ជាមួយសំណុំឯកសារ។[៣០]

**២.៦.៤.ដែនកំណត់នៃការផ្តល់សេវាសាធារណៈ**

ការិយាល័យច្រកចេញចូលតែមួយនៃខណ្ឌច្បារអំពៅបានបើកឱ្យដំណើរការ ជាផ្លូវការនៃផ្តល់សេវារដ្ឋបាលចំនួន ១៩៤ ប្រភេទសេវាដែលក្រសួងចំនួន០៩បានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព រហ័ស មានតម្លាភាព តាមនីតិវិធីសាមញ្ញ និងពេលវេលាកំណត់។ នៅក្នុង១៩៤ប្រភេទសេវាដែលផ្តល់ឱ្យដោយការិយាល័យច្រកចេញចូលតែមួយមាន១១វិស័យដូចជា៖ ១.ការងារនីត្យានុកូលកម្មមាន ២៦ប្រភេទសេវា ២.ការងារអគ្រានុកូលដ្ឋានមាន ០៦ប្រភេទសេវា ៣.វិស័យវប្បធម៌ និងវិចិត្រសិល្បៈមាន ២៥ប្រភេទសេវា ៤.វិស័យអប់រំ យុវជន និងកីឡាមាន ១០ប្រភេទសេវា ៥.វិស័យទេសចរណ៍មាន ១៣ប្រភេទសេវា ៦.វិស័យសំណង់ និងដីធ្លីមាន ៨៣ប្រភេទសេវា ៧.វិស័យឧស្សាហកម្ម រ៉ែ និងថាមពលមាន ០៩ប្រភេទសេវា ៨.វិស័យពាណិជ្ជកម្មមាន ០១សេវា ៩.វិស័យសុខាភិបាលមាន ០៤ប្រភេទសេវា ១០.វិស័យសាធារណៈការនិងដឹកជញ្ជូន ១១.វិស័យកសិកម្មមាន ០៦ប្រភេទសេវា។ បើយោងតាមកិច្ចសម្ភាសជាមួយអនុប្រធាននៃការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅបានបញ្ជាក់ប្រាប់ថា រាល់ការផ្តល់សេវារដ្ឋបាលទាំង ១១ វិស័យទៅឱ្យប្រជាពលរដ្ឋគឺអាចផ្តល់ជូនចំពោះអ្នកប្រើប្រាស់សេវានៅក្នុងដែនសមត្ថកិច្ចរបស់ខណ្ឌច្បារអំពៅតែប៉ុណ្ណោះ លើកលែងតែការងារនីត្យានុកូលកម្ម (ការបញ្ជាក់លើឯកសារថតចម្លង) តែប៉ុណ្ណោះដែលអ្នកប្រើប្រាស់អាចទទួលសេវានៅការិយាល័យច្រកចេញចូលតែមួយនៃខណ្ឌណាក៏បាន។ បន្ថែមពីនេះការិយាល័យច្រកចេញចូលតែមួយនៃខណ្ឌច្បារអំពៅផ្តល់សេវារដ្ឋបាលបានតែចំពោះរាល់ប្រភេទសេវាទាំងឡាយណា ដែលបានកំណត់ និងបានផ្សព្វផ្សាយជាសាធារណៈនៅក្នុងខិតប័ណ្ណផ្សព្វផ្សាយតែប៉ុណ្ណោះ។ ដូច្នេះបើប្រភេទសេវាណាដែលគ្មាននៅក្នុងក្រដាសផ្សព្វផ្សាយការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ មិនអាចផ្តល់សេវាបានទេ ពីព្រោះការធ្វើបែបនេះការិយាល័យច្រកចេញចូលតែមួយនឹងធ្វើការងារឆ្លងដែនសមត្ថកិច្ច។ ឧទាហរណ៍ ចំពោះការបញ្ជាក់ការងារនីត្យានុកូលកម្ម ការិយាល័យច្រកចេញចូលតែមួយនៃខណ្ឌច្បារអំពៅអាចបញ្ជាក់លើ ការងារនីត្យានុកូលកម្មត្រឹមកំរិតបរិញ្ញាបត្រចុះក្រោម បើលើសពីការបញ្ជាក់បរិញ្ញាបត្រគឺអ្នកទទួលសេវាត្រូវទៅបញ្ជាក់បន្តទៅសាលារាជធានីវិញ។[៣១]

[៣០] ក្រសួងមហាផ្ទៃ, *ការិយាល័យច្រកចេញចូលតែមួយ* (ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១៣), ៤៥។

[៣១] ខៀវ សុភារី (អនុប្រធានការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ), បទសម្ភាសដោយ តេង គង្គា, ១៨ មិថុនា ២០១៥។

## ២.៧.វិន័យ និងការហាមឃាត់ចំពោះមន្ត្រីក្នុងការិយាល័យច្រកចេញចូលតែមួយ

### ២.៧.១.វិន័យ

មន្ត្រីរាជការ បុគ្គលិក របស់ការិយាល័យច្រកចេញចូលតែមួយ អាចត្រូវបានចាត់ទុកថាមានកំហុសឆ្គងខាងវិន័យប្រសិនបើពួកគាត់មិនអនុវត្តតាម ឬអនុវត្តផ្ទុយពីរបៀបរបបធ្វើការងាដូចខាងក្រោមនេះ។ ទណ្ឌកម្មខាងវិន័យ ត្រូវអនុវត្តតាមមាត្រា៣១ មាត្រា៣២ នៃច្បាប់ស្តីពីសហាលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។ មន្ត្រីរាជការ បុគ្គលិក ដែលមានកំហុសឆ្គង និងត្រូវទទួលការអប់រំណែនាំពីប្រធាន ប៉ុន្តែបើមន្ត្រីរាជការ ឬបុគ្គលិកដែលមានកំហុសឆ្គងម្តងហើយមិនបានកែប្រែនឹងត្រូវទទួលការអប់រំណែនាំពីប្រធាន ឬអភិបាលរងទទួលបន្ទុក ក្នុងករណីធ្ងន់ធ្ងរ និងត្រូវបានដាក់ជូនអភិបាលជាអ្នកសម្រេច។[៣២]

#### ២.៧.១.១.ពេលវេលាប្រតិបត្តិការការងារ

មន្ត្រីរាជការ បុគ្គលិកទាំងអស់នៃការិយាល័យច្រកចេញចូលតែមួយត្រូវបំពេញការងារប្រាំ(០៥) ថ្ងៃក្នុងមួយសប្តាហ៍ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រៈ

-ពេលព្រឹក : ពីម៉ោង ៧:០០ នាទី ដល់ម៉ោង ១១:៣០ នាទី

-ពេលថ្ងៃ : ពីម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:៣០ នាទី។[៣៣]

#### ២.៧.១.២.ការឈប់សម្រាក

មន្ត្រីរាជការ បុគ្គលិកនៅក្នុងការិយាល័យច្រកចេញចូលតែមួយអាចត្រូវបានអនុញ្ញាតឱ្យឈប់សម្រាកពីការងារ ប្រសិនបើពួកគាត់ជួបប្រទះនូវបញ្ហាដូចខាងក្រោម៖ -ការឈប់សម្រាកពីការងារដោយធុរៈផ្សេងៗ ត្រូវមានការអនុញ្ញាតច្បាប់តាមគោលការណ៍ និងសេចក្តីណែនាំជាធរមាន។ -ការឈប់សម្រាកពីការងាររបស់មន្ត្រីរាជការ បុគ្គលិក ទោះក្នុងករណីណាក៏ដោយត្រូវមានការអនុញ្ញាតជាមុន ពីប្រធានការិយាល័យច្រកចេញចូលតែមួយ។ -ក្នុងករណីដែលមន្ត្រីរាជការ បុគ្គលិកណាម្នាក់ឈប់សម្រាកពីការងារ ប្រធានការិយាល័យត្រូវចាត់មន្ត្រីដែលមានសមត្ថភាពមកជំនួសដើម្បីធានានិរន្តរភាពការងារ។ -ក្នុងករណីមន្ត្រីរាជការ បុគ្គលិកមានជំងឺ សាមីខ្លួន ឬក្រុមគ្រួសារត្រូវផ្តល់ដំណឹងជូនប្រធានការិយាល័យ អំពីសភាពនៃជំងឺនៅ ថ្ងៃដំបូងនៃជំងឺ។ ក្នុងករណីជំងឺត្រូវអូសបន្លាយច្រើនជាងបី(០៣) ថ្ងៃ (រាប់ទាំងថ្ងៃមិនធ្វើការ) នៅថ្ងៃទីបួន មន្ត្រីរាជការ បុគ្គលិក ឬក្រុមគ្រួសារ ត្រូវមានសំបុត្រពេទ្យដែលតម្រូវឱ្យមន្ត្រីរាជការ បុគ្គលិក ឬក្រុមគ្រួសារបុគ្គលិកនោះឈប់សម្រាកពីការងារមួយរយៈដើម្បីព្យាបាលជំងឺ។ -ក្នុងករណីមន្ត្រីរាជការ បុគ្គលិកមិនអាចមកបំពេញ

[៣២] បទបញ្ជាផ្ទៃក្នុងរបស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ។

[៣៣] បទបញ្ជាផ្ទៃក្នុងរបស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ។

ការងារបានដោយមានឧបសគ្គចាំបាច់ មន្ត្រីរាជការ បុគ្គលិកនោះ ត្រូវផ្តល់ព័ត៌មានភ្លាមជូនទៅអ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន។ -ពេលមានមន្ត្រីរាជការ បុគ្គលិកណាម្នាក់អវត្តមានពីការងារ ទោះបីមានឬគ្មានមូលហេតុ និងការចូលបំពេញការងារវិញ អ្នកគ្រប់គ្រងផ្ទាល់មន្ត្រីរាជការ បុគ្គលិកនោះត្រូវរាយការណ៍ជូនប្រធានការិយាល័យច្រកចេញចូលតែមួយ។ -ក្នុងករណីដែលមន្ត្រីរាជការ បុគ្គលិកណាម្នាក់ត្រូវទៅចូលរួមប្រជុំ ឬសិក្ខាសិលា ឬចុះបំពេញបេសកកម្មការងារ សាមីខ្លួនត្រូវធ្វើលិខិតស្នើសុំពីប្រធានការិយាល័យច្រកចេញចូលតែមួយ។ បន្ទាប់ពីបានទៅចូលរួមប្រជុំសិក្ខាសិលា ឬបេសកកម្មមន្ត្រីរាជការ បុគ្គលិកត្រូវធ្វើសេចក្តីរាយការណ៍ពីលទ្ធផលការងារជូនប្រធានការិយាល័យច្រកចេញចូលតែមួយ ហើយចម្លងជូនការិយាល័យជំនាញសាមី។ -ក្នុងពេលម៉ោងបំពេញការងារមន្ត្រីរាជការ បុគ្គលិកត្រូវមានវត្តមានជាប្រចាំនៅការិយាល័យរបស់ខ្លួន។ ប្រសិនបើមន្ត្រីរាជការបុគ្គលិកណាម្នាក់មានភារកិច្ចត្រូវទៅការិយាល័យផ្សេង ត្រូវជូនព័ត៌មានឱ្យប្រធានការិយាល័យច្រកចេញចូលតែមួយ។ -ការឈប់សម្រាកការងារប្រចាំឆ្នាំនីមួយៗ ត្រូវអនុវត្តតាមការកំណត់របស់រាជរដ្ឋាភិបាល។[៣៤]

### ២.៧.១.៣.សីលធម៌ និងអាកប្បកិរិយា

បុគ្គលិក មន្ត្រីដែលបំពេញការងារនៅក្នុងការិយាល័យច្រកចេញចូលតែមួយគួរមានសីលធម៌ និងអាកប្បកិរិយាដូចជាៈ -ត្រូវមានអាកប្បកិរិយាសុភាពរាបសារ ថ្លៃថ្នូរ និងម៉ឺងម៉ាត់ក្នុងការងារ។ -មិនត្រូវប្រើភាសាគំរោះគំរើយ អសីលធម៌ ឬ ស្រែកឡូឡានៅក្នុងបន្ទប់ធ្វើការដែលនាំអោយរំខានដល់អ្នកដទៃ ឬចំពោះប្រជាពលរដ្ឋដែលមកស្នើសុំសេវា។ -រក្សាសណ្តាប់ធ្នាប់ របៀបរៀបរយក្នុងម៉ោងធ្វើការ ត្រូវមានវត្តមានតាមកន្លែងធ្វើការ មិនបង្កការរំខានដោយទូរស័ព្ទ ដល់កន្លែងធ្វើការជិតខាង។ -មិនត្រូវហូបគ្រឿងស្រវឹង ក្នុងម៉ោងកំពុងធ្វើការ។ -មិនត្រូវប្រព្រឹត្តល្បែងស៊ីសងគ្រប់ប្រភេទក្នុងកន្លែងធ្វើការងារ។ -រក្សាសាមគ្គីភាព មិត្តភាព រវាងមន្ត្រីរាជការទូទៅ។ ដោយយោងទៅតាមសៀវភៅស្តីអំពីគុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការបានចែងថា មន្ត្រីរាជការស៊ីវិលគ្រប់រូបត្រូវបំពេញការងារប្រកបដោយ ឆន្ទៈមនសិការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈនឹងធ្វើឱ្យរដ្ឋបាលសាធារណៈកាន់តែមាន តម្លាភាព ភាពឆ្លើយតប និងប្រសិទ្ធភាព ដើម្បីសម្រេចគោលដៅបម្រើប្រជាជនឱ្យកាន់តែល្អប្រសើរឡើង។[៣៥]

[៣៤] ក្រសួងមហាផ្ទៃ, *ការិយាល័យច្រកចេញចូលតែមួយ* (ភ្នំពេញៈ ក្រសួងមហាផ្ទៃ, ២០១៣), ៣៧-៣៩។
[៣៥] ក្រសួងមហាផ្ទៃ, *ការិយាល័យច្រកចេញចូលតែមួយ* (ភ្នំពេញៈ ក្រសួងមហាផ្ទៃ, ២០១៣), ៣៧។

**ក.ឆន្ទៈម្ចាស់ការ**

ឆន្ទៈម្ចាស់ការ គឺជាដំណើរការមួយ ដែលជំរុញ តម្រង់ទិស និងថែរក្សានូវឥរិយាបថរបស់មនុស្សទូទៅក្នុងទិសដៅនៃការសម្រេចគោលដៅណាមួយ។ ឆន្ទៈ គឺជាកត្តាមួយ ដែលជួយឱ្យអង្គភាព ឬស្ថាប័នមួយទទួលបានជោគជ័យ ប្រសិនបើបុគ្គលនៅអង្គភាពនោះមានឆន្ទៈបម្រើការងារ។ ចំណែកឯកឆន្ទៈបម្រើការងារវិញគឺវាកើតចេញពីមនសិការរបស់បុគ្គល ឬក្រុម មិនមែនកើតឡើងដោយការចាប់បង្ខំពីនរណាម្នាក់នោះទេ។ ខាងក្រោមនេះគឺជាចំណុចមួយចំនួនដែលមន្ត្រីរាជការគួរប្រតិបត្តិដើម្បីទទួលបានជោគជ័យរបស់អង្គភាព និងបុគ្គលខ្លួនឯងផ្ទាល់៖

- **ទឹកចិត្តស្រលាញ់ការងារ**

គ្រប់មន្ត្រីរាជការគឺត្រូវតែមានទឹកចិត្តស្រលាញ់ការងារ និងស្ថាប័នរបស់ខ្លួនព្រោះថាការងារនោះ ហើយដែលជាមុខរបររបស់ខ្លួនបានជ្រើសរើសយកដូច្នេះវាមានន័យថាការងារជាអ្នកកំណត់អំពីជោគវាសនា និងអនាគតរបស់ខ្លួន។ ការធ្វេសប្រហែសទៅលើការងារអ្វីមួយមានន័យស្មើនឹងការធ្វេសប្រហែសទៅលើអនាគតរបស់ខ្លួនឯងផងដែរ។ ហេតុដូចនេះហើយទើបថ្នាក់ដឹកនាំគ្រប់ស្ថាប័នតែងតែឱ្យតម្លៃទៅលើមន្ត្រីរាជការណាដែលមានឆន្ទៈបម្រើការងារ ទឹកចិត្តស្មោះត្រង់ ខិតខំបំពេញការងារឱ្យមានប្រសិទ្ធភាពដើម្បីឱ្យស្ថាប័នរីកចម្រើន ហើយការវិវដ្តអាជីពរបស់មន្ត្រីរាជការក៏ពឹងផ្អែកលើការងារដែលមន្ត្រីរាជការបានបំពេញផងដែរ។

- **ការមានគំនិតផ្តួចផ្តើម និងច្នៃប្រឌិត**

ក្រៅពីបំពេញកាតព្វកិច្ចតាមផែនការដែលអង្គភាពបានដាក់ចេញ មន្ត្រីរាជការត្រូវខិតខំសិក្សាស្វែងយល់ និងត្រូវមានគំនិតចេះច្នៃប្រឌិតក្នុងគោលបំណងកែលម្អសកម្មភាពការងារធ្វើយ៉ាងណាឱ្យការងារមានប្រសិទ្ធភាព និងរីកចំរើនយ៉ាងឆាប់រហ័ស។ គំនិតផ្តួចផ្តើម និងច្នៃប្រឌិតគឺជាចក្ខុវិស័យដែលកើតមានឡើងនៅពេលដែលមន្ត្រីរាជការចេះស្រលាញ់ការងារ ចេះស្រលាញ់វិជ្ជាជីវៈ និងមានគោលដៅច្បាស់លាស់ដើម្បីឱ្យអង្គភាពមានការរីកចម្រើន និងមានកិត្យានុភាពលើសពីនេះទៅទៀតការរៀបចំផែនការដើម្បីអនាគតរបស់ខ្លួនឯងផងដែរ។

- **ការបំពេញកាតព្វកិច្ចក្នុងស្មារតីជាក្រុម**

ការធ្វើការងារជាក្រុមនេះគឺជាគោលគំនិតដ៏មានសារៈសំខាន់គ្រប់កាលៈទេសៈ ហើយវាក៏ជាមូលដ្ឋានក្នុងការកាត់បន្ថយគម្លាតរវាងថ្នាក់ធ្វើគោលនយោបាយ និងថ្នាក់អនុវត្ត រវាងមន្ត្រីនិងមន្ត្រីជាងនេះទៅទៀតគឺកាត់បន្ថយនូវកំហុសឆ្គង ឬការខ្វែងគំនិតគ្នាដើម្បីរកចំណុចរួមនៅក្នុងអង្គភាពដែលនាំឱ្យមន្ត្រីរាជការចេះស្រលាញ់រាប់អានគ្នា រួមគ្នាទទួលខុសត្រូវ និងចេះអត់ឱនឱ្យគ្នាទៅវិញទៅមក។

• **ស្មារតីឈ្មុសឈ្មុលក្នុងការងារ**

ក្រៅពីបានបំពេញភារកិច្ចរបស់ខ្លួនរួចហើយ មន្ត្រីរាជការមិនត្រូវទុកពេលវេលាឱ្យទំនេរចោលឥតប្រយោជន៍នោះទេគឺត្រូវមានគំនិតចង់ដឹងថែមទៀត ដោយស្វះស្វែងរកការងារបន្ថែមដោយខ្លួនឯង មិនត្រូវអង្គុយចាំឱ្យការងាររត់មករកយើងនោះទេ។ នេះគឺជាការបណ្តុះមនសិការការងារ និងស្មារតីភ្ញាក់រឭករបស់មន្ត្រីម្នាក់ៗគ្រប់ពេលវេលា។ មន្ត្រីរាជការ មិនត្រូវខ្លាចនឿយហត់នៅពេលមានការងារច្រើនពេក ឬ ភ័យបារម្ភចំពោះការងារលំបាកឡើយមានន័យថាត្រូវតែមានភាពអំណត់ព្យាយាមជានិច្ចដើម្បីសម្រេចជោគជ័យក្នុងការងារ។ ភាពខ្ជីខ្ជា ធ្វើឱ្យរួចតែពីដៃ ដោយមិនគិតអំពីលទ្ធផលការងារ មិនគិតពីផលប្រយោជន៍រួម គឺជាប្រការដែលត្រូវចៀសវាងឱ្យខានតែបាន។ ភាពមានការងារធ្វើជាប្រចាំ នឹងធ្វើឱ្យមន្ត្រីរាជការអាចពង្រឹងបាននូវសមត្ថភាពរបស់ខ្លួន ព្រមទាំងទទួលបាននូវបទពិសោធ ចំណេះដឹង ចំណេះធ្វើ និងជំនឿទុកចិត្តពីថ្នាក់ដឹកនាំថែមទៀតផង។

• **ការជម្នះឧបសគ្គ**

ជាធម្មតា រាល់ការងារណាក៏ដោយក៏តែងតែមានឧបសគ្គផងដែរ ប៉ុន្តែឧបសគ្គទាំងនោះមិនមែនជារបាំងដែលមករាំងស្ទះការងាររបស់យើងគ្រប់ពេលនោះទេ។ ម្យ៉ាងវិញទៀតគ្រប់ឧបសគ្គទាំងអស់មិនមែនសុទ្ធតែមានផលអាក្រក់ទាំងអស់នោះទេ ឧបសគ្គខ្លះក៏បានផ្តល់នូវបទពិសោធន៍ល្អៗសម្រាប់យើងម្នាក់ៗផងដែរ។ ដូចនេះហើយមន្ត្រីរាជការទាំងអស់ត្រូវតែមានស្មារតីទទួលខុសត្រូវខ្ពស់ ហើយត្រៀមខ្លួនក្នុងការជម្នះរាល់ឧបសគ្គដែលកើតមានឡើង និងមិនត្រូវភ័យខ្លាច រួញរាជាពិសេសមិនត្រូវបោះបង់ចោលភារកិច្ចរបស់ខ្លួនជាដាច់ខាត។

**ខ.ភក្តីភាព**

ភក្តីភាព គឺសេចក្តីត្រូវការដែលមនុស្សក្នុងសង្គមអរិយធម៌ត្រូវតែប្រកាន់ភ្ជាប់ ដើម្បីលើកតម្កើងកិត្តិយស និងសេចក្តីថ្លៃថ្នូរ ទាំងក្នុងនាមជាបុគ្គលនិងក្នុងនាមជាស្ថាប័នដែលខ្លួនកំពុងបម្រើការងារផង។ មន្ត្រីរាជការដែលប្រកបដោយមនសិការត្រូវប្រកាន់ភ្ជាប់នូវភក្តីភាពតាមរយៈសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

• **ការយល់ដឹងអំពីសភាពការណ៍**

មន្ត្រីរាជការគ្រប់រូបត្រូវធ្វើការសិក្សា និងស្វែងយល់បន្ថែមអំពីសភាពការណ៍វិវដ្តជុំវិញសង្គមនិងពិភពលោក ជាពិសេសស្ថានភាពវិវដ្តរបស់រាជរដ្ឋាភិបាលដែលកំពុងបំពេញការងារ។ ការស្វែងយល់ពីសភាពការណ៍អាចជាកាបង្កើននូវស្មារតីទទួលខុសត្រូវ ចំណេះដឹង ការផ្តួចផ្តើមគំនិត ដើម្បីជំរុញការប្រតិបត្តិការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងមានភាពរីកចម្រើនដល់ក្រសួងស្ថាប័នរបស់ខ្លួន។

• **ភក្ដីភាពចំពោះស្ថាប័ន**

មន្ត្រីរាជការម្នាក់ៗត្រូវមានភាពស្មោះត្រង់និងភក្ដីភាពចំពោះស្ថាប័ន ព្រោះថាវាជាមូលដ្ឋានចាំបាច់ ដែលមន្ត្រីគ្រប់រូបត្រូវប្រកាន់ខ្ជាប់គ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែងដែលខ្លួនបំពេញការងារ អាចនិយាយបានថាវាជាគុណធម៌ដែលមន្ត្រីត្រូវតែមាន។

• **ភក្ដីភាពចំពោះវិជ្ជាជីវៈ**

មន្ត្រីរាជការគ្រប់រូបត្រូវបំពេញការងារដោយការទទួលខុសត្រូវខ្ពស់ និងមានមនសិការវិជ្ជាជីវៈខ្ពស់ក្នុងគោលដៅធ្វើឱ្យអង្គភាពរីកចម្រើន ដូចនេះមន្ត្រីរាជការគ្រប់រូបមិនត្រូវធ្វើឱ្យខូច ឬអាប់ឱនកិត្យានុភាពរបស់រដ្ឋបាលសាធារណៈ តាមរយៈការរក្សានូវពាក្យសំដីដែលខ្លួននិយាយចេញទៅ ឬសរសេរទៅដោយប្រុងប្រយ័ត្ន និងមិននិយាយអ្វីដែលប៉ះពាល់ដល់កិត្តិយស កិត្យានុភាពក្រសួង ស្ថាប័ន អង្គភាព ឬសមត្ថកិច្ចថ្នាក់ដឹកនាំរបស់ខ្លួន។

• **ភក្ដីភាពចំពោះប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវា**

មន្ត្រីរាជការគ្រប់រូបត្រូវរ៉ាប់រងការងារ ឬសេវាទាំងឡាយ ដែលអង្គភាពឬថ្នាក់ដឹកនាំប្រគល់ជូន ឬចាត់តាំងឱ្យអនុវត្ត។ មួយវិញទៀតមន្ត្រីរាជការទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវវប្បធម៌ "អ្នកផ្ដល់សេវា និងអ្នកប្រើប្រាស់សេវា" ព្រោះប្រជាពលរដ្ឋគឺជាអតិថិជនជាប្រចាំដែលផ្សារភ្ជាប់ទៅនឹងសកម្មភាពការងាររបស់មន្ត្រីរាជការទាំងនោះ ទោះដោយចំពោះ ឬដោយមិនចំពោះក្ដី។ មន្ត្រីរាជការគ្រប់រូបត្រូវយកចិត្តទុកដាក់ចំពោះការងាររបស់ខ្លួន និងផ្ដល់អាទិភាពទៅលើសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវា តាមរយៈការផ្ដល់នូវជំនឿទុកចិត្ត ប្រសិទ្ធភាពការងារ តម្លាភាព និងការធ្វើទំនាក់ទំនងប្រកបដោយភាតរភាព។

**គ.មនសិការវិជ្ជាជីវៈ**

មន្ត្រីរាជការគ្រប់រូបត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវកាតព្វកិច្ចនានា ដែលបានកំណត់នៅក្នុងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដើម្បីបំពេញវិជ្ជាជីវៈរបស់ខ្លួនឱ្យបានល្អ។ ការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ និងការទទួលខុសត្រូវអំពីកិច្ចការរបស់ខ្លួន គឺជាកាតព្វកិច្ចសំខាន់ ដែលមន្ត្រីរាជការគ្រប់រូបត្រូវបំពេញឱ្យបានដើម្បីប្រសិទ្ធភាពការងារ។ សកម្មភាពសំខាន់ៗមួយចំនួនដែលមន្ត្រីរាជការត្រូវប្រតិបត្តិមានដូចជាៈ មន្ត្រីរាជការត្រូវប្រឹងប្រែងបំពេញការងារឱ្យអស់ពីលទ្ធភាពសំដៅធ្វើឱ្យមានការរីកចម្រើន និងមានប្រសិទ្ធភាព។ មន្ត្រីរាជការត្រូវយកចិត្តទុកដាក់ក្នុងការបំពេញការងារ និងមានមនសិការការងារដើម្បីសម្រេចលទ្ធផលស្របតាមផែនការសកម្មភាព។ មន្ត្រីរាជការត្រូវធ្វើការប្ដេជ្ញាចិត្តអភិវឌ្ឍន៍ខ្លួនប្រើប្រាស់សមត្ថភាព ចំណេះដឹង ជំនាញ ភាពប៉ិនប្រសប់ និងចរិកលក្ខណៈរបស់ខ្លួនដោយសេចក្ដីថ្លៃថ្នូរ។ មន្ត្រីរាជការត្រូវស្ទិតស្វាញក្នុងការបំពេញការងារជាមួយមន្ត្រីផ្សេង

ទៀត។ មន្ត្រីរាជការត្រូវលះបង់ទាំងកម្លាំងកាយចិត្តចំពោះការងារក្នុងគោលបំណងបម្រើប្រយោជន៍សាធារណៈ។ មន្ត្រីរាជការចាំបាច់ត្រូវបង្កើនសមត្ថភាពជំនាញឯកទេស ចំណេះដឹងនិងបទពិសោធន៍របស់ខ្លួន។ មន្ត្រីរាជការមិនអាចយកពេលវេលាធ្វើការទៅប្រកបរបរឯកជនបានទេហើយក៏មិនអាចទទួលផលប្រយោជន៍នានាពីអ្នកណាមួយ ដោយអាងថាខ្លួនត្រួតពិនិត្យលើផ្នែកនោះ។ មន្ត្រីរាជការត្រូវរក្សាការសម្ងាត់នៅក្នុងស្ថាប័ន ហើយត្រូវប្រកាន់ភ្ជាប់នូវកាតព្វកិច្ចលាក់ការណ៍មានន័យថាមិននិយាយ ឬសរសេរពីអ្វីដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនិងកិត្យានុភាពរបស់អង្គភាព ឬសមត្ថកិច្ចថ្នាក់ដឹកនាំរបស់ខ្លួន។ មន្ត្រីរាជការត្រូវទទួលខុសត្រូវលើតួនាទីភារកិច្ចរបស់ខ្លួន ហើយមន្ត្រីរាជការក៏ត្រូវមានកាតព្វកិច្ចរ៉ាប់រងលើសេវាដែលថ្នាក់លើចាត់តាំងឱ្យ ជាពិសេសគាត់ត្រូវគោរពវិន័យការងារ ម៉ោងធ្វើការ និងបទបញ្ជាផ្ទៃក្នុងរបស់អង្គភាព។ ម្យ៉ាងវិញទៀតមន្ត្រីរាជការទាំងអស់ត្រូវគោរពបទបញ្ជារបស់ថ្នាក់លើដែលចាត់តាំងឱ្យបម្រើការងារ។

**ឃ.វប្បធម៌សេវាសាធារណៈ**

- **ការផ្លាស់ប្តូរឥរិយាបថ**

នៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋគឺមានឋានុក្រម ប៉ុន្តែរវាងរដ្ឋាភិបាលនិងពលរដ្ឋមិនមានឋានុក្រមទេ។ ហេតុនេះហើយមន្ត្រីរាជការត្រូវកែប្រែឥរិយាបថនិងរបៀបរបបនៃការធ្វើទំនាក់ទំនងជាមួយពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវាប្រកបដោយសេក្តីថ្លៃថ្នូរ មានភាតរភាព និងការទទួលខុសត្រូវ។ ការផ្លាស់ប្តូរឥរិយាបថ គឺជាកត្តាចាំបាច់ដើម្បីឱ្យមន្ត្រីរាជការអាចបំពេញការងាររបស់ខ្លួនក្នុងនាមជាអ្នកបម្រើសេវាទៅពលរដ្ឋបានល្អ។ ដូច្នេះវាមានន័យថា ត្រូវមានការផ្លាស់ប្តូរពីភាពជាអ្នកត្រួតត្រាគេទៅជាអ្នកផ្តល់សេវាវិញ។

- **អ្នកផ្តល់សេវា**

អ្នកផ្តល់សេវាត្រូវបំពេញការងាររបស់ខ្លួន ដោយផ្តោតទៅលើសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវាហើយការផ្តល់សេវាត្រូវឆ្លើយតបប្រកបដោយមនសិការវិជ្ជាជីវៈ និងសេចក្តីថ្លៃថ្នូរ។ ដោយមិនត្រូវប្រើប្រាស់តួនាទីរបស់ខ្លួនធ្វើឱ្យប្រជាពលរដ្ឋជួបការលំបាក។ បន្ថែមពីនេះទៅទៀតអ្នកផ្តល់សេវាត្រូវតែផ្តល់នូវភាពជឿទុកចិត្ត បំបាត់នូវភាពភ័យខ្លាច ផ្តល់នូវកក់ក្តៅ រាក់ទាក់ ការគោរពនិងធ្វើឱ្យប្រជាពលរដ្ឋពេញចិត្តចំពោះសកម្មភាពការងារនិងអត្តចរិតក្នុងនាមជាអ្នកផ្តល់សេវា។

- **អ្នកប្រឹក្សាយោបល់**

អ្នកប្រឹក្សាយោបល់ត្រូវធ្វើការយកចិត្តទុកដាក់ក្នុងការផ្តល់ព័ត៌មាន និងពន្យល់ អំពីនីតិវិធីរបៀបរបប និងបែបបទផ្សេងៗចំពោះប្រជាពលរដ្ឋឱ្យបានច្បាស់លាស់ ហើយមិនត្រូវមានអាកប្បកិរិយាធុញទ្រាន់ ក្រអឺតក្រទម រើសអើងរវាងអ្នកតូចអ្នកធំ អ្នកក្រអ្នកមាន អ្នកស្រែអ្នកក្រុងឡើយ។

• ការសម្របសម្រួល

យន្តការនៃការសម្របសម្រួលមានសារៈសំខាន់ណាស់ចំពោះដំណើរការនៃការផ្តល់សេវា និង ការមកទទួលសេវាទៅប្រើប្រាស់ ពីព្រោះវានាំមកនូវការបន្ថយគម្លាតរវាងអ្នកផ្តល់និងអ្នកប្រើប្រាស់ សេវា រវាងការយល់ច្រឡំ ឬការខ្វែងគំនិតគ្នា។ល។ ជាពិសេសធ្វើឱ្យនីតិវិធីនៃការផ្តល់សេវាមាន ភាពសាមញ្ញ ខ្លី និងទាន់ពេលវេលា និងមានភាពរលូនក្នុងទម្រង់ការងារទាំងអស់។[៣៦]

**២.៧.២.ការហាមឃាត់**

មន្ត្រីរាជការ បុគ្គលិកដែលបម្រើការងារនៅក្នុងបណ្តាក្រសួង ស្ថាប័ននីមួយៗរបស់រដ្ឋក៏ដូចជា មន្ត្រីរាជការ ដែលបម្រើការងារនៅក្នុងការិយាល័យច្រកចេញចូលតែមួយ អាចនឹងត្រូវបានហាម ឃាត់នូវប្រការមួយចំនួនដែលពាក់ព័ន្ធនឹងផ្នែកពីរសំខាន់គឺ វិសមិតភាពមុខងារ និងអំពើពុករលួយ។

**ក.វិសមិតភាពមុខងារ**

វិសមិតភាពមុខងារ គឺអលទ្ធភាពតាមគន្លងច្បាប់ ដែលមិនអាចឱ្យមនុស្សម្នាក់ បំពេញមុខងារ ពីរកន្លែងបានក្នុងពេលតែមួយនៅក្នុងពេលដែលមន្ត្រីរូបនោះកំពុងកាន់តំណែង។ ចំពោះការហាម ឃាត់លើមុខងារនេះ គឺមានគោលបំណងចង់ឱ្យមន្ត្រីរាជការនៅក្នុងការិយាល័យច្រកចេញចូលតែ មួយអាចបម្រើសេវាដល់ប្រជាពលរដ្ឋបានល្អ ដោយវាអាចធ្វើឱ្យគាត់មិនខ្វាយខ្វល់ពីមុខងារដទៃ ដែលនាំឱ្យមានឥទ្ធិពលទៅលើសកម្មភាពការងារផ្សេងៗទៀតរបស់ខ្លួនដែលកំពុងធ្វើ។

មន្ត្រីរាជការ បុគ្គលិក ដែលបំពេញការងារនៅក្នុងការិយាល័យច្រកចេញចូលតែមួយត្រូវបាន ហាមឃាត់នៅក្នុងផ្នែកមុខងារលើករណីមួយចំនួនដូចជា៖

-យកម៉ោងរដ្ឋបាលទៅប្រកបរបរផ្ទាល់ខ្លួនផ្សេងទៀត

-ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអ្នករាជការ

-ចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ឬប្រយោល

-ប្រកបមុខរបរបន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការ។

**ខ.អំពើពុករលួយ**

អំពើពុករលួយ គឺជាការស៊ីសំណូកសូកប៉ាន់ដែលតែងតែកើតមានឡើង ហើយមានច្រើនទម្រង់ បែបបទ ដូច្នេះហើយទើបគ្រប់ក្រសួងស្ថាប័នត្រូវចៀសវាងដាច់ខាតនូវការប្រព្រឹត្តអំពើពុករលួយ។ ចំណែកឯកការិយាល័យច្រកចេញចូលតែមួយ ដែលជាស្ថាប័នមួយដែលបង្កើតឡើងមកក្នុងគោល បំណងដើម្បីធ្វើឱ្យមានអភិបាលកិច្ចល្អទៅកាន់តែខិតជិតប្រជាពលរដ្ឋ ក៏ខិតខំពង្រឹងខ្លួនឱ្យចៀស

[៣៦] ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល, *គុណសម្បត្តិនៃឥរិយាបទរបស់មន្ត្រីរាជការ* (ភ្នំពេញ៖ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ បាល, ២០១០), ៨-៣៥។

ផុតអំពីអំពើពុករលួយដោយធ្វើការហាមឃាត់ទៅលើមន្ត្រីរាជការ ឬបុគ្គលិកដែលបម្រើការនៅក្នុងការិយាល័យច្រកចេញចូលតែមួយចំពោះករណីមួយចំនួន ដែលពាក់ព័ន្ធនឹងផ្នែកពុករលួយដូចជាៈ

-យកឥទ្ធិពល និងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើដើម្បីទាញយកផលប្រយោជន៍ ឬដើម្បីសម្លុត គំរាមកំហែង បំពានសិទ្ធិរបស់ប្រជាពលរដ្ឋ។

-ការប៉ុនប៉ង ឬការទទួលរង្វាន់ អំណោយ ឬគ្រប់រូបភាពនៃសគុណ ដែលទាក់ទងនឹងមុខងាររបស់មន្ត្រីបុគ្គលិកនោះ។

-បោះពុម្ពផ្សាយ ឬធ្វើការផ្សាយព័ត៌មានដែលពាក់ព័ន្ធនៅក្នុងមុខងាររបស់ខ្លួន ដោយពុំមានការអនុញ្ញាតជាមុនពីប្រធានការិយាល័យ។[៣៧]

## ២.៨.ធនធានហិរញ្ញវត្ថុនៃការិយាល័យច្រកចេញចូលតែមួយ

### ២.៨.១.ចរិតលក្ខណៈនៃការិយាល័យច្រកចេញចូលតែមួយ

ច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ ជាការិយាល័យដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋដូច្នេះវាជាអង្គភាពរបស់រដ្ឋមិនមែនឯកជនទេ ហើយអាចនិយាយបានថាវាមិនមែនជាអង្គភាពដែលមានលក្ខណៈស្វ័យភាពថវិកាទេ។ ការិយាល័យច្រកចេញតែមួយអាចដំណើរការងារបានដោយសារតែមានប្រភពចំណូលពីការផ្តល់សេវាទាំង១១វិស័យរបស់សាលាខណ្ឌច្បារអំពៅ។[៣៨]

### ២.៨.២.ប្រភពចំណូល

- **ចំណូលក្នុងឆ្នាំ ២០១៤**

ការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅអាចដំណើរការទៅបាន ដោយសារតែទទួលបានចំណូលផ្ទាល់ពីការផ្តល់សេវារដ្ឋបាលទាំង ១៩៥ប្រភេទសេវា ឬសេវាទាំង១១វិស័យ។ ដោយយោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០១៤លេខ ០០២របក.ចអពចុះថ្ងៃទី១៤ មករា ២០១៥ របស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅបានបង្ហាញថាចំណូល ដែលបានមកសេវាប្រតិបត្តិការតាមវិស័យនីមួយៗនៅក្នុងឆ្នាំ ២០១៤ សរុបរួមមានចំនួន៦២៣,៩១៥,៣២០រៀល ដែលចំណូលទាំងអស់នេះរាប់បញ្ចូលចាប់ពីនៅខណ្ឌមានជ័យមកប្រមាណ២៣៨,៣៥៨,០០០រៀល បើគិតចាប់ពីថ្ងៃទី២ ខែឧសភាដល់ថ្ងៃទី៩ ខែមិថុនាឆ្នាំ២០១៤ ។ ហើយចំណូលរបស់ខណ្ឌច្បារអំពៅផ្ទាល់គិតចាប់ពីថ្ងៃទី១០ ខែមិថុនា រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ មានប្រមាណ

[៣៧] ក្រសួងមហាផ្ទៃ, *ការិយាល័យច្រកចេញចូលតែមួយ* (ភ្នំពេញៈ ក្រសួងមហាផ្ទៃ, ២០១៣), ៣៦។
[៣៨] យី ធីរ៉ាត (ប្រធានការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ), បទសម្ភាសដោយ ទី ហុងឡេង, ២២ មិថុនា ២០១៥។

៣៨៥,៥៥៧,៣២០រៀល។បច្ចុប្បន្នខណ្ឌមានជ័យ បានបំបែកជាពីរគឺខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ។

**តារាងទី១៖ ចំណូលរបស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅឆ្នាំ២០១៤**

| ល.រ | វិស័យ | ចំនួនអតិថិជន | | ចំនួនសេវា | ចំណូលសរុប (រៀល) |
|---|---|---|---|---|---|
| | | សរុប | ស្រី | | |
| ១ | សាធារណៈការ និងដឹកជញ្ជូន | ៤១១ | ៩៥ | ៤៣០ | ១៣,១២៥,៣២០ |
| ២ | ពាណិជ្ជកម្ម | ០ | ០ | ០ | ០ |
| ៣ | សុរិយោដី និងសំណង់ | ០ | ០ | ២,២៩៩ | ៥៣៦,០០០,០០០ |
| ៤ | ទេសចរណ៍ | ០ | ០ | ០ | ០ |
| ៥ | ឧស្សាហកម្ម និងសិប្បកម្ម | ០ | ០ | ០ | ០ |
| ៦ | វប្បធម៌ និងវិចិត្រសិល្បៈ | ០ | ០ | ០ | ០ |
| ៧ | នីត្យានុកូលកម្ម | ៣៧,៨៩៥ | ២,២០៩ | ៤០,២០០ | ៤០,២០០,០០០ |
| ៨ | សុខាភិបាល | ៩ | ១ | ៩ | ១,៧៤០,០០០ |
| ៩ | កសិកម្ម | ១ | ០ | ១ | ៣៥,០០០ |
| ១០ | អប់រំ យុវជន និងកីឡា | ២ | ០ | ២ | ៤០០,០០០ |
| ១១ | អគ្រានុកូលដ្ឋាន | ៣,២៣០ | ៨៤៥ | ៦,៤៨៣ | ៣២,៤១៥,០០០ |
| សរុបរួម | | ៤២,៤៩៦ | ៣,៤៦៣ | ៤៩,៤២៤ | ៦២៣,៩១៥,៣២០ |

បើយោងតាមតារាងខាងលើនេះ បានបង្ហាញថាមានតែសេវារដ្ឋបាលចំនួន០៧ប៉ុណ្ណោះដែលមានដំណើរការនិងបានបម្រើជូនប្រជាពលរដ្ឋយ៉ាងសកម្ម។ សេវាទាំងនោះមានដូចជា:

-សាធារណៈការ និងដឹកជញ្ជូនទទួលចំណូល ១៣,១២៥,៣២០រៀល

-នីត្យានុកូលកម្មទទួលបានចំណូល ៤០,២០០,០០០រៀល

-សុខាភិបាលទទួលបានចំណូល ១,៧៤០,០០០រៀល

-កសិកម្មទទួលបានចំណូល ៣៥,០០០រៀល

-អប់រំ យុវជន និងកីឡាទទួលបានចំណូល ៤០០,០០០រៀល

-សុរិយោដីទទួលបានចំណូល ៥៣៦,០០០,០០០រៀល

-អត្រានុកូលដ្ឋានទទួលបានចំណូល ៣២,៤១៥,០០០រៀល

មួយវិញទៀត តាមរយៈតារាងនេះអាចសង្កេតបានថាសេវារដ្ឋបាល ដែលមានការមមាញឹកជាងគេនៅការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅគឺការងារនីត្យានុកូលកម្ម ដែលមានអតិថិជនមកទទួលសេវាទៅប្រើប្រាស់រហូតដល់ ៣៧,៨៩៥នាក់ និងមានចំនួនសេវាសរុបប្រមាណ ៤០,២០០ ប្រភេទសេវា។[៣៩]

**•ចំណូលប្រចាំឆមាសទី១ក្នុងឆ្នាំ ២០១៥**

**តារាងទី២៖ ចំណូលប្រចាំឆមាសទី១ ក្នុងឆ្នាំ ២០១៥ របស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ**

| ល.រ | វិស័យ | ចំនួនអតិថិជន | | ចំនួនសេវា | ចំណូលសរុប (រៀល) |
|---|---|---|---|---|---|
| | | សរុប | ស្រី | | |
| ១ | សាធារណៈការ និងដឹកជញ្ជូន | ១,៩២០ | ៣៩៨ | ១,៩២៥ | ១៥០,១៥០,០០០ |
| ២ | ពាណិជ្ជកម្ម | ០ | ០ | ០ | ០ |
| ៣ | សុរិយោដី និងសំណង់ | ៥០២ | ១២៤ | ២,០១៦ | ៤២៣,៨០០,០០០ |
| ៤ | ទេសចរណ៍ | ២ | ១ | ២ | ២៤០,០០០ |
| ៥ | ឧស្សាហកម្ម និងសិប្បកម្ម | ០ | ០ | ០ | ០ |
| ៦ | វប្បធម៌ និងវិចិត្រសិល្បៈ | ០ | ០ | ០ | ០ |
| ៧ | នីត្យានុកូលកម្ម | ២៣,៣៣០ | ២,៤២៧ | ២៣,៣៨៥ | ២៣,៣៨៥,០០០ |
| ៨ | សុខាភិបាល | ១០ | ២ | ១០ | ១,៨២០,០០០ |
| ៩ | កសិកម្ម | ១ | ០ | ១ | ៣៥,០០០ |
| ១០ | អប់រំ យុវជន និងកីឡា | ០ | ០ | ០ | ០ |
| ១១ | អត្រានុកូលដ្ឋាន | ១,៩០០ | ៧១៦ | ៣,៨១៧ | ១៩,០៨៥,០០០ |
| សរុបរួម | | ២៧,៦៦៥ | ៣,៦៦៨ | ៣១,១៥៦ | ៦១៨,៥១៥,០០០ |

[៣៩] សាលាខណ្ឌច្បារអំពៅ, *របាយការណ៍ប្រចាំឆ្នាំ២០១៤*, លេខ០០២.របក.ចអព (ភ្នំពេញ៖ សាលាខណ្ឌច្បារអំពៅ, ១៤ មករា ២០១៥), ៣-៧។

ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅទទួលបានចំណូលក្នុងឆ្នាំ ២០១៥ សរុបរួមមានចំនួន៦១៨,៥១៥,០០០រៀលពីការផ្តល់សេវាទាំង ១១វិស័យ។ មួយវិញទៀត តាមរយៈតារាងខាងលើនេះបង្ហាញឱ្យឃើញថាសេវារដ្ឋបាល ដែលមានការមមាញឹកជាងគេនៅការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ គឺការងារនីត្យានុកូលកម្ម ដែលមានអតិថិជនមកទទួលសេវាទៅប្រើប្រាស់រហូតដល់ ២៣,៣៣០នាក់ និងមានចំនួនសេវាសរុបប្រមាណ ២៣,៣៨៥ ប្រភេទ សេវាដែលត្រូវបានបញ្ចប់រួចរាល់។បើយោងតាមតារាងខាងលើនេះ បានបង្ហាញថាមានតែសេវារដ្ឋបាលចំនួន០៧ប៉ុណ្ណោះដែលមានដំណើរការនិងបានបម្រើជូនប្រជាពលរដ្ឋយ៉ាងសកម្ម។ សេវាទាំងនោះមានដូចជាៈ

-សាធារណៈការ និងដឹកជញ្ជូនទទួលចំណូល ១៥០,១៥០,០០០រៀល

-ទេសចរណ៍ទទួលបានចំណូល២៤០,០០០

-នីត្យានុកូលកម្មទទួលបានចំណូល ២៣,៣៨៥,០០០រៀល

-សុខាភិបាលទទួលបានចំណូល ១,៨២០,០០០រៀល

-កសិកម្មទទួលបានចំណូល ៣៥,០០០រៀល

-សុរិយោដី និងសំណង់ទទួលបានចំណូល ៤២៣,៨០០,០០០រៀល

-អគ្រានុកូលដ្ឋានទទួលបានចំណូល ១៩,០៨៥,០០០រៀល។[៩០]

### ២.៨.៣.ការចំណាយ

ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅបានទទួលចំណូលចាប់ពីថ្ងៃទី១០ ខែមិថុនា រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ ប្រមាណ ៣៨៥,៥៥៧,៣២០រៀលពីការផ្តល់សេវានិងការផាកពិន័យ។ ចំណូលទាំងនេះត្រូវបានគេបែងចែកសម្រាប់ការកាត់ទុកលើ រង្វាន់លើកទឹកចិត្ត និងសម្រាប់ជាថវិការដ្ឋបាលរបស់ខណ្ឌច្បារអំពៅសម្រាប់ការចំណាយ និងការងារអភិវឌ្ឍន៍ផ្សេងៗ ដោយយោងទៅតាមប្រកាសអន្តរក្រសួងលេខ៣៨៤៥ប្រក ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ច និងហិញ្ញវត្ថុ ចុះថ្ងៃទី២៩ វិច្ឆិកា ឆ្នាំ២០១៣។ ការកាត់ទុកសម្រាប់រង្វាន់លើកទឹកចិត្តត្រូវបានគេបែងចែកជា ៤ ចំណែកដូចជា ចំណែករដ្ឋបាលខណ្ឌច្បារអំពៅ ចំណែករដ្ឋបាលសង្កាត់ ចំណែកមន្ទីរជំនាញ និងចំណែករបស់មន្ទីរសេដ្ឋកិច្ចនិងហិញ្ញវត្ថុ

[៩០] សាលាខណ្ឌច្បារអំពៅ, *របាយការណ៍ប្រចាំឆមាសទី១ឆ្នាំ២០១៥*, លេខ០៦២.របក.ចអព (ភ្នំពេញ៖ សាលាខណ្ឌច្បារអំពៅ, ២៤ មិថុនា ២០១៥), ៣-៨។

ដែលមានចំនួន ១%នៃប្រាក់ចំណូលសរុប។[៤១] ម្យ៉ាងទៀតនៅពេលខណ្ឌច្បារអំពៅបានបំបែកចេញពីខណ្ឌមានជ័យ ចំណូលមួយភាគដែលគិតចាប់ពីថ្ងៃទី២ ខែឧសភា ដល់ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៤ មានចំនួន២៣៨,៣៥៨,០០០រៀលត្រូវបង្វិលឱ្យទៅខណ្ឌច្បារអំពៅ។[៤២]

**តារាងទី៣៖ ការបែងចែកប្រាក់ចំណូលដែលទទួលបានពីការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅក្នុងឆ្នាំ២០១៤**

| ល.រ | វិស័យ | ចំណូលប្រមូលពីខែមិថុនាដល់ធ្នូ | ការបែងចែកប្រាក់ចំណូលប្រមូលបាន | | | | |
|---|---|---|---|---|---|---|---|
| | | | បង់ចូលថវិការដ្ឋបាលខណ្ឌច្បារអំពៅ | ចំណែករបស់ខណ្ឌច្បារអំពៅ | ចំណែករដ្ឋបាលសង្កាត់ | មន្ទីរជំនាញ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ១ | ទីក្សានុកូលកម្ម | ៣៥,៧១២,០០០ | ១០,៧១៣,៦០០ | ២៤,៦៤១,២៨០ | ០ | ០ | ៣៥៧,១២០ |
| ២ | វប្បធម៌និងវិចិត្រសិល្បៈ | ០ | ០ | ០ | ០ | ០ | ០ |
| ៣ | អប់រំយុវជន និងកីឡា | ០ | ០ | ០ | ០ | ០ | ០ |
| ៤ | ទេសចរណ៍ | ០ | ០ | ០ | ០ | ០ | ០ |
| ៥ | អគ្រានុកូលដ្ឋាន | ២៥,៣៤៥,០០០ | ១០,១៣៨,០០០ | ១៤,៩៥៣,៥៥០ | ០ | ០ | ២៥៣,៤៥០ |
| ៦ | ស៊ីវិលយោធី និងសំណង់ | ៣១០,២០០,០០០ | ១៥៥,១០០,០០០ | ១០៥,៤៦៨,០០០ | ៣១,០២០,០០០ | ១៥,៥១០,០០០ | ៣,១០២,០០០ |
| ៧ | ឧស្សាហកម្ម រ៉ែ និងថាមពល | ០ | ០ | ០ | ០ | ០ | ០ |
| ៨ | ពាណិជ្ជកម្ម | ០ | ០ | ០ | ០ | ០ | ០ |
| ៩ | សុខាភិបាល | ១,១៤០,០០០ | ៥៧០,០០០ | ៣៨៧,៦០០ | ៥៧,០០០ | ១១៤,០០០ | ១១,៤០០ |
| ១០ | សាធារណៈការ និងដឹកជញ្ជូន | ១៣,១២៥,៣២០ | ៦,៥៦២,៦៦០ | ៤,៤៦២,៦០៩ | ៦៥៦,២៦៦ | ១,៣១២,៥៣២ | ១៣១,២៥៣ |
| ១១ | កសិកម្ម | ៣៥,០០០ | ១៧,៥០០ | ១១,៩០០ | ១,៧៥០ | ៣,៥០០ | ៣៥០ |
| | **សរុប** | **៣៨៥,៥៥៧,៣២០** | **១៨៣,១០១,៧៦០** | **១៤៩,៩២៤,៩៣៩** | **៣១,៧៣៥,០១៦** | **១៦,៩៤០,០៣២** | **៣,៨៥៥,៥៧៣** |

## ២.៩.ការិយាល័យប្រជាពលរដ្ឋ

ការិយាល័យប្រជាពលរដ្ឋ គឺជាអង្គភាពធ្វើសកម្មភាពដោយអព្យាក្រឹត្យក្នុងការទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ អំពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រុះសម្រួលដោះស្រាយបណ្តឹងទាំងនោះ ព្រមទាំងតាមដានការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ ហើយកសាងទំនាក់ទំនងល្អរវាងពាណិជ្ជករ អង្គការសង្គមស៊ីវិល និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ការិយាល័យប្រជាពលរដ្ឋមានសមត្ថកិច្ចទទួលពាក្យបណ្តឹងតវ៉ា និងផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ ក្រុមហ៊ុន សហគ្រាស និង

---

[៤១] សាលាខណ្ឌច្បារអំពៅ, *តារាងគណនាប្រាក់រង្វាន់លើកទឹកចិត្តគិតពីថ្ងៃទី១០ ខែមិថុនា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ លើចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ និងផាកពិន័យ*, គ្មានលេខ (ភ្នំពេញ៖ សាលាខណ្ឌច្បារអំពៅ)។

[៤២] សាលាខណ្ឌច្បារអំពៅ, *តារាងគណនាប្រាក់រង្វាន់លើកទឹកចិត្តគិតពីថ្ងៃទី២១០ ខែមិថុនា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ លើចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ និងផាកពិន័យ*, គ្មានលេខ (ភ្នំពេញ៖ សាលាខណ្ឌច្បារអំពៅ)។

អង្គការសង្គមស៊ីវិលក្នុងករណីមានភាពមិនប្រក្រតី ឬកំហុសឆ្គងរបស់បុគ្គលិកដែលបម្រើការងារក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនោះ។[៩៣]

### ២.៩.១.គោលបំណង

ការិយាល័យប្រជាពលរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើងដោយមានគោលបំណងដូចជា -ធ្វើឱ្យរដ្ឋបាលកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព កាត់បន្ថយអំពើពុករលួយ បង្កើនភាពពេញចិត្ត និងទំនុកចិត្តរបស់ប្រជាពលរដ្ឋចំពោះរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ -បង្កើននូវយន្តការចូលរួម និងផ្តល់ឱកាសសម្រាប់ប្រជាពលរដ្ឋបញ្ចេញមតិយោបល់ជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ -ធ្វើឱ្យប្រជាពលរដ្ឋទទួលបាននូវអ្នកសម្រុះសម្រួលអព្យាក្រឹតមួយដែលជួយពួកគាត់ក្នុងការដោះស្រាយជម្លោះជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ។[៩៤]

### ២.៩.២.តួនាទី

ការិយាល័យប្រជាពលរដ្ឋ ជាអង្គភាពធ្វើសកម្មភាពដោយអព្យាក្រឹត្យ ក្នុងការទទួលពាក្យបណ្តឹងតវ៉ាពីប្រជាពលរដ្ឋ អំពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងតវ៉ាទាំងនោះ។ ពាក្យបណ្តឹងតវ៉ាអាចលើកឡើងអំពីករណីមួយចំនួនដូចខាងក្រោម៖

-ការសម្រេចចិត្ត ឬអាកប្បកិរិយាដែលផ្ទុយនឹងគោលការណ៍ច្បាប់

-ការបដិសេធ ឬការស្ទាក់ស្ទើរក្នុងការទទួលយកពាក្យស្នើសុំត្រឹមត្រូវតាមច្បាប់របស់ប្រជាពលរដ្ឋ

-មិនបានផ្តល់លទ្ធផល ឬដំណោះស្រាយសមស្របតាមពេលវេលាណាមួយដែលបានកំណត់

-មានឥរិយាបថមិនអាចទទួលយកបានដូចជាការបំភិតបំភ័យ ឬការប្រមាថមាក់ងាយដល់ប្រជាពលរដ្ឋ ឬតំណាងសហគ្រាសនានា។[៩៥]

### ២.៩.៣.មុខងារ

ការិយាល័យប្រជាពលរដ្ឋមានមុខងារដូចខាងក្រោម៖

-ធានាឱ្យបានថាបញ្ហានានារបស់ប្រជាពលរដ្ឋ ត្រូវបានដោះស្រាយដោយបុគ្គលិករដ្ឋបាល ក្រុង ស្រុក ខណ្ឌស្របតាមលក្ខណៈច្បាប់លិខិតបទដ្ឋាននានាដោយគ្មានបែបបទរដ្ឋបាលច្រើននិងគ្មានការពន្យាពេល។

[៩៣] ក្រសួងមហាផ្ទៃ, *ការិយាល័យប្រជាពលរដ្ឋ* (ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១៣), ១។

[៩៤] ក្រសួងមហាផ្ទៃ, *ការិយាល័យប្រជាពលរដ្ឋ* (ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១៣), ២។

[៩៥] ក្រសួងមហាផ្ទៃ, *ការិយាល័យប្រជាពលរដ្ឋ* (ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១៣), ២-៣។

-ការពារប្រជាពលរដ្ឋ និងសហគ្រាសដែលមាននៅក្នុងក្រុង ស្រុក ខណ្ឌនៅក្នុងការធ្វើទំនាក់ទំនងជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងកិច្ចការអាជីវកម្មដែលមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រុង ស្រុក ខណ្ឌប្រឆាំងនឹងការធ្វើសេចក្តីសម្រេចណាដែលខុសឆ្គងដែលបំពានទៅលើច្បាប់និងលិខិតបទដ្ឋានជាធរមាន។

-ផ្សព្វផ្សាយ និងផ្តល់ព័ត៌មាននានាអំពីសេវារបស់ការិយាល័យច្រកចេញចូលតែមួយការអភិវឌ្ឍក្រុង ស្រុក ខណ្ឌ និងព័ត៌មានរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌព្រមទាំងព័ត៌មានផ្សេងៗទៀតពាក់ព័ន្ធនឹងគោលការណ៍ណែនាំ និងលិខិតបទដ្ឋានអំពីវិមជ្ឈការនិងវិសហមជ្ឈការ។

-ប្រឆាំងនឹងអំពើពុករលួយរបស់មន្ត្រីរាជការក្រុង ស្រុក ខណ្ឌ។[៤៦]

[៤៦] ក្រសួងមហាផ្ទៃ, *ការិយាល័យប្រជាពលរដ្ឋ* (ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១៣), ៣។

# ជំពូកទី៣
# ការវិភាគលើរបបគំហើញនៃការផ្តល់សេវាសាធារណៈនៃការិយាច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅ

## ៣.១.លទ្ធផលនៃការបង្កើតការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ

ការិយាល័យច្រកចេញចូលតែមួយ គឺជាផ្នែកមួយនៃគម្រោងរបស់រដ្ឋាភិបាលដែលជាគន្លឹះដ៏សំខាន់នៃយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ។ ហើយដែលគម្រោងនេះត្រូវបានដកស្រង់បទពិសោធន៍ចេញពីគម្រោងសាកល្បងនៅក្រុងទាំងពីរ ដែលបានបង្កើតការិយាល័យច្រកចេញចូលតែមួយ ការិយាល័យប្រជាពលរដ្ឋ និងទម្រង់ថ្មីៗនៃការចូលរួមរបស់ប្រជាពលរដ្ឋ។ ជាងនេះទៅទៀតតាមរយៈបទពិសោធន៍នៃការសាកល្បងនៅក្រុងសៀមរាប និងបាត់ដំបង បានធ្វើឱ្យការិយាល័យច្រកចេញចូលតែមួយនៅខណ្ឌច្បារអំពៅរឹតតែមានភាពស្និទ្ធស្នាល ជាមួយប្រជាពលរដ្ឋក្នុងការផ្តល់សេវាប្រកបដោយតម្លាភាព គណនេយ្យភាព និងឆាប់រហ័សនៅថ្នាក់ក្រុង ស្រុក ខណ្ឌដែលត្រូវត្រួសត្រាយផ្លូវដើម្បីធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបន្តទៅមុខទៀតរបស់រាជរដ្ឋាភិបាល។ ជាទូទៅបើទោះជាការបង្កើតការិយាល័យច្រកចេញចូលតែមួយបានផ្តល់នូវផលវិជ្ជមានជាច្រើនជូនប្រជាពលរដ្ឋ មន្ត្រីរាជការ អាជ្ញាធរ រាជរដ្ឋាភិបាលក៏ដោយ ប៉ុន្តែការបង្កើតការិយាល័យនេះក៏បានផ្តល់នូវផលអវិជ្ជមានផងដែរ។

### ៣.១.១.ផលវិជ្ជមាននៃការបង្កើតការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ

ការបង្កើតការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅ មានគោលបំណងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅខណ្ឌច្បារអំពៅបានផ្តល់នូវផលវិជ្ជមានមួយចំនួនជូន ប្រជាពលរដ្ឋ បុគ្គលិក មន្ត្រីរាជការ អាជ្ញាធរ និងរាជរដ្ឋាភិបាល ដែលផលវិជ្ជមានទាំងនោះមានដូចជា៖

**ចំពោះប្រជាពលរដ្ឋ:** ប្រជាពលរដ្ឋទាំងអស់ដែលស្នាក់នៅក្នុងទីតាំងដែលក្រុង ស្រុក ខណ្ឌដែលបានជ្រើសរើស ត្រូវបានទទួលនូវអត្ថប្រយោជន៍យ៉ាងច្រើនហើយដោយផ្ទាល់នូវសេវារដ្ឋបាលមួយចំនួនដែលទទួលបានតាមរយៈការផ្ទេរពីក្រសួង ស្ថាប័ននានាមកឱ្យការិយាល័យច្រកចេញចូលតែមួយក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ ដោយបង្កើននូវតម្លាភាព និងលទ្ធភាពផ្សេងៗទៀតដើម្បីឱ្យពួកគេទទួលបាននូវដំណឹងតាមរយៈរដ្ឋបាល។ ម្យ៉ាងវិញទៀតប្រជាពលរដ្ឋនៅក្នុងក្រុង ស្រុក ខណ្ឌដែលការិយាល័យច្រកចេញចូលតែមួយត្រូវបានបើកឱ្យដំណើរការនោះ នឹងត្រូវទទួលបាននូវការផ្តល់សេវារដ្ឋបាលចាំបាច់មួយចំនួន ក្នុងលក្ខណៈសាមញ្ញ រយៈពេលកំណត់ច្បាស់លាស់ រហ័សមាននីតិវិធីពេញលេញច្បាស់លាស់ និងមានតម្លៃកំណត់ជាផ្លូវការរួចជាស្រេចក្នុងការមកទទួលយកសេវាទៅប្រើប្រាស់។

-ប្រជាពលរដ្ឋអាចជឿជាក់បាន លើការិយាល័យច្រកចេញចូលតែមួយបានទៅតម្លៃនៃការស្នើសុំសេវាបាន ព្រោះថានៅការិយាល័យច្រកចេញចូលតែមួយត្រូវបានកំណត់តម្លៃសេវាទៅតាមក្រសួង ស្ថាប័នដែលពាក់ព័ន្ធរួចជាស្រេច ដូច្នេះហើយធ្វើឱ្យពួកគាត់អាចដឹងច្បាស់អំពីតម្លៃនៃការស្នើសុំសេវាដែលគាត់ត្រូវការ។

-ការបង្កើតការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅ គឺបានប្រមូលផ្តុំនៅគ្រប់ប្រភេទសេវានៅតែមួយកន្លែង ដែលវាធ្វើឱ្យងាយស្រួលដល់ប្រជាពលរដ្ឋមកទទួលសេវាទាំងការស្នើសុំ និងការទទួលឯកសារស្ថិតនៅកន្លែងតែមួយ។[៩៧]

**ចំពោះម្ចាស់អាជីវកម្មតូចតាច:** ដូចគ្នាផងដែរ អាជីវករ ម្ចាស់សិប្បកម្ម ភោជនីយដ្ឋាន និងផ្ទះសំណាក់មួយចំនួនក៏បានទទួលនូវផលចំណេញ ជាពិសេសពួកគេអាចចុះបញ្ជីអាជីវកម្មរបស់ខ្លួនបានយ៉ាងឆាប់រហ័ស ដោយគ្មានបញ្ហាអ្វីទាំងអស់នៅការិយាល័យច្រកចេញចូលតែមួយហើយមិនចាំបាច់ចំណាយពេលវេលាច្រើនក្នុងការធ្វើដំណើរទៅតាមក្រសួង ស្ថាប័ននានាដែលពាក់ព័ន្ធទៅនឹងការសុំចុះបញ្ជីអាជីវកម្មផ្សេងៗ។[៩៨]

**អាជ្ញាធរមូលដ្ឋាន:** អាជ្ញាធរក្រុង ស្រុក ខណ្ឌគោលដៅក៏បានទទួលផលប្រយោជន៍ពីការិយាល័យច្រកចេញចូលតែមួយនេះដែរ។ ដោយពួកគាត់ទទួលបាននូវមុខងារបន្ថែម ដែលអាចផ្តល់សេវារដ្ឋបាលក្នុងគោលដៅផលប្រយោជន៍របស់ប្រជាពលរដ្ឋខ្លួន។ មន្ត្រី បុគ្គលិកក្រុង ស្រុក ខណ្ឌនិងទទួលបាននូវការបណ្តុះបណ្តាលអំពីការទទួលខុសត្រូវរបស់ពួកគាត់ ហើយនៅពេលដែលពួកគាត់អនុវត្តតួនាទី ភារកិច្ចបានល្អ ពួកគាត់នឹងទទួលបានការតបស្នងមកវិញនូវការសរសើរចំពោះការបំពេញការងារប្រកបដោយសេចក្តីពេញចិត្តពេញថ្លើមរបស់ប្រជាពលរដ្ឋ។

-បុគ្គលិកបម្រើការងារការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅ ទទួលបាននូវគោលការណ៍លើកទឹកតាមរយៈការផ្តល់ប្រាក់រង្វាន់តាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ។[៩៩]

**មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់:** មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ក៏ទទួលបានផលប្រយោជន៍ពីការបង្កើតការិយាល័យច្រកចេញចូលតែមួយនេះដែរ។ នៅថ្នាក់ក្រុង ស្រុក ខណ្ឌមន្ត្រីរាជការថ្នាក់ក្រុង ស្រុក ខណ្ឌ នឹងត្រូវរៀបចំឱ្យស្ថិតនៅក្នុងគម្រោងអភិបាលកិច្ចល្អមូលដ្ឋានសម្រាប់ភារកិច្ចការងារថ្មី

[៩៧] យី ធីរ៉ាត (ប្រធានការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ), បទសម្ភាសដោយ ទី ហុងឡេង, ២២ មិថុនា ២០១៥។

[៩៨] ឌៀវ សុភារី (អនុប្រធានការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ), បទសម្ភាសដោយ តេង គង្គា, ២២ មិថុនា ២០១៥។

[៩៩] យី ធីរ៉ាត (ប្រធានការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ), បទសម្ភាសដោយ ទី ហុងឡេង, ២២ មិថុនា ២០១៥។

នេះ ហើយពួកគាត់ក៏និងទទួលបានមកវិញនូវប្រាក់ឧបត្ថម្ភលើកទឹកចិត្តដោយយោងទៅលើប្រភេទការងារដែលមាននៅការិយាល័យច្រកចេញចូលតែមួយ។[៥០]

**ចំពោះរាជរដ្ឋាភិបាល:** នៅទីបញ្ចប់ ការិយាល័យច្រកចេញចូលតែមួយក៏បានផ្តល់អត្ថប្រយោជន៍សម្រាប់រាជរដ្ឋាភិបាលប្រទេសកម្ពុជាផងដែរ។ ដោយសារតែការផ្តួចផ្តើមឱ្យមានតម្លាភាពសម្រាប់គម្រោងការិយាល័យច្រកចេញចូលតែមួយ ក្នុងការផ្តល់សេវាកម្មជាច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌក៏ដូចជាការផ្តល់ដំណឹងជូនប្រជាពលរដ្ឋ និងបណ្តាម្ចាស់អាជីវកម្មតូចតាច ឱ្យមានការគោរពច្បាប់ដោយការមកចុះបញ្ជីស្នាម និងអាជ្ញាប័ណ្ណផ្សេងៗ ត្រូវបានសង្ឃឹមថាមានការកើនឡើង (ដោយមានភាពងាយស្រួល និងគ្មានអំពើពុករលួយកើតមានឡើង)។ ការធ្វើបែបនេះរាជរដ្ឋាភិបាល និងទទួលបានប្រាក់ចំណូលយ៉ាងច្រើនតាមរយៈការផ្តល់សេវាកម្មជាច្រើនមកឱ្យរដ្ឋបាលមូលដ្ឋាន។

-លុបបំបាត់ចោលអ្នករត់ការឱ្យប្រជាពលរដ្ឋក្នុងការស្នើសុំសេវា ដែលធ្លាប់តែមានពីមុនមកតាមរយៈការបង្កើតឱ្យមានការិយាល័យច្រកចេញចូលតែមួយ ដើម្បីងាយស្រួលដល់ប្រជាពលរដ្ឋអាចមកទទួលសេវាដោយខ្លួនឯងផ្ទាល់ដោយមិនចំណាយថវិការច្រើនដូចពីមុនទៀត។

-ការិយាល័យច្រកចេញចូលតែមួយ ក៏បានបង្កលក្ខណៈងាយស្រួលផងដែរដល់ប្រជាពលរដ្ឋក្នុងការស្នើសុំសេវា ដែលពីមុនពេលមិនទាន់មានការិយាល័យច្រកចេញចូលតែមួយនោះពួកគាត់គឺត្រូវធ្វើដំណើរឆ្ងាយពីផ្ទះដើម្បីទៅស្នើសុំសេវានៅតាមក្រសួង ស្ថាប័នហើយមានរយៈពេលយូរខាតពេលវេលាហើយមានទម្រង់បែបបទច្រើន។ ដូច្នេះហើយទើបរដ្ឋាភិបាលបានបង្វិតសេវាឱ្យមកកាន់តែជិតប្រជាពលរដ្ឋតាមរយៈការបង្កើតការិយាល័យច្រកចេញចូលតែមួយ ដែលអាចផ្តល់ជូននូវសេវាមួយចំនួនទៅតាមតម្រូវការចាំបាច់របស់គាត់ ប្រកបដោយប្រសិទ្ធភាព គុណភាព រហ័ស។[៥១]

### ៣.១.២.ផលអវិជ្ជមាននៃការបង្កើតការិយាល័យច្រកចេញចូលតែមួយច្បារអំពៅ

ការបង្កើតការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ មិនមែនទទួលបានត្រឹមតែផលវិជ្ជមានប៉ុណ្ណោះទេ តែថែមទាំងទទួលបានផលអវិជ្ជមានផងដែរ។ ផលអវិជ្ជមានដែលទទួលបាននោះគឺមិនសូវមានច្រើនប៉ុន្មានទេ។ ផលអវិជ្ជមានដែលកើតមានចំពោះការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅមានដូចជា៖

[៥០] ខៀវ សុភាវី (អនុប្រធានការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ), បទសម្ភាសដោយ តេង គង្គា, ២២ មិថុនា ២០១៥។

[៥១] យី ធីរ៉ាត (ប្រធានការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ), បទសម្ភាសដោយ ទី ហុងឡេង, ២២ មិថុនា ២០១៥។

-ចំពោះពលរដ្ឋក៏រងផលអវិជ្ជមានពីការបង្កើតការិយាល័យច្រកចេញចូលតែមួយផងដែរ ដោយសារតែពួកគាត់ មិនទាន់បានយល់ដឹងច្បាស់អំពីនីតិវិធីបែបបទនៃការទទួលសេវានៅការិយាល័យច្រកចេញចូលតែមួយ។

-ថ្វីបើការបង្កើតការិយាល័យច្រកចេញចូលតែមួយបានបង្វិតសេវាឱ្យជិតប្រជាពលរដ្ឋ ប៉ុន្តែការបង្កើតការិយាល័យច្រកចេញចូលតែមួយក៏នៅតែមានគំលាតឆ្ងាយសម្រាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅនៅក្នុងសង្កាត់ដែលនៅឆ្ងាយពីខណ្ឌច្បារអំពៅ។

-ចំពោះមន្ត្រីរាជការ និងបុគ្គលិកនៃការិយាល័យច្រកចេញចូលតែមួយមានការងារធ្វើច្រើនជាងមុនដោយសារតែក្រសួង ស្ថាប័នបានផ្ទេរសេវារបស់ខ្លួនមកការិយាល័យច្រកចេញចូលតែមួយ ទើបធ្វើឱ្យប្រជាពលរដ្ឋមកទទួលសេវាកម្មច្រើន ដែលជាហេតុធ្វើឱ្យការងារមានការមមាញឹកច្រើន។

-លើសពីនេះទៅទៀតការបង្កើតការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ ក៏ផ្តល់ផលអវិជ្ជមានចំពោះរាជរដ្ឋាភិបាលដែរ ដោយសារតែរាជរដ្ឋាភិបាលជាបបមត្រូវចំណាយថវិកាច្រើនក្នុងការសាងសង់នូវអគារថ្មី ចំណាយទៅលើគ្រឿងសម្ភារបរិក្ខា កុំព្យូទ័រ និងសម្ភារការិល័យផ្សេងៗទៀតដើម្បីដំណើរការច្រកចេញចូលតែមួយ។[៥២]

## ៣.២.បញ្ហាប្រឈម

ទោះបីជា ការបង្កើតការិយាល័យច្រកចេញចូលតែមួយបានជួយកាត់បន្ថយការលំបាករបស់ប្រជាពលរដ្ឋក៏ពិតមែន ប៉ុន្តែប្រជាពលរដ្ឋខ្លះនៅតែមានទម្លាប់ទៅសុំសេវានៅតាមមន្ទីរហើយភាគច្រើនតែងតែពឹងពាក់មន្ត្រីឱ្យជួយរត់ការឱ្យ ដែលជាផ្នត់គំនិតធ្វើឱ្យពួកគាត់សោះអង្គើយមិនសូវខ្វាយខ្វល់មកសុំ សេវានៅការិយាល័យច្រកចេញចូលតែមួយទោះបីជាពេលខ្លះពួកគាត់ក៏បានដឹងថានៅការិយាល័យច្រកចេញចូលតែមួយ ក៏មានការផ្តល់សេវាជូនដល់ពួកគាត់នៅតាមមូលដ្ឋានក៏ដោយតែពួកគាត់បែរជាគិតថាការផ្តល់សេវានៅការិយាល័យច្រកចេញចូលមួយនេះ នៅមានរយៈយូរសម្រាប់ពួកគាត់។ដូច្នេះ ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនផងដែរ។

### ៣.២.១.ប្រជាពលរដ្ឋ

-ដោយសារតែខណ្ឌច្បារអំពៅជាខណ្ឌមួយដែលទើបតែបង្កើតថ្មី ហើយទើបតែដាក់ឱ្យដំណើរការិយាល័យច្រកចេញចូលតែមួយផងនោះ ទើបធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនមានការយល់ដឹងពុំទាន់បានច្បាស់លាស់នៅឡើយ អំពីការមកទទួលសេវានៅការិយាល័យច្រកចេញចូលតែមួយ

[៥២] យី ធីរ៉ាត (ប្រធានការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ), បទសម្ភាសដោយ តេង គង្គា, ២២ មិថុនា ២០១៥។

ព្រោះថាកាលពីមិនទាន់មានការបង្កើតឱ្យមានការិយាល័យច្រកចេញចូលតែមួយនៅតាមខណ្ឌ គឺអតិថិជនតែងតែមានទម្លាប់ទៅស្នើសុំសេវាតាមរយៈមន្ទីរ ឬស្ថាប័នរដ្ឋ និងមានអ្នកខ្លះទៀតទម្លាប់បើកអាជីវកម្មដោយមិនបាច់សុំការអនុញ្ញាត។

-ប្រជាពលរដ្ឋមួយចំនួនបានបើកអាជីវកម្ម ដោយមិនបានចុះបញ្ជីសុំធ្វើអាជីវកម្មបានត្រឹមត្រូវពីអាជ្ញាធរមូលដ្ឋានមានសមត្ថកិច្ច។ ដោយសារកិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរមូលដ្ឋានឃុំសង្កាត់ និងភូមិជាមួយការិយាល័យច្រកចេញចូលតែមួយនៅមានកម្រិតតិចតួចនៅឡើយក្នុងការស្រាវជ្រាវមុខសញ្ញាអាជីវកម្ម។

-ប្រជាពលរដ្ឋមួយចំនួនបានពឹងពាក់អ្នកដទៃឱ្យមកបង់លុយសេវាជំនួស មិនព្រមមកបង់ថ្លៃសេវាដោយខ្លួនឯងទៅលើសេវាដែលបានស្នើសុំនោះទេ ហើយបែរជារិះគន់មកលើការិយាល័យច្រកចេញចូលតែមួយថាយកលុយថ្លៃសេវាច្រើនលើសពីការកំណត់ក្នុងតារាងតម្លៃនៃសេវា។[៥៣]

**៣.២.២.មន្ត្រីរាជការ**

-កង្វះមន្ត្រីមានក្របខណ្ឌចំនួន ០៣រូប ដែលបំពេញការងារនៅផ្នែកជួរមុខ ព្រោះមន្ត្រីទាំងនោះបានផ្ទេរទៅខណ្ឌមានជ័យ។ ដោយសារតែការសុំផ្លាស់ប្តូរទៅកាន់ទីតាំងថ្មី ដែលធ្វើឱ្យមានការរអាក់រអួលនៅក្នុងដំណើរការនៃផ្តល់សេវាដល់អតិថិជន។

-សមត្ថភាពរបស់មន្ត្រីជួរក្រោយនៅមានកម្រិតនៅឡើយ។ ដូចដែលយើងបានដឹងហើយថានៅក្នុងការិយាល័យច្រកចេញចូលតែមួយការផ្តល់សេវាអាចធ្វើការប្រតិបត្តិការទៅបាន គឺអាស្រ័យទៅលើផ្នែកជួរមុខ និងផ្នែកជួរក្រោយ ប្រសិនបើផ្នែកណាមួយអសកម្មនោះដំណើរការនៃការផ្តល់សេវានិងមានការរាំងស្ទះមិនអាចដំណើរការនីតិវិធីរបស់ខ្លួនបានឡើយ។

-ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅមានការយឺតយ៉ាវម្តងម្កាល ដោយសារតែដល់ថ្ងៃកំណត់នៃការផ្តល់សេវាជូនប្រជាពលរដ្ឋ ហើយបុគ្គលិកនៃការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅមិនទាន់បានបញ្ចប់ប្រតិបត្តិការការងារលិខិតស្នាម ដែលយកមកបញ្ជាក់នៅឡើយព្រោះថាដោយសារតែអភិបាលរងខណ្ឌ ដែលជាអ្នកចុះហត្ថលេខាដើម្បីឱ្យរាល់លិខិតស្នាមនោះមានសុពលភាពជាហេតុធ្វើឱ្យរាល់លិខិតស្នាមដែលមកស្នើសុំមានការខកខាន ឬចុះហត្ថលេខាមិនទាន់ពេលវេលា។ ឧទាហរណ៍ពេលខ្លះអភិបាលរងខណ្ឌមានកិច្ចការត្រូវទៅប្រជុំនៅសាលារាជធានីភ្នំពេញដើម្បីទទួលយកនូវព័ត៌មានថ្មី ឬក៏ផែនការថ្មីៗដើម្បីយកមកអនុវត្តនៅការិយាល័យច្រកចេញចូលតែមួយ។

[៥៣] បទសម្ភាសជាមួយនឹងប្រជាពលរដ្ឋនៅខណ្ឌច្បារអំពៅ, ២៤ មិថុនា ២០១៥។

-ការិយាល័យច្រកចេញចូលតែមួយពីមួយថ្ងៃទៅមួយថ្ងៃទទួលអតិថិជនឥតឈប់ឈរ ដែលមកទទួលយកសេវាជាហេតុធ្វើឱ្យបុគ្គលិក ដែលបម្រើការនៅការិយាល័យច្រកចេញចូលតែមួយមានការមមាញឹកក្នុងការផ្តល់សេវា មិនត្រឹមតែបុគ្គលិកនោះទេដែលមានការមមាញឹកនោះ សូម្បីតែម៉ាស៊ីនព្រីន កូពីក៏មានការមមាញឹកដែរ។ ដោយសារភាពមមាញឹករបស់ម៉ាស៊ីននេះហើយទើបពេលខ្លះធ្វើឱ្យដំណើរការរបស់ម៉ាស៊ីនមានការគាំង ឬខូចលែងដំណើរការដែលជាមូលហេតុមួយផងដែរក្នុងការបង្អាក់ដំណើរការនៃការផ្តល់សេវាជូនប្រជាពលរដ្ឋ។

-ភ្លើងអគ្គិសនីក៏ជាបញ្ហាមួយផងដែរ នៅពេលដែលមានការដាច់ភ្លើងនោះការិយាល័យច្រកចេញចូលតែមួយមិនអាចធ្វើការផ្តល់លើរាល់ប្រភេទសេវា ដែលប្រជាពលរដ្ឋបានទៅទទួលយកនៅការិយាល័យច្រកចេញចូលតែមួយនោះបាន ទេព្រោះថារាល់ឯកសារត្រូវបានរៀបចំទុកដាក់ដោយបុគ្គលិកនៅទីនោះ បានយកសំណុំឯកសារ លិខិតស្នាមផ្សេងៗដាក់បញ្ចូលក្នុងទិន្នន័យទាំងអស់។ ដូច្នេះធ្វើឱ្យការិយាល័យមិនអាចដំណើរការបានទេ ព្រោះថាការងារនៅក្នុងការិយាល័យច្រកចេញចូលតែមួយក៏ត្រូវការភ្លើងអគ្គិសនីជាចាំបាច់ក្នុងដំណើរការប្រតិបត្តិការរបស់ខ្លួន។

-ការធ្វើស្លាកលេខម៉ូតូក៏នៅតែមានបញ្ហាតិចតួចកើតមានឡើងផងដែរ ដោយសារតែប្រជាពលរដ្ឋមកទទួលសេវា នៅការិយាល័យច្រកចេញចូលតែមួយគាត់ចង់ជ្រើសរើសយកលេខស្លាកម៉ូតូទៅតាមតម្រូវការរបស់អតិថិជនដូចដែលប្រជាពលរដ្ឋធ្លាប់ទៅធ្វើស្លាកលេខម៉ូតូ នៅឯមន្ទីរសាធារណៈការនិងដឹកជញ្ជូនពីមុនអញ្ចឹងដែរ។

-មន្ត្រីដែលបម្រើការងារនៅការិយាល័យច្រកចេញចូលតែមួយផ្នែកជួរក្រោយចំនួនមួយរូប ផ្នែកសុរិយោដី និងសំណង់សមត្ថភាពនៅមានកម្រិតនៅមិនទាន់បានយល់ដឹងច្បាស់ពីនីតិវិធីការងារនៅឡើយ។[៥៩]

## ៣.៣.ដំណោះស្រាយ

ការផ្តល់ ឬការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋត្រូវមានស្ថិរភាព និរន្តភាព និងឥតឈប់ឈរ ដូច្នេះការផ្តល់សេវាសាធារណៈនៃច្រកចេញចូលតែមួយរបស់ខណ្ឌច្បារអំពៅក៏ត្រូវតែមានស្ថិរភាព និរន្តភាព និងឥតឈប់ឈរដូចទៅនឹងសេវាសាធារណៈដទៃទៀតរបស់រដ្ឋដែរ។ ម្យ៉ាងទៀតកាលណាអ្នកផ្តល់សេវាសាធារណៈ ជាពិសេសការិយាល័យច្រកចេញចូលតែមួយជួបនឹងបញ្ហាប្រឈមច្រើន វាក៏អាចរាំងស្ទះដល់ដំណើរការនៃការផ្តល់សេវាសាធារណៈផងដែរ។ ការបង្កើតការិយាល័យច្រកចេញចូលតែមួយនៅខណ្ឌច្បារអំពៅបានជួបប្រទះនូវបញ្ហាប្រឈម ជា

[៥៩] បទសម្ភាសជាមួយនឹងមន្ត្រីការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ, ២៤ មិថុនា ២០១៥។

ច្រើន ដែលជាកត្តាជះឥទ្ធិពលទៅលើការផ្តល់ និងបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ ប៉ុន្តែរាល់បញ្ហាទាំងនោះគឺអាចត្រូវបានដោះស្រាយតាមរយៈមធ្យោបាយមួយចំនួនដូចជា៖

**៣.៣.១.ប្រជាពលរដ្ឋ**

-ដោយសារតែខណ្ឌច្បារអំពៅជាខណ្ឌមួយដែលទើបតែបង្កើតថ្មី ហើយទើបតែដាក់ឱ្យដំណើរការិយាល័យច្រកចេញចូលតែមួយផងនោះ ទើបធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនមានការយល់ដឹងពុំទាន់បានច្បាស់លាស់នៅឡើយ។ ដូច្នេះដើម្បីដោះស្រាយទៅលើបញ្ហានេះអាជ្ញាធរគួរតែផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ក៏ដូចជាបង្កើតវេទិកាសំណេះសំណាលជាមួយប្រជាពលរដ្ឋ ព្រមទាំងណែនាំឱ្យអាជ្ញាធរមូលដ្ឋានធ្វើការផ្សព្វផ្សាយ និងពន្យល់អំពីការមកទទួលសេវានៅការិយាល័យច្រកចេញចូលតែមួយ។

-ប្រជាពលរដ្ឋមួយចំនួនបានបើកអាជីវកម្ម ដោយមិនបានចុះបញ្ជីសុំធ្វើអាជីវកម្មបានត្រឹមត្រូវពីអាជ្ញាធរមូលដ្ឋានមានសមត្ថកិច្ច។ដូច្នេះដើម្បីដោះស្រាយនឹងបញ្ហានេះអាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ និងភូមិគួរតែសហប្រតិបត្តិការជាមួយការិយាល័យច្រកចេញចូលតែមួយយ៉ាងជិតស្និទ្ធ ដើម្បីងាយស្រួលស្រាវជ្រាវរកមុខសញ្ញាអាជីវកម្មមិនត្រឹមត្រូវ។

-ប្រជាពលរដ្ឋមួយចំនួនបានពឹងពាក់អ្នកដទៃឱ្យមកបង់លុយសេវាជំនួស មិនព្រមមកបង់ថ្លៃសេវាដោយខ្លួនឯងទៅលើសេវាដែលបានស្នើសុំនោះទេ ហើយបែរជារិះគន់មកលើការិយាល័យច្រកចេញចូលតែមួយថាយកលុយថ្លៃសេវាច្រើនលើសពីការកំណត់ក្នុងតារាងតម្លៃនៃសេវា។ ដំណោះស្រាយទៅលើបញ្ហានេះ គឺតម្រូវឱ្យគាត់មកបង់ថ្លៃសេវាដោយខ្លួនឯង ហើយមន្ត្រីការិយាល័យច្រកចេញចូលតែមួយគួរតែផ្តល់ខិតប័ណ្ណផ្សព្វផ្សាយអំពីតារាងតម្លៃសេវា ឱ្យទៅប្រជាពលរដ្ឋ។[៥៥]

**៣.៣.២.មន្ត្រីរាជការ**

-កង្វះមន្ត្រីមានក្របខណ្ឌ ០៣រូប ដែលបំពេញការងារនៅផ្នែកជួរមុខ ព្រោះមន្ត្រីទាំងនោះបានផ្ទេរទៅខណ្ឌមានជ័យ។ ដើម្បីដោះស្រាយលើបញ្ហានេះ ក្រសួងសាមីគួរតែបញ្ជូនមន្ត្រីដែលមានក្របខណ្ឌរបស់ខ្លួន ដើម្បីមកបំពេញការងារនូវការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅឱ្យទាន់ពេលវេលាដែលប្រជាពលរដ្ឋចង់បាន។ ការដែលបណ្តោតបណ្តោយឱ្យមានកង្វះអ្នកផ្តល់សេវាបែបនេះអាចធ្វើឱ្យដំណើរការនៃផ្តល់សេវាដល់អតិថិជនមានភាពរអាក់រអួល។

[៥៥] យី ធីរ៉ាត (ប្រធានការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ), បទសម្ភាសដោយ ទី ហុងឡេង, ២២ មិថុនា ២០១៥។

-សមត្ថភាពរបស់មន្ត្រីជួរក្រោយនៅមានកម្រិតនៅឡើយ។ ដូច្នេះដើម្បីដោះស្រាយលើបញ្ហាប្រឈមនេះ មន្ត្រីរាជការ បុគ្គលិកនៃការិយាល័យច្រកចេញចូលតែមួយគួរតែត្រូវរៀបចំវគ្គបណ្តុះបណ្តាលសមត្ថភាពបន្ថែម។

-ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅមានការយឺតយ៉ាវម្តងម្កាល ដោយសារតែដល់ថ្ងៃកំណត់នៃការផ្តល់សេវាជូនប្រជាពលរដ្ឋ ហើយបុគ្គលិកនៃការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅមិនទាន់បានបញ្ចប់ប្រតិបត្តិការការងារលើលិខិតស្នាមដែលយកមកបញ្ជាក់នៅឡើយ ហេតុនេះហើយដំណោះស្រាយដ៏ល្អគឺខាងមន្ត្រី បុគ្គលិកនៃការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅត្រូវអត់ធ្មត់ ហើយនិយាយសុំទោសអតិថិជនដោយពន្យល់អំពីមូលហេតុដែលនាំឱ្យមានការខនខាននៃដំណើរការការងារស្នើសុំសេវា ព្រមទាំងកំណត់ពេលវេលាណាត់ជួបដើម្បីមកទទួលយកឯកសារសារជាថ្មី។

-ទាក់ទងទៅនឹងបញ្ហាម៉ាស៊ីនព្រីន កូពីគាំង ឬលែងដំណើរការដំណោះដ៏ល្អលើចំនុចនេះគឺទាក់ទងជាងមកជួសជុលម៉ាស៊ីនព្រីន កូពីឱ្យបានឆាប់រហ័ស ហើយម្យ៉ាងទៀតគួរតែបន្ថែមចំនួនម៉ាស៊ីនមួយចំនួនបន្ថែមទៀត។

-នៅពេលដាច់ភ្លើងអគ្គិសនីវាជាបញ្ហាមួយ ដែលធ្វើឱ្យការិយាល័យច្រកចេញចូលតែមួយមិនអាចធ្វើការផ្តល់រាល់ប្រតិបត្តិការការងារដល់ប្រជាពលរដ្ឋបានទេ ព្រោះថារាល់ឯកសារត្រូវបានរៀបចំទុកដាក់ដោយបុគ្គលិកនៅទីនោះបានយកសំណុំឯកសារ លិខិតស្នាមផ្សេងៗដាក់បញ្ចូលក្នុងទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រទាំងអស់។ ដូច្នេះហើយបញ្ហានេះត្រូវបានដោះស្រាយតាមរយៈមធ្យោបាយពីរគឺ ការទាក់ទងទៅផ្នែកមន្ត្រីអគ្គិសនីឱ្យជួយពន្លឿនការដោះស្រាយទៅលើបញ្ហាអគ្គិសនីឱ្យឆាប់រហ័ស។ មួយវិញទៀតសាលាខណ្ឌច្បារអំពៅគួរតែទិញម៉ាស៊ីនភ្លើងផ្ទាល់ខ្លួន ដើម្បីការពារនៅពេលគ្មានអគ្គិសនីប្រើប្រាស់។

-ការធ្វើស្លាកលេខម៉ូតូក៏នៅតែមានបញ្ហាតិចតួចកើតមានឡើងផងដែរ ដោយសារតែប្រជាពលរដ្ឋមកទទួលសេវា នៅការិយាល័យច្រកចេញចូលតែមួយគាត់ចង់ជ្រើសរើសយកស្លាកលេខម៉ូតូទៅតាមតម្រូវការរបស់គាត់ដូចដែលប្រជាពលរដ្ឋធ្លាប់ទៅធ្វើស្លាកលេខម៉ូតូ នៅឯមន្ទីរសាធារណៈការនិងដឹកជញ្ជូនពីមុនអញ្ចឹងដែរ។ ដូច្នេះដើម្បីដោះស្រាយលើបញ្ហានេះមន្ត្រី និងបុគ្គលិកការិយាល័យច្រកចេញចូលតែមួយគួរតែពន្យល់ទៅប្រជាពលរដ្ឋពីមូលហេតុ ដែលគាត់មិនអាចរើសលេខបានស្រេចតែចិត្តនោះទេ ដោយសារតែស្លាកលេខម៉ូតូត្រូវបានចងជាលេខស្វ៊ីតក្នុងប្រព័ន្ធកុំព្យូទ័រ។

-មន្ត្រីដែលបម្រើការងារនៅការិយាល័យច្រកចេញចូលតែមួយផ្នែកជួរក្រោយចំនួនមួយរូប ផ្នែកសុរិយោដី និងសំណង់សមត្ថភាពនៅមានកម្រិត ដូច្នេះហើយត្រូវមានដំណោះស្រាយជូនគាត់ដោយបញ្ជូនគាត់ឱ្យទៅរៀនវគ្គបណ្តុះបណ្តាលបន្ថែមទៅលើជំនាញ និងសមត្ថភាពរបស់គាត់ដើម្បីឱ្យការងាររបស់គាត់កាន់តែមានប្រសិទ្ធភាព រហ័សទាន់ពេលវេលា។

# សេចក្តីសន្និដ្ឋាន

ការផ្តល់សេវាសាធារណៈគឺជាកត្តាមួយដ៏ចាំបាច់ក្នុងការអភិវឌ្ឍប្រទេសជាតិ ហេតុនេះហើយទើបរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការផ្តល់សេវាឱ្យកាន់តែល្អជាងមុន តាមរយៈការបង្កើតការិយាល័យច្រកចេញចូលតែមួយ ដែលជាយន្តការមួយត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលក្នុងគោលបំណងដើម្បីធ្វើការកែទម្រង់ប្រព័ន្ធរដ្ឋបាលសាធារណៈនៃការផ្តល់សេវា ឱ្យកាន់តែប្រសើរឡើងជាងមុនជូនប្រជាពលរដ្ឋ។ ការផ្តល់សេវាសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយគឺជាកត្តាមួយជួយជំរុញឱ្យមានការលើកម្ពស់អភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋាន ដែលស្របទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ដោយហេតុតែរាជរដ្ឋាភិបាលបានឃើញអំពីអត្ថប្រយោជន៍ជាច្រើន ដែលទទួលបានពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ ទើបរាជរដ្ឋាភិបាលដោយមានកិច្ចសហប្រតិបត្តិការជាមួយនឹងធនាគារពិភពលោកបានសម្រេចបង្កើតឱ្យមានឡើង នូវការិយាល័យច្រកចេញចូលតែមួយនៅតាមក្រុង ស្រុក ខណ្ឌនៅថ្នាក់មូលដ្ឋានក្នុងគោលបំណងធ្វើឱ្យការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋមានប្រសិទ្ធិភាពជាងមុន ដែលនេះជាកត្តាជំរុញឱ្យស្នូលនៃយុទ្ធសាស្ត្រចតុកោណគឺអភិបាលកិច្ចអាចឆ្ពោះទៅរកគោលដៅ។ ការិយាល័យច្រកចេញចូលតែមួយត្រូវបានបង្កើតសាកល្បងជាបឋមនូវខេត្តបាត់ដំបង និងសៀមរាប ប៉ុន្តែក្រោយមកដោយឃើញពីភាពជោគជ័យ រាជរដ្ឋាភិបាល ក៏សម្រេចបង្កើតការិយាល័យច្រកចូលតែមួយនៅ ក្រុង ស្រុក ខណ្ឌគោលដៅផ្សេងៗទៀតដែលមានទាំងខណ្ឌភាគច្រើននៃរាជធានីភ្នំពេញបូករួមទាំងខណ្ឌច្បារអំពៅផងដែរ។

ការបង្កើតការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ បានផ្តល់នូវផលវិជ្ជមានជាច្រើនជូនប្រជាពលរដ្ឋ អាជ្ញាធរក៏ដូចជារាជរដ្ឋាភិបាល ប៉ុន្តែការបង្កើតការិយាល័យច្រកចេញចូលតែមួយក៏បានផ្តល់នូវផលអវិជ្ជមានតិចតួចបំផុតចំពោះ ប្រជាពលរដ្ឋ មន្ត្រី អាជ្ញាធរ និងរាជរដ្ឋាភិបាល។ លើសពីនេះទៅទៀតតាមរយៈការស្រង់មតិផ្ទាល់ អំពីប្រជាពលរដ្ឋបានបង្ហាញថាអតិថិជនដែលជាអ្នកមកទទួលសេវានូវការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅមានសេចក្តីពេញចិត្ត ក៏ដូចជាគាំទ្រយ៉ាងខ្លាំងចំពោះការបង្កើតការិយាច្រកចេញចូលតែមួយនៅខណ្ឌច្បារអំពៅ ដែលជាទីតាំងមួយដ៏ល្អសម្រាប់ពួកគាត់មកទទួលសេវា ព្រោះថាសេវាទាំង១១វិស័យបានស្ថិតក្រោមដំបូលតែមួយហើយព្រមទាំងការផ្តល់សេវាមានលក្ខណៈល្អប្រសើរជាងមុន ដោយសារតែបែបបទនីតិរដ្ឋបាលមានភាពងាយស្រួល សាមញ្ញ ចំណេញពេលវេលានិងប្រាក់កាស សេវាដែលផ្តល់មានភាពរហ័ស និងមានប្រសិទ្ធិភាព។ ថ្វីបើយោងតាមការស្រង់មតិមានប្រជាជនភាគច្រើនពេញចិត្តទៅនឹង

ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅក៏ពិតមែន ប៉ុន្តែបើយោងតាមការសង្កេតបានបង្ហាញថាមានចំនួនអតិថិជនភាគតិច ដែលបានមកទទួលសេវាពីការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅមិនសូវពេញចិត្ត បើធៀបទៅនឹងចំនួនប្រជាពលរដ្ឋសរុបរបស់ខណ្ឌច្បារអំពៅ។ បញ្ហានេះមិនមែនកើតឡើងដោយគ្មានមូលហេតុទេ គឺកើតមានឡើងដោយសារតែការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅមានកង្វះខាតនូវ មន្ត្រីជំនាញមានក្របខណ្ឌផ្នែកជួរមុខចំនួន ០៣ រូប ដែលនេះអាចជាបញ្ហាប្រឈមមួយធ្វើឱ្យដំណើរការមានការរាំងស្ទះ និងយឺតយ៉ាវ។

សរុបសេចក្ដីមកការផ្ដល់សេវាសាធារណៈ ដែលធ្វើឡើងតាមរយៈការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ គឺជាជម្រើសមួយដ៏ល្អក្នុងការបង្វិតសេវាឱ្យទៅជិតប្រជាពលរដ្ឋក្នុងខណ្ឌច្បារអំពៅ។

## អនុសាសន៍

ក្រោយពីបានចុះទៅស្រាវជ្រាវនៅ ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅបានបង្ហាញឱ្យឃើញថា ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅនៅមានចំណុចខ្វះខាតមួយចំនួនទៅលើការផ្ដល់សេវា។ ដូច្នេះដើម្បីឱ្យការផ្ដល់សេវាសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅកាន់តែប្រសើរឡើង និងរឹតតែមានប្រសិទ្ធភាពនោះ យើងខ្ញុំសូមលើកឡើងនូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

-រាជរដ្ឋាភិបាលគួរតែបញ្ជូនមន្ត្រី ដែលមានក្របខណ្ឌទៅឱ្យការិយាល័យច្រកចេញចូលតែមួយតាមការស្នើសុំឱ្យទាន់ពេលវេលា

-សាលាខណ្ឌគួរតែដាក់ទឹកទទួលភ្ញៀវ នៅក្នុងការិយាល័យច្រកចេញចូលតែមួយ

-មន្ត្រី បុគ្គលិករបស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅគួរតែមានអាកប្បកិរិយារួសរាយរាក់ទាក់ជាងមុន និងព្យាយាមផ្ដល់សេវាឱ្យល្អជាងមុន។

-មន្ត្រី បុគ្គលិករបស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅគួរតែបង្ហាញពីលំហូនីតិវិធីឱ្យបានច្បាស់លាស់ជាងមុន។

-ប្រធានការិយាល័យច្រកចេញចូលតែមួយគួរតែបែងចែករចនាសម្ព័ន្ធធ្វើការ ដើម្បីឱ្យមានអ្នកផ្ដល់ព័ត៌មានឱ្យបានត្រឹមត្រូវ។

-មន្ត្រី បុគ្គលិករបស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅ គួរតែសម្រួលដល់មនុស្សចាស់ជរា និងជាពិសេសអ្នកមិនចេះអក្សរ។

-មន្ត្រី បុគ្គលិករបស់ការិយាល័យច្រកចេញចូលតែមួយខណ្ឌច្បារអំពៅគួរតែផ្ដល់សេវាឱ្យទាន់ថ្ងៃដែលបានសន្យា។

# ឯកសារយោង


-ប្រកាសអន្តរក្រសួងស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, លេខ៣៨៤៥ប្រក, ២៩ វិច្ឆិកា ២០១៣។

-ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុងស្រុកខណ្ឌគោលដៅ, លេខ៩២៨ ប្រក, ១២ មិនា ២០០៩។

-សេចក្តីសម្រេចស្តីពីការកំណត់ក្រុង ស្រុក ខណ្ឌគោលដៅនៃគម្រោងការិយាល័យច្រកចេញចូលតែមួយនិងការិយាល័យប្រជាពលរដ្ឋសម្រាប់អនុវត្តក្នុងឆ្នាំ២០១២-២០១៣, លេខ១០២៨សសរ, ៥ មេសា ២០១២។

-សេចក្តីសម្រេចស្តីពីការផ្ទេរការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋពីរចនាសម្ព័ន្ធសាលាខណ្ឌមានជ័យទៅសាលាខណ្ឌច្បារអំពៅ, លេខ២៣០៧សសរ, ១៧ មិថុនា ២០១៤។

-ដីកាស្តីពីការតែងតាំងមន្ត្រីការិយាល័យច្រកចេញចូលរបស់សាលាខណ្ឌមានជ័យ, លេខ១៤៤ដក.កធម, ១៣ កុម្ភៈ ២០១៤។

-សេចក្តីជូនដំណឹងស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលខណ្ឌច្បារអំពៅ, លេខ០២១សជណ.ចអព.អណ២, ៣ តុលា ២០១៤។

-ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល. ២០០៦. *គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ*។

-ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល. ២០១០. *គុណសម្បត្តិនៃឥរិយាបថរបស់មន្ត្រីរាជការ*។

-ក្រសួងមហាផ្ទៃ. ២០១៣. *ការិយាល័យច្រកចេញចូលតែមួយ*។

-ក្រសួងមហាផ្ទៃ. ២០១៣. *ការិយាល័យប្រជាពលរដ្ឋ*។

-អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល. ២០០៤. *របាយការណ៍ស្តីពីលទ្ធផលការងាររយៈពេល ៥ឆ្នាំ (១៩៩៩-២០០៣)របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល*។

-Erin Thebault-Weiser និងប៉ក់ គឹមជឿន. ២០១៣. *របាយការណ៍ស្តីអំពីមេរៀន និងបទពិសោធន៍ក្នុងការអនុវត្តគម្រោងការិយាល័យច្រកចេញចូលតែមួយនិងការិយាល័យប្រជាពលរដ្ឋ*។

-អ៊ុង ចំរើន. ២០១១. *សិក្ខាប័ននីតិរដ្ឋបាល*. ភ្នំពេញ៖ រោងពុម្ពភ្នំពេញ។

-ក្រសួងមហាផ្ទៃ. ២០១២. នីតិវិធីនៃការអនុវត្តតួនាទី និងភារកិច្ចនៃការិយាល័យច្រកចេញចូលតែមួយ. បទបង្ហាញនៅក្នុងវគ្គបណ្តុះបណ្តាលមន្ត្រីការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ, ក្រុងបាត់ដំបង, ១៤-១៦ វិច្ឆិកា ។

-សាលាខណ្ឌច្បារអំពៅ. ២០១៥. *របាយការណ៍ប្រចាំឆមាសទី១ក្នុងឆ្នាំ២០១៥*, លេខ០៦២. របក.ចអព. ភ្នំពេញ៖ ២៤ មិថុនា។

-សាលាខណ្ឌច្បារអំពៅ. ២០១៥. *របាយការណ៍ប្រចាំឆ្នាំ២០១៤*, ០០២.របក.ចអព. ភ្នំពេញ៖ ២ មករា។

-សាលាខណ្ឌច្បារអំពៅ. ២០១៤. តារាងគណនាប្រាក់រង្វាន់លើកទឹកចិត្ត គិតពីថ្ងៃទី ១០ ខែមិថុនា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤លើចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ និងការផាកពិន័យ, គ្មានលេខ. ភ្នំពេញ៖ ៣១ ធ្នូ។

-សាលាខណ្ឌច្បារអំពៅ. ២០១៥. *របាយការណ៍បូកសរុបលទ្ធផលការចាត់តាំងអនុវត្ត គោលនយោបាយ «ភូមិ-សង្កាត់ មានសុវត្ថិភាព»នៅក្នុងខណ្ឌច្បារអំពៅ ប្រចាំខែឧសភា ឆ្នាំ២០១៥*, ០៥២.របក.ចអព.អណ២. ភ្នំពេញ៖ ២៨ ឧសភា។

-គេហទំព័រ http://www.km.wikipedia.org/wiki/សេវាសាធារណៈ

-គេហទំព័រ http://www.owso.gov.kh

-គេហទំព័រ http://www.owso.gov.kh/?lang=kh&page_id=703